# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៦ លេខ ៣ ខែ មិនា

ព.ស. ២៥០៦ គ.ស. ១៩៦៤

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា នឹងអក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

- សប្បុរិសធម្មកថា តែងរៀបរៀងដោយ ភិក្ខុ អ៊ុង-សុខ វត្តពិភទ្ធរង្សី . . . ២២៩
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ូ តែងរៀបរៀង (ត) . . . ២៤១
- អ្នកមានគុណ រៀបរៀងដោយលោក ហេង-សមអាន នៅសេនាធិការយោធភូមិភាគ ទី ១ ខេត្តកំពង់ចាម . . . . . . . . . . ២៤៩
- ព្រះវិធុរជាតក (ត) . . . . . . . . . . ២៦៥

*ផ្នែកអក្សរសាស្ត្រ*

- ជម្ងឺ មីក្រូ នឹងជម្ងឺវិទ្យុ (វិចារណកថា) លោក ផេង-ជ្រីវ និពន្ធ . . . . ២៧៧
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង (ត) . . . . ២៨៦
- រឿងអាប៊ូលហ៊ាស៊្វីរ៉េស លោក ភ៉យ-ល្អុត ជំណាងរាស្ត្រ ប្រែរៀបរៀង . . . ២៨៨
- ល្បើកឃ្លាហុងតែន លោក ផេង ជ្រីវ ប្រែពីភាសាបារាំង (ត) . . . . ២៩៦
- រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា ង្វៀ-កន ប្រែរៀបរៀង (ត) . . . ៣០០
- ព្រះរាជនិពន្ធ រាជក្បេ ស្រាវជ្រាវ ដោយលោក ឌុ-តាម . . . . . ៣០៧
- រឿងព្រេងចិន (ចចកក្មេងធ្វើជាស្ដេច) លោក ភ៉យ-ប៊ុក ប្រែពីភាសាបារាំង (ត) . . ៣២០
- ទំនៀមទម្លាប់ខ្មែរៈ ល្ខោនបាសាក់ . . . . . . . . ៣២៤

*ផ្នែកកំណត់ទីនប្រវត្តិការណ៍*

- ប្រវត្តិនៃវត្តប្រាង្គ រៀបរៀង ដោយព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា . . . . . . . ៣៣៨
- បុណ្យបញ្ចុះសីមា នឹងឆ្លងវិហារវត្តប្រាង្គ . . . . . . . . ៣៤៣
- រឿងតាំងចៅអធិការ នឹងគ្រូសូត្រក្នុងវត្តនានា ក្នុងព្រះរាជអាណាចក្រ . . . ៣៤៦

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៛០០

## ផ្ចាកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការៈលាមក ឲ្យធ្វើល្អទៅ
ឲ្យផុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

ប.ព.

# សប្បុរិសធម្មកថា

*រៀបរៀងដោយភិក្ខុ អ៊ុង-ស៊ុខ វត្តពិកទូរង្ស៊ី*

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការចំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព ។*

*ពេលនេះ នឹងសំដែងអំពីសប្បុរស ព្រមទាំងធម៌របស់សប្បុរស ដោយសេចក្ដីសង្ខេប តាមក្រសែនៃព្រះពុទ្ធដីកានិងអដ្ឋកថា ដើម្បីជាសណ្ដាប់នៃពុទ្ធបរិស័ទទាំងឡាយ ដូចមានសេចក្ដីដែលត្រូវសំដែងតទៅ :*

*ពាក្យថា « អ្នកសប្បុរស » គឺបុគ្គលដែលប្រកបដោយធម៌សុចរិតគ្រប់ត្រៃទ្វារគឺ កាយ វាចា ចិត្ត ជាអ្នកឃើញប្រយោជន៍ដ៏ធំទូលាយជាសាធារណៈដល់អ្នកដទៃ មិនឃើញត្រឹមតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ យ៉ាងនេះជាដើម ហៅថា « អ្នកសប្បុរសយ៉ាងទ្រង់ក្រិដ្ឋ» ។*

មួយទៀតមនុស្សអ្នកមានចិត្តល្អ មានការប្រព្រឹត្តរៀបរយត្រូវល្អចំពោះលោកអ្នកមានគុណ ចំពោះព្រះសង្ឃ គ្រហស្ថ ចាស់ទុំ ជាអ្នកមានសីលធម៌គួរជាទីជ្រះថ្លាដល់ក្នុងអ្នកផង ក៏ហៅថា «អ្នកសប្បុរស» ។

ពាក្យថា «សប្បុរស» នេះ មកអំពីបាលីថា «សន្តៈ» មានអត្ថឲ្យប្រែបាន ៦ យ៉ាងគឺ :

១– សន្តៈ ប្រែថា «មាន មានគ្រប់គ្រាន់» ដូចបាលីថា : ទ្វេមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា ទុល្លភា លោកស្មឹ «ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ គេរកបានដោយក្រដែលមានក្នុងលោក ។

២– សន្តៈ ប្រែថា «មនុស្សល្អ» ដូចបាលីថា សន្តោ ហវេ សព្ភិ បវេទយន្តិ ពួកមនុស្សល្អរមែងនិយាយនឹងមនុស្សល្អ» ។

៣– សន្តៈ ប្រែថា «ហត់នឿយ» ដូចបាលីថា : ទីឃំ សន្តស្ស យោជនំ «យោជន៍វែងដល់បុគ្គលអ្នកនឿយហត់ ។

៤– សន្តៈ ប្រែថា «រលត់» ដូចបាលីថា : អយញ្ចវិតក្កោ អយញ្ច វិចារោ សន្តា ហោន្តិ «វិតក្កនេះក្តី វិចារនេះក្តី ជាធម៌រលត់ហើយ» ។

៥– សន្តៈ ប្រែថា «ល្អិតល្អ» ដូចបាលីថា អធិគតោ ខោ ម្យាយំ ធម្មោ សន្តោ បណីតោ «ធម៌នេះជាធម៌ល្អិតល្អប្រសើរ ដែលតថាគតត្រាស់ដឹងហើយ ។

៦- សទ្ធៈ ប្រែថា «ស្ងប់ស្ងាប់ ឬ រៀបរយ» ដូចបាលីថា: ទបសន្តស្ស សទា សតិមតោ «បុគ្គលអ្នកស្ងប់ស្ងាប់ ឬរៀបរយ មានស្មារតីគ្រប់កាលទាំងពួង» ។

ពាក្យថា «អ្នកសប្បុរស» ក្នុងទីនេះ សំដៅយកមនុស្សល្អ ឬមនុស្សចិត្តជា ដែលមានសីលធម៌ មានសណ្ដាប់ធ្នាប់ដោយកាយវាចាចិត្តជាសុចរិត អាចឲ្យអ្នកផងគួរសេពគប់ទទួលស្គាល់បាន ។ បុគ្គលរួបរួមទាក់ទងនឹងគ្នាដោយករណីយកិច្ចផ្សេង ៗ តាំងពីពីរនាក់ឡើងទៅ ទោះបីជាតិជាមួយគ្នាក្ដី ជាតិផ្សេងពីគ្នាក្ដី គេហៅថា សហភាព ប្រែថា «ការនៅរួមរួបជាពួកជាមួយគ្នា» ។ ពួកជនក្នុងសហភាពនោះៗ កាលបើគ្មានមនុស្សសប្បុរស គឺមនុស្សល្អហើយ ទោះបីប្រកបកិច្ចការអ្វីមួយក៏មិនបានសម្រេចផលដោយល្អទេ ច្រើនតែមានឧបសគ្គស្ទាក់ស្ទើរដំណើរសេចក្ដីចំរើនទៅវិញ ។ មែនពិត មនុស្សទាំងអស់ក្នុងលោកដែលមានកិច្ចការត្រូវធ្វើ សុទ្ធតែទាក់ទងដោយពួកគណៈ បើមិនច្រើនក៏តិច ព្រោះថាមនុស្សយើងនឹងនៅតាមទំនើងខ្លួនម្នាក់ឯងដោយមិនបាច់ពឹងអាស្រ័យ នឹងអ្នកណាមួយនោះពុំបានឡើយ ។ តាមធម្មតា មនុស្សក្នុងលោកនេះ តែងមានអធ្យាស្រ័យ មានគំនិតផ្សេងៗគ្នា គឺមនុស្សខ្លះមានអធ្យាស្រ័យល្អ គួរគប់រក គួររាប់អាន មានចិត្តទូលាយផ្សាយប្រយោជន៍ដល់ជាតិ សាសនា របស់ខ្លួន ដោយសុចរិតធម៌ស្មោះត្រង់ល្អប្រកបដោយ

មេត្តាករុណា ចំពោះបុគ្គលទូទៅមិនរើសមុខ មិនចំពោះតែត្រកូលត្រូសារខ្លួនឡើយ បុគ្គលបែបនេះលោកហៅថា សប្បុរស ។ មនុស្សសប្បុរស កាលបើមាននៅក្នុងគណៈណា ក្នុងសមាគមណាឬក្នុងទីប្រជុំណា រមែងឲ្យសម្រេចផលល្អ ញុំាងប្រយោជន៍ឲ្យសម្រេចដោយសុវត្ថិភាពដល់គណៈនោះ ដល់សមាគមនោះ ដល់ទីប្រជុំនោះដោយពិតពុំខាន ។ ព្រោះហេតុនោះ ការសេពគប់ត្រូវជ្រើសរើសពិនិត្យបុគ្គលដែលល្អ ដោយហ្មត់ចត់ទើបជាការល្អ ។ មនុស្សខ្លះមានអធ្យាស្រ័យគ្រោតគ្រាតអាក្រក់ គ្មានសុចរិតធម៌ គិតតែប្រយោជន៍ផ្ទាល់ខ្លួន មានចិត្តឫស្យា ឈ្នានិសជិះជាន់ លោភរកប្រយោជន៍តាំងបំពាន គិតតែខាងបានប្រយោជន៍មកខ្លួនដោយផ្លូវទុច្ចរិត មានចិត្តប្រាសចាកមេត្តាករុណា ក្បត់ចិត្តនឹងមនុស្សជាតិផងគ្នា បុគ្គលបែបនេះលោកហៅថា អសប្បុរសគ្រោតគ្រាតបំផុត ។ ក្នុងប្រទេសណាឬក្នុងសមាគមណា បើមានមនុស្សអសប្បុរសនៅលាយឡំផង ប្រទេសនោះនឹងសមាគមនោះនឹងមានអនាធិបតេយ្យ ហើយវិនាសហិនហោចខ្សត់ខ្សោយចុះជាលំដាប់ ៗ

មួយទៀត ពាក្យថា «សប្បុរស» សំគាល់យកមនុស្សមានសុចរិតធម៌ ។ សុចរិតធម៌ទុកដូចជាសញ្ញាប័ត្រមួយដ៏ប្រសើរបំផុត កាលបើបុរសស្ត្រីណាមួយ មានសុចរិតធម៌ បុរសស្ត្រីនោះ គេហៅថាមនុស្សសប្បុរស ។ សុចរិតធម៌ ជាគ្រឿងសំគាល់មួយសម្រាប់ទាយបានថា

ជាសប្បុរស ដែលផ្ទុយគ្នាអំពីអសប្បុរសដោយពិត ព្រោះជាធម៌របស់ សប្បុរសនឹងអសប្បុរស ឃ្លាតគ្នាដូចទិសខាងកើតនឹងទិសខាងលិច ។

ព្រះពុទ្ធសាសនាជាសាសនាដែលសម្បូរទៅដោយសុចរិតធម៌នេះ ច្រើនជាទីបំផុត ។ អ្នកដែលបានសន្សំសុចរិតធម៌ រមែងបាននូវសេចក្តី សុខទាំងបច្ចុប្បន្នទាំងបរលោក ។ សុចរិតធម៌ ជាមូលហេតុនៃសេចក្តី ផ្ទុយគ្នានឹងទុច្ចរិត ចំណែកឯទុច្ចរិតក៏ជាមូលហេតុនៃសេចក្តីទុក្ខ ឬជា មូលហេតុនៃអសន្តិសុខ យ៉ាងនេះវិញក៏បាន ។ រដ្ឋាភិបាលក្នុងប្រទេស នីមួយ ៗ ក៏ត្រូវគិតអំពើសុចរិតនឹងទុច្ចរិតដែរ គឺជាត្រូវប្រមូលសន្សំសុចរិត នឹងត្រូវតែលោងនឹងបន្សាត់ទុច្ចរិតចេញឲ្យអស់ទើបបានគាប់ប្រសើរ ។

ពុទ្ធសាសនា ឈ្មោះថា សកាសន្តិសុខផ្លូវធម៌ ដែលមានព្រះសម្មា សម្ពុទ្ធជាប្រធានរបស់សកា ។ សកាសន្តិសុខក្នុងលោក ក្រៅអំពីព្រះ ពុទ្ធសាសនាឈ្មោះថា សកាសន្តិសុខផ្លូវលោក ជាសកាសម្រាប់រក្សាការ ពារប្រទេស ដើម្បីកុំឲ្យកើតសង្គ្រាមរវាងប្រជាជនក្នុងលោក ឬកុំឲ្យមាន ការចលាចលប៉ុណ្ណោះ ទោះបីមានសកាសន្តិសុខផ្លូវលោកព្រមទាំងមាន គ្រឿងអាវុធជាជំនួយយ៉ាងនេះហើយ ក៏គង់តែកើតសង្គ្រាមឡើងបាន ក្នុងកាលខ្លះពុំខាន ដូចយ៉ាងសន្និបាតជាតិនៅប្រទេសអ៊ឺរ៉ុបក្តី អង្គការ សហប្រជាជាតិក្តី នៅសហរដ្ឋអាមេរិកក្តី សុទ្ធតែជាសកាសន្តិសុខសំ រាប់រលត់ភ្លើងទុក្ខក្នុងលោក បានផលខ្លះពិតមែនហើយ តែជាសកា

សន្តិសុខនេះសម្រាប់រក្សាតែសេចក្ដីស្ងប់ខាងក្រៅតែម្យ៉ាង ៗ ចំណែកខាងព្រះពុទ្ធសាសនា ជាសភាសន្តិសុខផ្លូវធម៌ដ៏ប្រសើរបំផុត ព្រោះអាចរម្ងាប់សត្រូវបានទាំងខាងក្នុងទាំងខាងក្រៅ ហើយនាំអ្នកសមាជិកឲ្យបានមគ្គផលនិព្វាន, មានកម្មវិធីដ៏ជ្រាលជ្រៅសុខុមភាពច្រើនប្រការណាស់ ហើយគួរកប់ថាជាសភាចាស់ទុំមានអាយុជីវិតវែងឆ្ងាយណាស់មកហើយ គួរយើងជាពុទ្ធបរិស័ទរៀបចំជួសជុលឲ្យមានរបៀបឡើង ៗ មួយទៀត សភាសន្តិសុខគឺព្រះពុទ្ធសាសនានេះ មិនបាច់ប្រើគ្រឿងអាវុធយុទ្ធភណ្ឌ ដូចសភាសន្តិសុខផ្លូវលោកឡើយ ។ ចំណែកខាងគ្រឿងអាវុធយុទ្ធភណ្ឌ ក្នុងផ្លូវព្រះពុទ្ធសាសនាក៏មានប្រើដែរ តែជាអាវុធដោយនាមធម៌ សម្រាប់តស៊ូនឹងបច្ចាមិត្រគឺកិលេសមានលោភៈជាដើម មិនមែនអាវុធមានរូបដែលធ្វើអំពីវត្ថុផ្សេង ៗ មានដែកជាដើមនោះទេ ។

អាវុធក្នុងព្រះពុទ្ធសាសនាមាន ៣ យ៉ាងគឺ :

១– សុតាវុធ ការស្ដាប់ ការរៀន ការប្រតិបត្តិធម៌ដោយគោរព នេះឯងទុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា

២– បរិវេកាវុធ ការនៅដោយស្ងប់ស្ងាត់ចាកពួកគណៈ ស្ងប់ស្ងាត់ចាកកិលេសមានរាគៈជាដើម ឬស្ងប់ស្ងាត់ចាកនីវរណធម៌ទាំងឡាយមានកាមច្ឆន្ទៈជាដើម នេះឯងទុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា

៣– បញ្ញាវុធ ការពិចារណារករកហេតុផលរបស់សេចក្ដីសុខ

ទុក្ខ និងហេតុផលនៃលក្ខណ ៣ យ៉ាង មានអនិច្ចលក្ខណជាដើមរបស់បញ្ចក្ខន្ធ នេះឯងទុកជាអាវុធព្រះពុទ្ធសាសនា ។

មួយទៀតព្រះពុទ្ធសាសនា មានដំបូន្មានដ៏ល្អ ៗ ទៀតជាច្រើនណាស់ សម្រាប់ប្រដៅប្រជាជន ដែលមិនទាន់មានសុចរិតធម៌ឲ្យមានសុចរិតធម៌ឡើង ដែលមិនមានឋានៈជាអសប្បុរស ធ្វើឲ្យទៅជាមនុស្សសប្បុរសឡើងបាន តាំងនេះឯងក៏ទុកជាអាវុធដ៏ប្រសើរ ដែលនាំមនុស្សឲ្យក្លាយជាសប្បុរស ។

មួយទៀត សភាគឺទីប្រជុំនិយាយការឯណា ដែលមិនមានមនុស្សសប្បុរសជាសមាជិក ទីនោះមិនឈ្មោះថាជាសភាឡើយ សមដូចពុទ្ធភាសិតក្នុងសំយុត្តនិកាយថា :

នេសា សភា យត្ថ ន សន្តិ សន្តោ
សន្តោ ន តេ យេ ន វទន្តិ ធម្មំ
រាគញ្ច ទោសញ្ច បហាយ មោហំ
ធម្មំ វទន្តា ច ភវន្តិ សន្តោ ។

ប្រែថា មនុស្សសប្បុរសទាំងឡាយ មិនមានក្នុងពួកណា ពួកនោះមិនឈ្មោះថាជាសភាទេ ពួកជនណាមិននិយាយធម៌ ពួកជននោះមិនឈ្មោះថាសប្បុរសទេ លុះតែពួកជនណាដែលលះបង់នូវរាគៈ ទោសៈ មោហៈ ហើយ និយាយនូវធម៌ ទើបឈ្មោះថា «អ្នកសប្បុរស» ។

ពុទ្ធភាសិតនេះ វិនិច្ឆ័យអំពីសភាវរបស់សមាជិកសប្បុរសនិងអសប្បុរសព្រមទាំងវិនិច្ឆ័យអំពីបុគ្គលដែលគួរហៅថាមនុស្សសប្បុរស ។

ទីណាឬប្រទេសណា ដែលសម្បូណ៌ដោយមនុស្សសប្បុរស ទីនោះ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសុខ សេចក្ដីចំរើន ដោយពិតប្រាកដ ឥតអាក់ កុំថាឡើយដល់ទៅសង្គ្រាម សូម្បីតែចោរលួចប្លន់ក៏ពុំមានឡើយ ។ មួយវិញទៀត ធម៌របស់សប្បុរស ឬធម៌សម្រាប់សំគាល់ឲ្យដឹងថា អ្នកនេះជាមនុស្សសប្បុរសឬអសប្បុរសនោះ លោកហៅថាសប្បុរសធម៌មាន ៧ យ៉ាងគឺ :

១- ធម្មញ្ញុតា សេចក្ដីដឹងធម៌ សំដៅយកការដឹងហេតុនៃសេចក្ដីសុខ-ទុក្ខ ហើយកាន់យកហេតុនៃសេចក្ដីសុខ លះបង់ហេតុនៃសេចក្ដីទុក្ខចេញ;

២- អត្ថញ្ញុតា សេចក្ដីដឹងអត្ថគឺដឹងផលនៃសេចក្ដីសុខ ទុក្ខ ហើយតាំងចិត្តសន្ដោស គឺត្រេកអរតាមមានតាមបាន

៣- អត្តញ្ញុតា សេចក្ដីដឹងខ្លួន គឺដឹងថាអាត្មាអញមានជាតិត្រកូលជោគទាបខ្ពង់ខ្ពស់យ៉ាងណា ហើយប្រព្រឹត្តខ្លួនឲ្យសមគួរ មិនឲ្យជាទំនាស់ដល់អ្នកដទៃ

៤- មត្តញ្ញុតា សេចក្ដីដឹងប្រមាណ គឺដឹងច្បាស់ក្នុងការស្វែងរក ក្នុងការទទួលយក ក្នុងការបរិភោគប្រើប្រាស់ចំពោះវត្ថុផ្សេងៗ

ហើយគាប់គេះលៃលកឲ្យសមគួរដល់ប្រមាណ ប្រកបដោយធម៌សន្តោស សមគួរដល់ប្រទេសជាតិរបស់ខ្លួន មិនស្ទុះស្ទារ មិនលោភឡើងឲ្យហួសហេតុពេក ខុសទំនង ដែលនាំឲ្យខូចតម្លៃកិត្តិយសរបស់ជាតិសាសនារបស់ខ្លួន ព្រោះតែនយោបាយរបស់គេនោះឡើយ ។

៥- កាលញ្ញុតា សេចក្ដីដឹងកាល គឺដឹងថាកាលវេលានេះគួរប្រកបកិច្ចការនោះៗ កាលវេលានេះមិនគួរប្រកបកិច្ចការនោះៗ ទេ ។

៦- បរិសញ្ញុតា សេចក្ដីដឹងបរិស័ទ គឺដឹងថាប្រជុំជននេះមានឋានៈបែបនេះ មានកិរិយាបែបនេះ ហើយប្រព្រឹត្តខ្លួនតម្រូវឲ្យសមដល់អធ្យាស្រ័យនៃបរិស័ទនោះ ។

៧- បុគ្គលបរោបរញ្ញុតា សេចក្ដីដឹងបុគ្គលជាន់ខ្ពស់កណ្ដាល ទាប គឺដឹងថា បុគ្គលនេះជាមនុស្សសប្បុរស គឺមនុស្សដែលគួរសេពគប់ បុគ្គលនេះជាមនុស្សអសប្បុរសគឺមនុស្សអាក្រក់ដែលមិនគួរសេពគប់ជាដើម ។

សប្បុរសធម៌ ៧ ប្រការនេះ ទុកជាគ្រាប្រថាប់ឬជាសញ្ញាប័ត្រមួយសម្រាប់ឲ្យទាយបានថា : បើនរណាមានធម៌ ៧ ប្រការនេះ នរនោះទើបឈ្មោះថាជាមនុស្សសប្បុរសដោយពិត បើបុគ្គលណាមិនមានធម៌ ៧ ប្រការនេះទេ បុគ្គលនោះក៏ឈ្មោះថាជាមនុស្សអសប្បុរស ។

មនុស្សយើង ដោយប្រក្រតី រមែងមានធម៌ទាំងនេះតាំងនៅក្នុងខ្លួនខ្លះ

មិនខាន បើមិនមានច្រើនក៏គង់មានតិច ៗ អ្នកដែលមានធម៌នេះតិច មិនគ្រប់គ្រាន់ក្នុងសន្តាន រមែងទៅជាមនុស្សមានសេចក្តីអន់អាចតិច មានសេចក្តីសុខចំរើនក៏តិចតាមលំដាប់ ៗ អ្នកដែលមានធម៌ទាំងនេះច្រើនក្នុងសន្តាន រមែងបានជាមនុស្សមានសមត្ថភាព ថ្ងៃថ្លា មោះមុត អង់អាចច្រើន ធ្វើប្រយោជន៍ដល់ខ្លួនឹងជាតិសាសនារបស់ខ្លួនក៏បានច្រើន ទាំងសេចក្តីសុខ ការសរសើរនឹងកេរ្តិ៍ឈ្មោះ យសសក្តិមានច្រើន ៗ

ព្រះពុទ្ធសាសនា ជាបដិបត្តិឲ្យកើតសន្តិសុខដោយសុភសុភាពសម្រាប់ដឹកនាំមនុស្សឲ្យទៅជាសប្បុរស ៗ ឯពាក្យ «សន្តិសុខ» នេះសំដៅយកសេចក្តីសុខសាន្តទាំងលោកនេះទាំងលោកខាងមុខ ៗ មួយទៀត សេចក្តីសុខនេះមានពីរយ៉ាងគឺ : សេចក្តីសុខដែលកើតអំពីការស្ងប់រម្ងាប់បាតទុក្ខទោសពៃរ៍ភ័យសត្រូវ ជាសេចក្តីសុខសម្រាប់ប្រទេសជាតិរបស់មនុស្ស·ទេព្តា ដែលនៅលាយឡំដោយទុក្ខខ្លះ ហៅថាសាមិសសុខ ១ សេចក្តីសុខស្អាតបរិសុទ្ធដែលកើតអំពីការស្ងប់រម្ងាប់បាតកិលេសបាតបញ្ចក្ខន្ធ គឺជាសេចក្តីសុខដែលមិនលាយឡំដោយទុក្ខទោសពៃរ៍តទៅទៀត បានដល់សេចក្តីសុខរបស់ព្រះនិព្វាន នេះលោកហៅថានិរាមិសសុខ ១ ព្រះពុទ្ធសាសនាតែងឲ្យសម្រេចផលដ៏ទូលាយ គឺសុខពីរប្រការនេះឯង ៗ

ព្រះពុទ្ធសាសនាប្រៀបដូចជាផ្ទះផ្សារមួយខ្នង ដែលមានទំនិញល្អៗជា

ច្រើន ហើយជាទំនិញសុទ្ធតែវត្ថុបរិសុទ្ធ មិនមែនជារបស់ក្លែងក្លាយឬមានពិសពុលក្តៅក្រហាយ ដូចកនផ្សារគឺសាសនាឯទៀតៗ នោះទេ ផ្សារគឺពុទ្ធសាសនានេះ បើកលក់ចំពោះតែរបស់ណាដែលមិនជាសត្រូវ ៗ ទំនិញបរិសុទ្ធនោះគឺមគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើមនិងកុសលធម៌ទាំងឡាយឯទៀតៗ ជាច្រើន គួរតែប្រជាជនក្នុងលោកចូលមកទិញទំនិញល្អៗ នោះតាមត្រូវការ ៗ ព្រះពុទ្ធសាសនា មានបញ្ញត្តសិក្ខាបទជាសាធារណៈដល់មនុស្សនិងមនុស្សផងគ្នា ព្រមទាំងដល់មនុស្សនិងតិរច្ឆានឥតមានរើសជាតិឡើយ ទោះបីមនុស្សក៏ត្រូវមានធម៌សុចរិតក្នុងសន្តានរវាងសត្វតិរច្ឆាន ៗ ព្រោះសត្វតិរច្ឆានមានជីវិតជាទីស្រឡាញ់ មានមេ មានបា មានកូនជាទីស្រឡាញ់របស់វាយ៉ាងណា មនុស្សយើងក៏យ៉ាងនោះដែរ ៗ សាសនាឯទៀតៗ ក្រៅពីនេះឬច្បាប់បញ្ញត្តរបស់ប្រទេសទាំងឡាយក្នុងលោក ច្រើនតែបញ្ញត្តតឹងរឹងតែក្នុងរវាងមនុស្សនិងមនុស្ស ដូចយ៉ាងផ្លូវបាណាតិបាតឬអទិន្នាទានជាដើម ចំពោះតែមនុស្សផងដូចគ្នា ត្រង់មនុស្សសម្លាប់តិរច្ឆានឬលួចប្លន់ដណ្តើមសុតសត្វតិរច្ឆានកូនចៅសត្វតិរច្ឆាន មិនឃើញមានបញ្ញត្តផងឡើយ ៗ

បុគ្គលជាមនុស្សជាតិណាមួយ កាន់ធម៌សុចរិតទៀងទាត់ពិតត្រង់ក្នុងការរបស់ប្រទេស របស់សាសនា ទាំងរវាងមនុស្សនិងមនុស្សដូចគ្នា. ទោះបីជាមនុស្សជាន់ទាបឬជាន់ខ្ពស់ ក៏មិនត្រូវប្រមាថមើលងាយទៀត

បៀនរឹបជាន់ផល់គ្នានឹងគ្នាទេ ទាំងមនុស្សក៏ត្រូវកាន់ធម៌សុចរិតចំពោះតិរច្ឆានផងដែរ ។ បុគ្គលអ្នកកាន់ធម៌តាមបញ្ញត្តិនៃព្រះពុទ្ធសាសនាដូច្នេះ ហៅថាសប្បុរស ។ មនុស្សសប្បុរសនេះ ច្រើនមានតែក្នុងព្រះពុទ្ធសាសនា អ្នកដែលកាន់ធម៌សុចរិតរើសមុខដោយអាងថា: ខ្លួនអញជាមនុស្សជាន់ខ្ពស់ ជាអ្នកមានយសសក្តិអំណាច ជាមនុស្សមានកម្លាំងទ្រព្យធនច្រើន ជាមនុស្សមានឧបាយកិច្ចកលច្រើន ហើយបៀតបៀនសង្កត់សង្កិនមនុស្សដែលថោកទាបបៀតបៀនមនុស្សដែលឥតយសសក្តិ មើលងាយមនុស្សដែលក្រទ័លទ្រព្យសម្បត្តិ បោកប្រាស់បំបាត់មនុស្សដែលល្ងង់ខ្លៅដែលគ្មានឧបាយ អ្នកដែលមានសេចក្តីប្រមាថពាយងាយដូច្នេះ ទោះបីបន្ទំខ្លួននៅក្នុងសាសនាក៏ហៅថាអសប្បុរសដែរ ។

> ជនដទៃ តែជាអ្នកធ្វើប្រយោជន៍ឲ្យយើង ទុកជាផៅពង្ស
> ឯផៅពង្សពិត តែជាអ្នកមិនធ្វើប្រយោជន៍ឲ្យយើង ក៏ទុក
> ជាអ្នកដទៃ រោគកើតក្នុងកាយយើងពិត ៗ រកប្រ
> យោជន៍គ្មាន ថ្នាំកើតនៅក្នុងព្រៃ ធ្វើប្រយោជន៍ឲ្យយើង
>
> ហិតោបទេស

# ព្រះអភិធម្មបិដក

( គម្ពីរព្រះមហាបដ្ឋាន )

លោក ប៊ូ - ប៊ូ រៀបរៀង

តមក

---

កុសលជាឧបបីឡិកកម្មនោះ គឺបុគ្គលធ្វើអកុសលកម្មរួចហើយ កុសលមកបៀតបៀនអកុសល កុសលឲ្យផលដោយខ្លួនឯង មិនឲ្យអកុសលឲ្យផលឡើយ ដូចជាកុសលនៃនាយចោរឃាតកបុរសអ្នកសម្លាប់ចោរឈ្មោះរាតកាលកបុរស ។

## រឿងនាយចោរឃាតក

រាជគហោ កិរ បានឮរឿងមកថា នាយចោរឃាតកនោះជាអ្នកសម្លាប់ចោរនៅក្នុងនគររាជគ្រឹះ ព្រះមហាក្សត្រទ្រង់តាំងទុកក្នុងឋានន្តរឲ្យជាអ្នកសម្លាប់ចោរ បើអ្នកស្រុកចាប់ចោរបានតិចក្តីច្រើនក្តី នាំយកមកដល់ហើយ នាយចោរឃាតកឈ្មោះរាតកាលកនោះ ចេះតែសម្លាប់ចោលទាំងអស់ គ្រប់ពេលវេលា ឥតលោះទានថ្ងៃណាឡើយ ។ នាយចោរឃាតកនោះសម្លាប់ចោរតាំងពីខ្លួននៅក្មេងរហូតដល់ចាស់ជរាចំនួន ៥០ ឆ្នាំមកហើយ ដល់គ្រាខ្លួនចាស់ជរា ថយកម្លាំង កាប់ចោរតែម្តងមិនស្លាប់ទេ ត្រូវកាប់ពីរបីដងទើបចោរស្លាប់ ។

វញ្ញា អាភេចេស៊ុំ អមាត្យទាំងឡាយនាំសេចក្ដីនោះក្រាបទូលចំពោះព្រះមហាក្សត្រថា មហាល្ហោកា ឧសក្កោតិ នាយចោរឃាតកនោះចាស់ជរាទុព្វលភាពហើយ មិនអាចប្រហារនូវចោរទាំងឡាយឲ្យក្ស័យជីវិតដោយការប្រហារតែម្ដងបានទេ ធ្វើឲ្យពួកចោរបានសេចក្ដីលំបាកខ្លាំងណាស់ សូមព្រះអង្គទ្រង់ជ្រាប ។

ព្រះបរមក្សត្រមានព្រះឱង្ការត្រាស់ថា អបេថ ធំបើដូច្នោះហើយអ្នកលំនាំគ្នាចូរដក បញ្ឈប់នូវនាយឃាតកាលកចោរឃាតកពីឋានន្តរនោះចុះចូរតាំងនូវបុរសដទៃទៀតក្នុងដំណែងចោរឃាតកនោះវិញ ។ អមាត្យទាំងពួង ក៏ធ្វើតាមព្រះរាជបញ្ជា បញ្ឈប់នាយឃាតកាលកបុរសនោះចេញហើយយកបុរសឯទៀតមកធ្វើជំនួសវិញ ។

ចំណែកនាយឃាតកាលកបុរសនោះ លុះបានរួចផុតពីដំណែងជាអ្នកសម្លាប់ចោរហើយ ក៏នឹកចង់ស្លៀកដណ្ដប់សំពត់ថ្មី គាក់តែងខ្លួនប្រាណដោយកម្រងផ្កាមានក្លិនក្រអូប ប្រាថ្នានឹងបរិភោគនូវបាយបាយាស នឹងចង់ប្រស់ព្រំកាយដោយគ្រឿងអប់ ចង់ងូតទឹកជម្រះកាយ ដោយទឹកក្រអូប ព្រោះថានាយឃាតកាលកនោះ កាលនៅធ្វើការសម្លាប់ចោរដរាបណា មិនដែលបានស្លៀកពាក់សំពត់ការថ្មី មិនដែលបានសៀតកម្រងផ្កានឹងបរិភោគបាយបាយាស នឹងលុបលាងកាយដោយគ្រឿងអប់ ជម្រះកាយដោយទឹកក្រអូបដរាបនោះ ។ ហេតុដូច្នោះ នាយឃាតកាលកនោះ លុះ

ចេញផុតពីដំណែងជាពេជ្ឈឃាតហើយ ទើបនឹកក្នុងចិត្តថា មេ ចរិតំ តាំង ពីអញប្រព្រឹត្តអំពើដ៏សៅហ្មងនេះ ជាយូរយារណាស់ ប្រមាណ៥០ឆ្នាំ ហើយ មិនដែលបានបរិភោគអាហារល្អ ៗ មិនដែលបានស្លៀកពាក់សំពត់ អាវថ្មី ៗ សោះ គិតរួចក៏ស្រែកហៅភរិយាមកបង្គាប់ឲ្យដណ្តាំបាយបាយាស ហើយឲ្យយកគ្រឿងលំអិតក្រអូបសម្រាប់ងូតទឹក ហើយទៅឯកំពង់ទឹក ងូតជម្រះសរីរៈឥន្ទ្រិយ៍កក់ក្បាលដោយប្រេងដែលចម្រាញ់បានមួយរយដង ហើយស្លៀកពាក់សំពត់អាវថ្មី លុបលាងសរីរកាយដោយគ្រឿងក្រអូប ស្លៀកផ្កាតាក់តែងខ្លួនដោយប្រដាប់យ៉ាងល្អឆើតឆាយ ដើរមកតាមមាគ៌ាវិថី ក៏បានឃើញព្រះធម្មសេនាបតីសារីបុត្រនិមន្តពីមុខខ្លួនចូលមក ទើបមានចិត្ត សោមនស្សរីករាយ គិតថាអញចេញផុតពីកម្មដ៏សៅហ្មងក្នុងថ្ងៃនេះ ស្រាប់ តែបានមកជួបប្រទះនឹងលោកម្ចាស់សារីបុត្រ គួរតែអញនឹងធ្វើកុសល ប្រគេនអាហារបិណ្ឌបាត គិតរួចក៏អារាធនាឲ្យទទួលអាហារបិណ្ឌបាតក្នុង គេហស្ថាន ហើយទទួលបាត្រព្រះមហាថេរទៅឯផ្ទះ និមន្តចូលទៅខាង ក្នុងផ្ទះ ហើយឲ្យគង់លើអាសនៈដែលតាក់តែងល្អស្អាត ហើយចាត់ចែង អង្គាសដោយបាយបាយាសដ៏លាយដោយសប្បិ នឹងលំអិតខៃស្ករក្រាម ៗ

អនុមោទនំ អកាសិ ព្រះសារីបុត្តត្ថេរជាម្ចាស់ធ្វើភត្តកិច្ចស្រេច ហើយ ក៏ធ្វើអនុមោទនាថា ឃរំ ហោតុ អ្នកប្រាថ្នាយ៉ាងណា សូមឲ្យ បានសម្រេចយ៉ាងនោះចុះ ឥច្ឆិតំ បត្ថិតំ សេចក្តីប្រាថ្នាដែលអ្នកប្រាថ្នា

ហើយដោយកាយវាចានិងចិត្ត ចូរឲ្យបានសម្រេចយ៉ាងឆាប់រហ័ស

សព្វេ បូរេន្តុ សង្កប្បា សេចក្តីត្រិះរិះទាំងឡាយចូរពេញបរិបូណ៌ក្នុង

ខន្ធសន្តាន ប្រៀបដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី បើមិនដូច្នោះទេ សេចក្តី

ត្រិះរិះរបស់អ្នកចូរសម្រេចតាមប្រាថ្នា ដូចជាកែវមណីជោតិដែលឲ្យ

សម្រេចកិច្ចគ្រប់ប្រការ ធានំ សក្កស្ស សោចានំ ទាននេះជា

ជណ្តើរឡើងទៅកាន់ស្ថានសួគ៌ អាចកំចាត់បង់នូវសេចក្តីទាល់ក្របាន

អាចវេចខ្ចប់ទៅនូវស្បៀងក្នុងមាគ៌ាឲ្យម៉ាំទាំងដល់នូវនិព្វាន ទាននេះជា

គន្លងផ្លូវទៅនិព្វាន ។ ព្រះសារីបុត្តត្ថេរជាម្ចាស់ធ្វើអនុមោទនាដូច្នេះ

នាយវាតកាលកនោះ បានស្តាប់ចប់ហើយ ក៏បាននូវអនុលោមខន្តី ។ ព្រះ

សារីបុត្តត្ថេរធ្វើអនុមោទនាចប់ហើយ ក៏ចុះចាកគេហស្ថាន នាយវាតកាលក

កាន់បាត្រជូនដំណើររហូតទៅដល់ខាងក្រៅភូមិ ប្រគេនបាត្រទៅព្រះថេរ

ហើយត្រឡប់មកវិញ ដល់ពាក់កណ្តាលផ្លូវ មានមេគោមកជល់នាយវាត-

កាលកឲ្យដួលដេកក្ស័យជីវិតទៅ លុះរលត់បញ្ចក្ខន្ធហើយ បានទៅកើត

ក្នុងតាវត្តឹង្សពិភព បានសោយទិព្វសម្បត្តិ មានទេពអប្សរជាបរិវារ ។

កុសលកម្មនៃនាយវាតកាលកនេះឈ្មោះថា កុសលកាត់អកុសល.

បាន ព្រោះហេតុប្រគេនបិណ្ឌបាតប្រកបដោយសេចក្តីជ្រះថ្លាក្នុងកាល

ទាំងបី គឺបុព្វចេតនា មុញ្ចនចេតនា បរាបរចេតនា កុសលទើបកាត់

អកុសលបានដូចវិសជ្ជនាមកនេះ ។

ឧបបីឡកកម្ម សង្ខេបប៉ុណ្ណោះ :

## ១១– ឧបច្ឆេទកកម្ម (១)

កុសលច្ឆេទកំ ពល ឯរកាបត្តស្ស នាគរញ្ញោ កុសលច្ឆេទកមេវ វេទិតព្វំ សោ កិរ សេដ្ឋី វស្សស ហស្សានិ សមណធម្មំ បូរេសិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងកម្មបច្ច័យសំដែងនូវឧបច្ឆេទកកម្មតទៅ ។ អ្នកប្រាជ្ញគប្បីចូលចិត្តថា ឧបបីឡកកម្មដូចសំដែងមកហើយក្តី ឧបឃាដ-កកម្មក្តី ឧបច្ឆេទកកម្មក្តី មានសេចក្តីអធិប្បាយដូចគ្នា ការដែលឲ្យផលសោតទៀត ក៏ដូចគ្នាដែរ ប្លែកតែបាលីគឺ ឧបបីឡកកម្មនោះប្រែថាបៀតបៀន ឧបឃាដកកម្មនោះប្រែថាសម្លាប់ ឧបច្ឆេទកកម្មនោះប្រែថាកាត់ ។

ដំណើរសេចក្តីក្នុងឧបច្ឆេទកកម្មតអនុសន្ធិថា កុសលច្ឆេទកំ ពល គឺឯឧបច្ឆេទកកម្មជាអកុសល កាត់បង់នូវកុសល គឺមិនបានញុំាងកុ-សលឲ្យ ។ ផលដោយខ្លួនឯង ដូចអកុសលនៃឯរកបត្តនាគរាជនោះ កាត់បង់នូវកុសល គឺមិនបានញុំាងកុសលឲ្យសម្រេចផល អកុសលកាត់បង់នូវកុសល អកុសលឲ្យផលដោយខ្លួនឯង ។

### រឿងឯរកបត្តនាគរាជ

សោ កិរ បានឮមកថា ឯរកបត្តនាគរាជនោះ ពីអតីតកាល ក្នុងគ្រាសាសនានៃសម្តេចព្រះបរមទសពល សម្មាសម្ពុទ្ធមួយព្រះអង្គ ជាកុល-

---

១– ក្នុងក្បួនខ្លះហៅថា ឧបឃាដកកម្ម ។

បុត្រប្រកបដោយសទ្ធា បព្វជ្ជាឧបសម្បទជាភិក្ខុក្នុងព្រះបវរពុទ្ធសាសនា បំពេញព្រះសមណធម៌មកបានមួយម៉ឺនឆ្នាំ ថ្ងៃមួយ ជិះទូកទឹងឆ្លងស្ទឹងទៅត្រើយម្ខាង កាលចុះទៅដល់ទូកនោះ ចាប់ទាញស្លឹករៃទឹកទៅក្បែរច្រាំង លុះទូកលឿនទៅ មិនបានលែងស្លឹករៃទឹកនោះចោល ស្លឹករៃទឹកក៏ដាច់ដោយអំណាចកម្លាំងទូកលឿនទៅ លុះឆ្លងទៅដល់ត្រើយម្ខាងហើយ នឹកមិនឃើញ ចំណេរលង់មក កាលជិតនឹងរលត់បញ្ចក្ខន្ធទើបនឹករឭកឃើញពីរឿងធ្វើឲ្យដាច់ស្លឹករៃទឹកនោះ ប៉ុន្តែនឹងរកភិក្ខុអង្គណាមួយសំដែងអាបត្តិនោះមិនបាន ។ ភិក្ខុនោះកើតវិប្បដិសារ មានសេចក្តីក្តៅក្រហាយ តានតឹងក្នុងចិត្ត លុះអស់ជីវិត បានទៅកើតក្នុងកំណើតសត្វ-តិរច្ឆាន ជាស្តេចនាគដោយអំណាចនៃអកុសល ឯសមណធម៌ដែលខ្លួនប្រព្រឹត្តចំនួនមួយម៉ឺនឆ្នាំនោះ មិនបានឲ្យផលទេ ព្រោះហេតុអកុសលជាឧបច្ឆេទកកម្មកាត់កុសល ។

ហេតុនោះ សម្តេចព្រះបរមទសពល ទើបត្រាស់ទេសនាថា កម្មនេះឈ្មោះថាបច្ច័យ ។ ឯកុសលកម្មកាត់ផ្តាច់អកុសលកម្មចេញក៏មាន ដូចបុគ្គលធ្វើតែអំពើអកុសលមកជាយូរយារច្រើនឆ្នាំ កាលជិតនឹងអស់ជីវិតក៏ត្រេកអរក្នុងពុទ្ធបូជា លុះរលត់បញ្ចក្ខន្ធហើយ កុសលនោះកាត់ផ្តាច់អកុសលបាន ។ ទៅកើតក្នុងស្ថានសួគ៌ ដូចជាបិតានៃព្រះមហាថេរមួយអង្គ ។

# រឿងនាយព្រានម្រឹគ

មាននាយព្រានម្រឹគម្នាក់ ជាបិតានៃព្រះមហាថេរ តែងដើរបរបាញ់សម្លាប់សត្វលក់ចិញ្ចឹមជីវិតរៀងរាល់ថ្ងៃជាយូរឆ្នាំ លុះដល់ខ្លួនចាស់ជរាហើយ ក៏ចូលទៅបួសនៅជាមួយព្រះមហាថេរជាកូនរបស់ខ្លួន ៗ ព្រះមហាថេរជាបុត្រប្រាប់បិតាឲ្យបរិកម្មការនា ៗ កាលភិក្ខុចាស់ជរាធ្វើបរិកម្មការនាយូរទៅ ព្រះកម្មដ្ឋានក៏មិនបានកើតមានប្រាកដក្នុងចិត្តសោះ ពេះតែឲ្យនឹករឭកឃើញពីការដែលខ្លួនសម្លាប់ម្រឹគ មិនអាចតាំងសតិស្មារតីចំពោះព្រះកម្មដ្ឋានបាន ទើបចូលទៅប្រាប់ព្រះមហាថេរជាបុត្រ ៗ ព្រះមហាថេរក៏ប្រាប់ឲ្យចំរើនព្រះកម្មដ្ឋាននោះជានិច្ចតមកទៀត ៗ

កាលភិក្ខុចាស់ជរានោះ មានជម្ងឺឈឺធ្ងន់ជិតក្ស័យជីវិត ព្រះមហាថេរជាបុត្រគិតថា បិតាអញនេះ កាលបើស្លាប់ទៅហើយ មិនគួរទឹងទៅទុគ្គតិទេ ទើបព្រះមហាថេរគាត់តែងគ្រឿងសក្ការបូជា យកទៅដាក់នៅខាងក្បាលដំណេកបិតា ហើយប្រាប់ថា បិតាចូរញុំាងចិត្តឲ្យជ្រះថ្លាចុះ គ្រឿងសក្ការបូជានេះ អាត្មាគាត់តែងទុកឲ្យលោកជាបិតាយកទៅថ្វាយបង្គំព្រះចេតិយ ៗ ភិក្ខុចាស់ជរាក៏មានចិត្តត្រេកអរគិតប្រាថ្នាទិងនមស្ការព្រះចេតិយដោយគ្រឿងសក្ការបូជានោះ លុះរលត់បញ្ចក្ខន្ធក៏បានឡើងទៅកើតក្នុងស្ថានសួគ៌ នេះឈ្មោះថាកុសលកម្មជាឧបច្ឆេទកកម្មកាត់អកុសល ហាមឃាត់អកុសលមិនឲ្យ ៗ ផល កុសលឲ្យផលខ្លួនឯងវិញដូច្នេះ ៗ

កុសលក្តី អកុសលក្តី ទាំងពីរប្រការ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថាជាអចិន្តេយ្យ មិនគួរអ្នកណានឹងគប្បីគិត ព្រោះសម្តេចព្រះភគវន្តបពិត្រប្រទានព្រះសទ្ធម្មទេសនាថា កម្មវិស័យជាអចិន្តេយ្យៈ គឺអ្នកណាគិតនឹងញុំាងចិត្តអ្នកនោះឲ្យរាយមាយ ។ ឯការដែលកុសលនឹងកាត់ផលហាមឃាត់ផលនៃអកុសលនោះ ដោយអំណាចនៃកុសលជាយថាសន្នកម្ម គឺនឹករឭកឃើញឬធ្វើនៅពេលជិតអស់ជីវិត កុសលនោះកាត់ផ្តាច់នូវផលនៃអកុសលបាន ។ ហេតុនោះ បុគ្គលដែលកើតមកក្នុងលោកវិស័យ កាលគាំងនៅក្នុងបឋមវ័យ មិនបានធ្វើនូវទីពឹង គឺការកុសលសីលទានជាដើម លុះដល់មជ្ឈិមវ័យ បូរឧស្សាហ៍ធ្វើការកុសល ។ ការកើតមកក្នុងវដ្តសង្សារនេះ ប្រៀបដូចមនុស្សដើរតាមមាគ៌ា បុគ្គលដែលបានរចនាការកសាងកុសលទុក ប្រៀបដូចអ្នកដំណើរមានស្បៀងទៅតាមផ្លូវ ។ ធម្មតាអ្នកដើរផ្លូវឆ្ងាយ ហើយមានស្បៀងនោះ សូម្បីកន្លងយប់កន្លងថ្ងៃទៅដល់ប៉ុន្មាន ៗ ក្តី ក៏អាចទៅដល់ទីកន្លែងដែលខ្លួនប្រាថ្នានឹងទៅនោះបាន សេចក្តីនេះមានឧបមាដូចម្តេច ។ បុគ្គលដែលកើតមកក្នុងសង្សារវដ្តមានចិត្តប្រាថ្នាព្រះអមតមហានិព្វាន ហើយកសាងធ្វើការកុសលមិនធ្វេសប្រហែស កាលខ្លួនធ្វើដំណើរទៅក្នុងផ្លូវកន្តារគឺសង្សារវដ្ត សូម្បីមិនទាន់អស់ជាតិអស់ភព ក៏នឹងបានបរិភោគផលនៃកុសលជាស្បៀងរៀងរហូតទៅ បើគ្រប់មួយបណិធានកាលណា ក៏នឹងបានសម្រេចដូចសេចក្តីប្រាថ្នាកាលនោះ ព្រោះខ្លួនមានស្បៀង គឺសីលនឹងទានជាដើម ។

# អ្នកមានគុណ

## ពាក្យកាព្យ

និពន្ធដោយលោក ហោង-សមអាន

---

នៅសេនាធិការយោធភូមិភាគទី ១ ខែត្រកំពង់ចាម

អតីតគ្រូបង្រៀនយុទ្ធសាស្ត្រ នៃមជ្ឈមណ្ឌលសិក្សាពលថ្មើរជើង

ខែត្រពោធិសត្វ

### សេចក្ដីផ្ដើម

បទព្រហ្មគីត

| | |
|---|---|
| ខ្ញុំសូមអភិវាទ | ព្រះលោកនាថជាម្ចាស់ |
| ព្រះអង្គទ្រង់បានត្រាស់ | ធម៌ល្អណាស់ដល់សព្វសត្វ ។ |
| ដែលមានចិត្តជ្រះថ្លា | ប៉ងប្រាថ្នានឹងប្រតិបត្តិ |
| ដើម្បីកយកំចាត់ | ឲ្យកិលេសឆេះឆាបឆាប់ ។ |
| ខ្ញុំសូមក្រាបវន្ទា | ព្រះធម្មាដ៏ចំណាប់ |
| ជ្រាលជ្រៅតាមលំដាប់ | ប្រសើរជាងច្បាប់ដទៃ ។ |
| គឺជាពាក្យប្រធាន | ល្អឥតមានល្អក់មោះមៃ |
| ល្អិតល្អន់ពន់ប្រពៃ | ថ្វីព្រះឧស្សព្រះសម្ពុទ្ធ ។ |
| ខ្ញុំសូមបង្គំផង | ពោះព្រះសង្ឃអង្គកុលបុត្រ |
| មានសីលដ៏បរិសុទ្ធ | វិសេសផុតមនុស្សទេព្ដា ។ |

លោកមានចិត្តស្អាតបាត　　គ្រាប់ពូជព្រះសាស្តា
ជាស្រែមានផ្លែផ្កា　　មានដីជាតពុតគ្នាកើត ។
　　ដោយគេដនមស្អាត　　ផ្លែអស្ចារ្យវិសេសពេក
ឧបសគ្គបំរុងកើត　　សូមវិនាសចៀសចេញក្រៅ ។
សូមកុំកើតសង្គ្រាម　　មេខ្មាំងនាំសោកសៅ
រលត់រលាយទៅ　　សូមសុខសាន្តបានឋិតថេរ ។
　　តទៅសូមបរិយាយ　　កែដោះស្រាយទុកជាកេរ្តិ៍
អ្នកមានគុណលើខ្មែរ　　គឺម៉ែ.ឪទាំងទាហារ ។
នឹងគុណព្រះអគ្គ:　　មហាវីរៈដ៏អស្ចារ្យ
ដែលទ្រង់ខំចាត់ការ　　កសាងជាតិបានសុខសាន្ត ។
តស៊ូនឹងឧបសគ្គ　　ទ្រង់លុកស្ទាក់គ្រប់ទិសឋាន
ដើម្បីរកសុខសាន្ត　　ឲ្យជាតិខ្មែរបានសប្បាយ ។
មិនខុសពីឪពុក　　ដែលស្វែងលុករុកទម្លាយ
ឧបសគ្គធាក់ធ្លុះធ្លាយ　　ដើម្បីរកនូវមាសប្រាក់ ។
ចិញ្ចឹមកូនប្រុសស្រី　　ដោយមេត្រីក្តីពក់ពាក់
ខំស្រាយកាយបញ្ជាក់　　ជាពាក្យកាព្យមានសម្រស់ ។

## អ្នកមានគុណ

　　មាតានិងបិតា　　ក្នុងលោកាគ្រប់ទាំងអស់

តែងមានចិត្តសប្បុរស　　ចំពោះកូនគ្រប់ ៗ ប្រាណ ។
លោកអាចថែរក្សា　　បុត្តធីតាទាំងឡាយបាន
ឋិតនៅសុខក្សេមក្សាន្ត　　អាស្រ័យព្រហ្មវិហារធម៌ ។
　　ឪពុក-ម្តាយទាំងឡាយ　　លោកតែងផ្សាយដោយស្មោះសរ
នូវព្រហ្មវិហារធម៌　　ដល់គ្រប់កូនទាំងប្រុសស្រី ។
ស្មើស្មើគ្នាទាំងអស់　　ញញឹមស្រស់ស្មោះមេត្រី
ថ្នាក់ថ្នមបមពរបី　　យ៉ាងជិតស្និទ្ធឥតហ្មងសៅ ។
មិនថាកូនមានក្រ　　អាក្រក់ល្អកាយស-ខ្មៅ
កូនបេះកូនល្ងង់ខ្លៅ　　កមដំបៅរមាស់ស្រែង ។
វៀចមាត់វៀចចង្កា　　ខ្វាក់ទេត្រាក្បាលត្រមែង
ខ្វិនដើរនៅកន្លែង　　តឿកន្ទុញសុញ្ញពា ។
លោកខំប្រឹងស្វះស្វែង　　គ្រប់កន្លែងទិសនានា
ថ្ងៃយប់គ្រប់វេលា　　ដើម្បីរកសុភមង្គល ។
　　មិនតែប៉ុណ្ណោះឯង　　ម៉ែឪតែងតែកង្វល់
ក្នុងចិត្តគិតទៅដល់　　កូនប្រុសស្រីពេលយប់ថ្ងៃ ។
ខ្លាចក្រែងកូនកើតទុក្ខ　　ជម្ងឺរុកពេកពាំរ៉ៃ
ឬក្រែងចោរចង្រៃ　　ប្លន់ដណ្តើមទ្រព្យសម្បត្តិ ។
លោកតែងបន់ទេព្តា　　ដែលរក្សាមហាស្វេតច្ឆត្រ

របស់ព្រះមហាក្សត្រ    កម្ពុជាបុទ្ធីល្បី ។
ឧិនវត្តស័ក្តិសិទ្ធិ    ពួកពិតក្នុងលោកិយ
សុំឲ្យកូនប្រុសស្រី    កើតសួស្តីទាំងយប់ថ្ងៃ ។
ពិសេសជាងនេះទៀត    ម៉ែឪធ្មៀតអប់ទ្រៃ
ប្រដៅកូនរាល់ថ្ងៃ    ឲ្យស៊ីវិល័យតាមនិយម ។
ឲ្យកូនទាំងប្រុសស្រី    ស្គាល់ត្រូវ ខុសច្បាប់សង្គម
ស្គាល់ក្មេង ស្គាល់ចាស់ទុំ    ស្គាល់អ្នកធំ អុំមីងមា ។
ឲ្យញាតិមិត្រជិតឆ្ងាយ    មូលស្រស់ស្រាយស្ម័គ្រចិន្តា
រាប់អានស្និទ្ធស្នេហា    បុគ្គពីតាយ៉ាងជិតដិត ។
ឲ្យកូនខំរៀនសូត្រ    បេះរហូតថ្នាក់បណ្ឌិត
រៀនសព្វវិជ្ជាពិត    តាមកម្លាំងនៃបញ្ញា ។
ឲ្យកូនចេះរួមរ័ក    មូលស្មោះស្ម័គ្រស្មើចិន្តា
រាប់អានស្និទ្ធស្នេហា    ជាសាមគ្គីស្អិតជាប់នៅ ។
បំណាមកូនស្រីប្រុស    មានត្រូវខុសមានសខ្មៅ
មានប្រាជ្ញមានល្ងង់ខ្លៅ    ពាលកម្លៅនឹងបណ្ឌិត ។
បើកូនប្រុសស្រីណា    កាន់កិរិយាទុច្ចរិត
កោងកាចព្រហើនពិត    ហ៊ានប្រមាថឪពុក ម្ដាយ ។
ប្រព្រឹត្តជក់កញ្ឆា    ផឹកសុរាមេអន្តកាយ
លេងល្បែងភ្នាល់ទាំងឡាយ    រួមសប្បាយស្រីពេស្យា ។

ដើរលេងយប់ហួសយាម ជាប់តាក់តាមស្និទ្ធស្នេហា
ទឹងមនុស្សពោលឫស្យា ចាយបង្ហិនទ្រព្យទាំងឡាយ ៗ
ម៉ែឪមិនស្ងៀមស្ងាត់ តែងកំហាត់ដោយឧបាយ
អំពើល្មើសទាំងឡាយ របស់កូនប្រុសស្រីនោះ ៗ
ដោយជេរវាយប្រាំផាក់ គំហកដាក់យ៉ាងទ្រគោះ
ពោលពាក្យមិនពិរោះ ដាក់ទណ្ឌកម្មឥតប្រណី ៗ
កាត់កាល់លែងរាប់រក លែងឲ្យជ្រករួមមេត្រី
លែងឲ្យទំចំណី បាយទឹកធីដូចរាល់ថ្ងៃ ៗ
ប្រសិនទឹងទាំងក្លា យ៉ាងនេះណាទៅកាល័យ
ក្នុងចិត្តគិតរាល់ថ្ងៃ អាណិតកូន កាត់មិនដាច់ ៗ
តែងតែហៅរាប់រក ឲ្យចូលមករួមជាសាច់
ចិត្តម្តាយកាត់មិនដាច់ ដូចកាត់សាច់របស់ឯង ៗ
ម៉ែឪមានគុណធ្ងន់ ចិត្តពោរពេនធន់ពាក្យស្នែង
ដែលកូនពោលឥតក្រែង យ៉ាងគំរោះគំរើយបាន ៗ
នេះគឺព្រហ្មវិហារ ប្អូនប្រការក្នុងសន្តាន
ទើបអាចអត់ធន់បាន ពាក្យកូនប្រុសស្រីទាំងឡាយ ៗ
កូនណាវាយប្រាំផាក់ គំហកដាក់ឪពុកម្តាយ
កូននោះទឹងអន្តរាយ កាយរងទុក្ខឥតបំឃាត ៗ

រីអង្គព្រះចេស្ដា ព្រះបិតាឯករាជ្យជាតិ
ទ្រង់ខំប្រឹងខ្មីឃ្មាត កសាងជាតិគ្មានឈប់ឈរ ។
ព្រះទ័យត្រជាក់សាយ ទ្រង់ផ្សព្វផ្សាយដោយស្មោះសរ
នូវព្រហ្មវិហារធម៌ ដល់កូនចៅស្មើៗគ្នា ។
មិនថាគហបតី រាស្ត្រមន្ត្រីជវង្សា
ព្រះទ័យសុទ្ធស្នេហា គ្រប់ទាំងអស់ជាសាកល ។
ទ្រង់ខិតខំខ្វល់ខ្វាយ មិនដិនណាយព្រះកាយពល
វិស្សមកសុភមង្គល ប្រទានដល់គ្រប់កូនចៅ ។
កាលមុនឆ្នាំហាសិប រាស្ត្រប្រុសស្រីសោយសោកសៅ
រងទុក្ខក្ដុកក្ដៅ ដោយបរទេសជាន់ញាំញី ។
សម្ដេចត្រេចលីលា ចាកភាកពជធានី
ហោះផ្លោះលើគិរី ទៅប្រទេសមហាអំណាច ។
ព្រះអង្គទ្រង់ប្រឆាំង ទឹងបារាំងយ៉ាងអង់អាច
តាមតារយកអំណាច ឯករាជ្យជាតិកម្ពុជា ។
មិនបានដូចបំណង ទ្រង់ហោះឆ្វងចូលសេមា
បង្កើតនូវ ផែនការ· ព្រះសីហនុ ល្បីខ្ចាយខ្ចរ ។
រាស្ត្រខ្មែរប្រាំលាននាក់ មានចិត្តស្ម័គ្រស្មើស្មោះសរ
ក្រោកឈរច្រើនកុះករ តារអំណាចមកគ្រប់គ្រា ។

ប្រជារាស្ត្រជាតិយើង　　កាន់កាំភ្លើងឈើសង្ហា
វែកស្បូនព្យូហ៍យាត្រា　　ចូលតវ៉ាយ៉ាងក្លាហាន ៗ
ចាំងឃើញជាក់ច្បាស់　　ភិតភ័យណាស់ញាក់ញ័រប្រាណ
ចុះចាកពីគ្រឹះស្ថាន　　ចូលបង្គំសុំជីវិត ៗ
ថ្វាយខ្លួនថ្វាយអំណាច　　ញ៉ិបខ្ញុបខ្មាចព្រះទ្រង់ឫទ្ធិ
ក្នុងថ្ងៃប្រាំបួនពិត　　វិច្ឆិកា ឆ្នាំហាបី (១) ៗ
ដោយគ្មានញាំងដំណក់　　ឈាមឲ្យស្រក់លើផែនដី
នៃជាតិខ្មែរប្រុសស្រី　　មួយដំណក់គ្មានសោះណា ៗ
　　គ្រប់ស្តេចប្រមុខរដ្ឋ　　បានសន្ទត់ប្រាកដថា
ព្រះសីហនុសក្តា　　អង្គទេព្តាបារមីថ្កើង ៗ
ដោះជាតិពីទុក្ខព្រួយ　　លើកជាតិស្ទួយទ្រតម្កើង
បានខ្ពស់មុខមាត់ឡើង　　ដោយព្រះបញ្ញាបារមី ៗ
　　យៀកមិញពេញព្រឹក្សា　　ប៉ងប្រាថ្នាចូលវាតទី
ជិះជាន់ប្អូនញុំាញី　　យកទឹកដីរបស់ខ្មែរ ៗ
នៅខែត្របាត់ដំបង　　សត្រូវប៉ងទីងបង្វែរ
ផែនដីរបស់ខ្មែរ　　បញ្ចូលទៅប្រទេសវា ៗ
ព្រះបិតាសន្តិភាព　　ចេញបង្ក្រាបខ្មាំងពាលា

---

១) ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ។

ដឹកនាំស្ត្រប្រជា    ប្រតិបត្តិការសាមគ្គី ។
ដោយមានលោកមេទ័ព    តាមហែជាប់ព្រះចក្រ
លោកឧត្តមសេនីយ    លន់ ណុល ល្បីថ្វីដៃខ្វង ។
សម្តេចព្រះបិតា    ទ្រង់យាត្រាគ្រប់កន្លែង
ជិតឆ្ងាយប្រឹងស្វះស្វែង    រកសន្តិភាពជូនជាតិខ្មែរ ។
យាងមុខគង់ខេមរៈ    កុម្មុនិស្ត៍គ្រស្មោះមិនបែរ
នារីជីវពលខ្មែរ    ហែតាន់តាប់ក្រោយព្រះអង្គ ។
យាងដោយព្រះបាទា    កងអគ្គាមិនបង្អង់
សំដៅឆ្ពោះទៅត្រង់    ទល់មុខខ្មាំងតាំងតក ។
ទ្រង់យាងចូលទន្ទ្រាន    លុករុករានក្នុងព្រៃក្បា
ឆ្លងព្រែកព្រៃព្រឹក្សា    ហាលភ្លៀងខ្យល់កំដៅថ្ងៃ ។
ព្រះទ័យក្រដាក់សាយ    មិនដឹងណាយព្រះកាយថ្ងៃ
ស្វះស្វែងតាំងយប់ថ្ងៃ    ការពារជាតិបានសុខសាន្ត ។
បារមីសម្តេចឪ    ខ្មាំងសត្រូវតាំងប៉ុន្មាន
មិនអាចទប់ទល់បាន    រត់ប្រាសប្រាណបន់ជូនតា ។
ក្រចេះនឹងស្ទឹងត្រែង    យួនប្រឹងប្រែងប៉ងត្រួតត្រា
មិនខ្លាចរិទ្ធិចេស្តា    ព្រះបិតាទ្រង់បារមី ។
ក៏ទ្រង់ខំប្រឹងឆ្លៀត    យាងទៅទៀតក៏ត្រូវប្រិមប្រិយ

កំចាត់ខ្មាំងតិរិយ    ចេញពីដីកម្ពុជា ៗ
សត្រូវចេញអស់ហើយ    ខ្មែរបានស្បើយចាកវេទនា
ត្រេកក្សាន្តបានគ្រប់គ្នា    រន្ទឺល្បីពេញលោកា ៗ
មិនតែប៉ុណ្ណោះឯង    ទ្រង់ប្រឹងប្រែងខំតក់
នាំដែនកម្ពុជា    ចូលក្នុង អ ស ប ជាតិ (១) ៗ
ជាវង្សអព្យាក្រិត    ប្រាកដពិតឥតវាត
ថ្លឹងស្មើមិនឲ្យឃ្លាត    កាន់ជាប់ស្អិតបញ្ចសីលា ៗ
ចងស្ពានរួមមេត្រី    លោកសេរីឫទ្ធិក្តា
និងលោកកុម្មុយនិស្តណា    ឫទ្ធិក្តាអស្ចារ្យក្រៃ ៗ
អព្យាក្រឹតខ្មែរល្អ    ស្អាតបវរឥតកាឡៃ
មហាយក្សអបអរក្រៃ    សើចចញ្ចព្រះចក្រី ៗ
គេជះអព្យាក្រិត    វង្វាយ·ជិតឫទ្ធិល្បី
ចូលមករួមមេត្រី    តាំងទូតនៅជាសុខសាន្ត ៗ
ប្រទេសនៅជិតខាង    ធ្វើក្អេងក្អាងឫកសាមាន្យ
មិនខ្លាចអំណាចចក្រាន្ត    អព្យាក្រិតរបស់ខ្មែរ
លើកទ័ពតាំងបំពាន    លុករុកកននៅក្បែរ ៗ

១) អ ស ប: អង្គការសហប្រជាជាតិ (ONU); organisation des nations unies)

ជាយដែនរបស់ខ្មែរ ដែលជារដ្ឋជាប់ល្បីនាម ៗ
សម្តេចប្រាជ្ញអង់អាច មិនស្លុតខ្លាចមេសង្គ្រាម
ដែលកាន់ព្យាយាម ការសង្គ្រាមក្នុងលោកា ៗ
ទ្រង់ចេញតប្រឆាំង ដោយកម្លាំងព្រះបញ្ញា
ព្រះឪស្ដព្រះបិតា ហាកាលណាសង្គ្រាមស្ងប់ ៗ
បរទេសនៅជិតខាង ដែលក្អេងក្អាងកល់ថ្ងៃយប់
ចុះញ៉មដាក់មុខជ្រប់ ធ្វើមុខជូរឈ្លោកមើលង ៗ
សម្តេចព្រះអគ្គៈ មហាវីរៈទ្រង់បារមី
ដឹកនាំរាស្ត្រប្រុសស្រី នូវមន្ត្រីគ្រប់ដំណែង ៗ
នឹងអ្នកនយោបាយ កបប្រាជ្ញប្រាយយ៉ាងខែងវែង
ចូលស្ទួយជួយចាត់ចែង លើកតំកើងកម្ពុជា ៗ
ពួកដែក្នុងសង្គម រាស្ត្រនិយមរួមសាមគ្គា
តែមួយជួយគ្រប់គ្នា អុំនាក់តាមតម្រាយ ៗ
ហើយទ្រង់ប្រៀនប្រដៅ នាំកូនចៅឲ្យចំណាយ
កម្លាំងចិត្តនឹងកាយ ធ្វើនូវការហត្ថកម្ម ៗ
ព្រះអង្គទ្រង់ជាគ្រូ ធ្វើគំរូពេលរដ្ឋតាំ
ក្នុងការហត្ថកម្ម ដាំដើមឈើធ្វើសាលា ៗ
ជីកស្រះអណ្តូងទឹក រាស្ត្រងូតផឹកតាមចិន្តា

សែនដីជាក់សាលា ធ្វើសួនផ្កាច្បារប៉ារ ៗ
លើកថ្នាំគមនាគមន៍ ព័ទ្ធកុដិឃុំដោយស្មោះសារ
ភ្លឺស្រែខ្វះគ្រោគអរ ផ្ដើលឈ្មួចជួយលើកគ្នា ៗ
ជីកស្រះប្រឡាយទឹក ខ្វះសទ្ធកម្មសាមគ្គា
មន្ត្រីក្រសួងប្រជា គ្រប់ ៗ គ្នាខំប្រឹងប្រែង ៗ
ដោយការហាត្ថកម្ម ផលដំណាំគ្រប់កន្លែង
បញ្ចេញផលជាក់ស្ដែង គ្រប់កន្លែងស្រែចំការ ៗ
អ្នកក្រទៅជាមាន ទ្រព្យធនធានមានខ្លឹមសារ
បរិភោគសុខអាហារ ឆ្ងាញ់ពិសារពេលរាត្រី ៗ
មានឡានមានគង់ជិះ យានជំនិះស៊ីវិល័យ
សប្បាយកាយចិត្តក្រៃ ស្មាព្រះហស្តព្រះបិតា ៗ
បើមានក្រសួងប្រុសស្រី គហបតីមន្ត្រីណា
កាន់ខ្ជិលកិរិយា ទុច្ចរិតកុងសង្គម ៗ
ប្រកាន់បក្សស្តាំ ឆ្វេង រិលរើផ្វើងតាមពួកក្រុម
ឃាតកាកច្បាប់សង្គម ក្រសួងនិយមអព្យាក្រិត ៗ
សម្ដេចទ្រង់ប្រដៅ នូវកូនចៅនោះពិត ៗ
ឲ្យប្រែគំនិត ដំលាមកទាំងប្រុសស្រី ៗ
ព្រះទ័យសែនត្រជាក់ ទឹកព្រះកត្រូញញឹមប្រិយ

រក្សាសីលប្រក្រតី　　ខ្វះប្រុសស្រីស្និទ្ធស្នេហា ។
និងរកព្រះមហាក្សត្រ　　បារមីក្តាត់ថ្កើងចេស្តា
ឬប្រមុខរដ្ឋណា　　ស្មើព្រះអង្គគ្មានសោះឡើយ ។
ប្រទេសបានសុខសាន្ត　　ខ្វះគ្រប់ប្រាណបានហើយ
ទុក្ខព្រួយគ្មានសោះឡើយ　　ស្នាព្រះហស្តមហាក្សត្រក្សាន្ត ។
សម្តេចមានគុណធ្ងន់　　ធ្ងន់លើសលន់ពន់ប្រមាណ
មិនអាចប្រៀបផ្ទឹមបាន　　គឺគុណធ្ងន់លើសមាតា ។
ព្រះគុណធ្ងន់សែនធ្ងន់　　ធ្ងន់លើសលន់ឥតឧបមា
ពលរដ្ឋជាតិខេមរា　　តែងគោរពព្រះចក្រី ។
ប្រសិនមានកូន-ចៅ　　ណាចិត្តខ្មៅពាលអប្រិយ
គោងកាចអន្យតីរ្ថិយ　　ហ៊ានប្រមាថព្រះចេស្តា ។
បង្កើតអសន្តិសុខ　　ក្នុងភូមិស្រុកនៃអាត្មា
កូនចៅនោះឈ្មោះថា　　អកតញ្ញូអាក្រក់ក្រៃ ។
រមែងតែងវិនាស　　ហ៊ានប្រាក់មាសមានតម្លៃ
រងទុក្ខវេទនាក្រៃ　　រាល់យប់ថ្ងៃឥតស្រាកស្រាន្ត ។

## បទកាកគតិ

### មាតាបិតា

គុណធ្ងន់ណាស់ណា　　ធ្ងន់ប្រៀបពុំបាន　　ធ្ងន់លើសទឹកដី

ប្រុសស្រីគ្រប់ប្រាណ   មិនអាចសងបាន   គុណលោកទាំងទ្វី ។

មាសប៉ុនដូងធំ

គរខ្ពស់ស្មើភ្នំ   សុមេរុគិរី   ឬកែវមរកត

ពេជ្ររត្នមណី   ធំប៉ុនគិរី   ថ្លៃពុំស្មើណា ។

បើកូនប្រុសស្រី

ណាមានបារមី   បុទ្ធិចេស្ដា   កំចាត់សត្រូវ

ដល់ខូវបក   លើកស្ទួយមាតា.   បិតាពីរប្រាណ ។

ជាស្ដេចមហាចក្រ

រុងរឿងអនន្ត   ខ្ពង់ខ្ពស់ថ្កើងថ្កាន   កិត្តិនាមល្បីឮ

ទ្វីគ្រប់ឋាន   មនុស្សយក្សគ្រប់ប្រាណ   ខ្ញុំខ្លាចចេស្ដា ។

យ៉ាងនេះក៏ដោយ

ព្រះពុទ្ធមិនឲ្យ   កូននោះឈ្មោះថា   ជាអ្នកតបស្នង

សងគុណមាតា   បិតាស្នេហា   ទាំងពីរនោះបាន ។

សម្ដេចបិតា

ប្រមុខរដ្ឋ   កម្ពុជក្សេមក្សាន្ត   ទ្រង់មានព្រះគុណ

ធ្ងន់ពន់ប្រមាណ   លើខ្មែរគ្រប់ប្រាណ   ក្នុងកម្ពុជា ។

ទុកស្មើមែឪ

ស្ដេចទ្រង់នាំផ្លូវ   ប្រុសស្រីគ្រប់គ្នា   សាងប្រទេសជាតិ

ផុតឃ្លាតវេក   រាស្ត្រខ្មែរគ្រប់គ្នា   បានសុខក្សេមក្សាន្ត ។

បើកូនប្រុសស្រី

ណាពាលតិរ្យ កោងកាចសាមាន្យ អកតញ្ញូ
មូរខូសន្តាន ពិឃាតដល់ប្រាណ មាតាបិតា ។

ឬក្សត្រមន្ត្រី

ណាពាលតិរ្យ ប្រមាថចេស្តា ញុំាងប្រទេសជាតិ
ក្រុមញាតិកា ធ្លាក់ក្នុងផលសា មហាភយន្តរាយ ។

រីកូនប្រុសស្រី

ឬក្សត្រមន្ត្រី នោះនឹងខ្វាត់ខ្វាយ ព្រាត់ប្រាសសោកសៅ
ទុក្ខក្តៅក្រហាយ ស្រែកយំសោកស្តាយ ក្នុងនាលោកិយ ។

លុះស្លាប់បាត់ទៅ

ចាប់កំណើតនៅ នរកអវិចី ទោសទណ្ឌចម្លែក
ធ្ងន់ប្លែកលោកិយ ទុក្ខក្នុងអវិចី ទុក្ខប្រៀបពុំបាន ។

នរកអវិចី

គ្មានតូរ្យតន្ត្រី កំដរកំសាន្ត មានតែសម្រែក
សូរស្រែកគ្រប់ប្រាណ ស្រែកគ្មានស្រាកស្រាន្ត ប្រាណក្តៅខ្លោចផ្សា ។

នរកអវិចី

ឆេះនៅប្រក្រតី រាត្រីទិវា អណ្តាតសន្ធៅ
ឆេះនៅនោះណា ក្តៅឥតឧបមា លើសភ្លើងលោកិយ ។

ពួកនិរយបាល

នៅជានិច្ចកាល ចាំតែក្រញី វាយវែកកាយា
ឥតត្រាប្រណី កាប់ពុះសិរសី បំបែកលលាដ៍ ។

បោះចូលរណ្តៅ

រត់លៀនសំដៅ មិននៅពេក ពួកនិរយបាល
ពុះក្បាលមរណា កើត·ស្លាប់ស្ទុះវារ ក្នុងភ្លើងនោះឯង ។

កើតស្លាប់កើតស្លាប់

លំបាកយ៉ាកយ៉ាប់ នៅជាអង្វែង ទុក្ខធ្ងន់អនេក
ភ្លើងបែកជាផ្សែង ឆេះគ្រប់កន្លែង ជាអចិន្ត្រៃ ។

នរកអវិចី

ទុក្ខជាប្រក្រតី យូរយាពេកក្រៃ អាយុមួយកប្ប
ឥតរាប់ខែថ្ងៃ មានតែឧបមេយ្យ តាមព្រះសម្តែង

រូបពីអវិចី

ជាប្រេតអប្រិយ ធីខ្ពុះឈាមឯង ភ្លើងឆេះអណ្តាត
ក្អែកត្មាតទិនខ្លួន ចំពុះទុងដែង តាមចឹកក្រញី ។

រូបពីប្រេតប្រាណ

ចាប់កំណើតបាន ជាគោក្របី បំរើអ្នកស្រុក
ជាទុក្ខប្រក្រតី ឬមាន់ទាត្រី ស្វាអាំងប្រឡាក់ ។

រូបតិរច្ឆាន

ចាប់កំណើតបាន  ជាមនុស្សគមគាត់  ដំបៅពកយក្ស
ខ្វិនខ្វង់ជើងបាក់  ភ្នែកទាំងពីរខ្វាក់  កក្អិតក្អង់ក្អូង ។

បុគ្គលលីលា

ព្រោះពោសពាធា  អ្នកមានគុណឯង  ប្រមាថមើលងាយ
និយាយចាត់ចែង  ឥតកោតឥតក្រែង  តែងធ្លាក់អវិចី ។

ដូចឧទាហរណ៍

រឿងរ៉ាវយ៉ាងល្អ  នៅក្នុងបាលី  ខ្ញុំជ្រាវរករក
នាំមកស្រដី  កាត់បំព្រួញខ្លី  ស្ដីអភិប្រាយ ។

(នៅមានត)

---

## បំណោទគំនិតទី ៣

កងក្រុមអ្នកបំរើជាតិទាំង ៣៣ នាក់  ខ្ញុំជាអ្នកទី ៣៣ ។ ប្រសិនបើគ្មានខ្ញុំទេ  ភ្នំពេញក្ដី ខេត្របាត់ដំបងក្ដី- កំពង់ចាមក្ដី កំពតក្ដី កំពង់ឆ្នាំងក្ដី កំពង់ធំក្ដី កំពង់ស្ពឺក្ដី ឥងមិនមានទៀយ ។  តើខ្ញុំជាអ្វី?

មិត្តអ្នកអាន ណាររកឃើញមុនគេនឹងពុះផ្សាយសេចក្ដីសរសើរ
ក្នុងទស្សនាវដ្ដីយើង

# វិធុរជាតក (ត)

វិមហាក្សត្រទាំង ៤ ព្រះអង្គ សឹងតែសរសើរសីលអាត្មាឯងទៅ ៗ ថា ប្រសើរលើសគ្នា នូវប្រការអម្បាលនោះហើយ អណ្ដាប់នោះ សម្ដេចឥន្ទ្រាធិរាជ មានព្រះបន្ទូលផណ្ដឹងទៅព្រះបាទធនញ្ជ័យ កោរព្យរាជថា នៃព្រះបាទធនញ្ជ័យ កោរព្យរាជ ក្នុងនគរអ្នក តើមានអ្នកប្រាជ្ញឬទេ ហើយអ្នកថា បើអ្នកប្រាជ្ញមានហើយ យើងនឹងឲ្យទៅអញ្ជើញ អ្នកកាត់សន្ទិះកង្ខានេះឲ្យយើង ថាបើកើតសេចក្ដីវិវាទទាំងអម្បាលនេះ នៅនាត្រៃត្រឹង្សនាយមិញ ឈ្លោះឡាយ អញឯងនឹងស្រោលជ្រើសរើសរកទេវបុត្រឯណា ១ មានប្រាជ្ញា ឲ្យមកកាត់សន្ទិះកង្ខានេះឲ្យយើង ១ សោត ថាបើកើតសេចក្ដីវិវាទទាំងអម្បាលនេះ នៅនាចុងរកានគរពិភពព្រះបាទសុបណ្ណគ្រុឌរាជនាយមិញ ឈ្លោះឡាយ ឯព្រះបាទសុបណ្ណគ្រុឌរាជ ជ្រើសរើសរកបក្សីបក្សាឯណា ១ មានប្រាជ្ញា មកកាត់សន្ទិះកង្ខាឲ្យយើង មួយសោត ថាបើសេចក្ដីវិវាទទាំងអម្បាលនេះ នៅនាពិភពនាគនាយមិញ ឈ្លោះឡាយ ឯព្រះបាទវរុណនាគរាជ នឹងជ្រើសរើសរកនាគីនាគា មច្ចាឯណាមួយមានប្រាជ្ញា មកកាត់សន្ទិះកង្ខានេះឲ្យយើង ៗ ឥឡូវនេះ កើតមានសេចក្ដីវិវាទទាំងអម្បាលនេះ ក្នុងខេត្តខណ្ឌនានគរ ព្រះបាទធនញ្ជ័យកោរព្យរាជ ឯប្របាទធនញ្ជ័យ ត្រូវរកអ្នកប្រាជ្ញឲ្យកាត់សន្ទិះកង្ខា ថានៃ ប្របាទធនញ្ជ័យ កោរព្យរាជ

ឯអ្នកប្រាជ្ញតើមានឬទេ ? អ្នកស្តាប់ពាក្យនេះ ប្របាទធនញ្ជ័យ គោរព្យកជ ឆ្លើយថាមហាកជ នាអ្នកប្រាជ្ញខ្ញុំនោះ ឈ្មោះទៅពិធូរអ្នកប្រាជ្ញ តែង នឹងប្រដៅធម៌អាថ៌ សេចក្តីលោកិយ លោកា ជាភ្នាក់ងារសព្វថ្ងៃនៃខ្ញុំឯង ក៏ទៅអ្នកប្រាជ្ញនោះនឹងបន្ទោបង់នូវសន្ទិះកន្ទានេះឲ្យយើង គួរយើងនឹងទៅ កាន់សំណាក់ទៅពិធូរអ្នកប្រាជ្ញហោង រីមហាក្សត្រទាំង ៣ ព្រះអង្គ នោះ សឹងស្តាប់ហើយ មានព្រះហឫទ័យនោះត្រេកអរសាទរពេកហោង ។ ម៉្លោះ ហើយ មហាក្សត្រទាំង ៤ ព្រះអង្គនោះ នាំគ្នាលីលាចេញទៅអំពីព្រះឧទ្យាន ទៅកាន់ធម្មសភាសាលា ហើយឲ្យទៅអញ្ជើញពោធិសត្វ ។ រីពោធិសត្វ សោត អ្នកស្មៀកស ស្លាយឈៀងស ប្រដាប់ប្រដាអាត្មាស្រេចហើយ អញ្ជើញឲ្យឡើងគង់លើគ្រែទន់ទិព្វ ប្រដាប់ប្រសើរ ហើយមហាក្សត្រ ទាំង ៤ ព្រះអង្គ ធ្វើការប្រស្រ័យសួរទទួលពតិមានសុខ ទុក្ខ ។ សឹងនៅ ស្នានព្ធសមគួរនឹងអាត្មាទីតែ ។ ហើយទើបថា ហៃ ទៅពិធូរអ្នកប្រាជ្ញ យើងកើតមានសន្ទិះកន្ទា ចូរទៅបន្ទោបង់ឲ្យយើងហោង ។ មហាក្សត្រមិន បន្ទូលទេឡើយ សូត្រជាបទគាថា ៖ បុច្ឆាម កត្តារ មនោមបញ្ញ ។ ហៃ ទៅពិធូរអ្នកប្រាជ្ញអើយ ឥឡូវនេះ យើងមានពាក្យជំលោះប្រកែកជជែក នឹងសីលធម៌គ្នា កើតនៅនាយើងទាំង ៤ នេះ ក៏យើងមកដណ្តឹងទៅជា អ្នកប្រាជ្ញ អាចដឹងខុសដឹងគាប់ ដឹងគួរពុំគួរ ទៅសោតមានប្រាជ្ញា ច្រើនឥតអ្នកឯណាមួយ នឹងស្មើបានឡើយ ចូរទៅកាត់សន្ទិះកន្ទា ពាក្យ

វិចិកិច្ឆា កើតមានក្នុងចិត្តយើងនេះ ឲ្យជ្រះស្រឡះឲ្យយើងហោង នាយើងទាំង ៤ នេះសោត ទំនងនឹងរួចអំពីពាក្យសន្ទិះកង្ខា ដោយសារប្រាជ្ញាទៅហោង ៗ អណ្តាប់នោះ ពោធិសត្វស្តាប់បន្ទូលមហាក្សត្រទាំង ៤ ព្រះអង្គហើយ អ្នកឆ្លើយថាបពិត្រមហារាជ ខ្ញុំពុំទាន់ដឹងព្រះបន្ទូលព្រះអង្គឯណា បន្ទូលគាប់ ព្រះអង្គឯណាបន្ទូលមិនគាប់ នាកើតវិវាទ ឈ្មោះប្រកែកជជែកគ្នាទាំងអម្បាលនេះ ហេតុដ្បិតតែអាស្រ័យនឹងសីលព្រះអង្គទទៃ ៗ ហោង ៗ ពោធិសត្វមិនស្រដីទេឡើយ សូត្រជាបទគាថា: យេ បណ្ឌិតា អត្ថទស្សា កវិត្តិ ៗ ថាបពិត្រមហារាជឧត្តមកន្ទុង ក្រៃលែងនៃក្សត្រផងទាំងឡាយអើយ នរអ្នកប្រាជ្ញឯណា ១ មានប្រាជ្ញាឈ្លាសវៃ តែងនឹងយល់សារពើសេចក្តីផងទាំងឡាយសឹងពិចារណា ដោយដំណើរពាក្យតិះដៀល មានសេចក្តីគេប្រាប់នោះហោង ថាបើអ្នកដ៏មានសេចក្តីនោះពុំទាន់សំដែងថ្លែងប្រាប់ដើមសេចក្តីឡើយ រីអ្នកប្រាជ្ញមិនពិចារណាសេចក្តីម្តេចបាន ព្រះអង្គ ៗ រីព្រះបាទពរុណនាគរាជ តើមានយោបល់ដូចម្តេច ព្រះបាទសុបណ្ណគ្រុឌរាជ តើមានព្រះបន្ទូលដូចម្តេច រីសម្តេចព្រះឥន្ទ្រាធិរាជ តើមានព្រះបន្ទូលដូចម្តេច ព្រះបាទធនញ្ជយកោរព្យរាជដ៏ជាម្ចាស់ខ្ញុំនោះ តើមានព្រះបន្ទូលដូចម្តេច? លំដាប់នោះ មហាក្សត្រទាំង ៤ ព្រះអង្គ សឹងសូត្រជាបទព្រះគាថាប្រាប់ទៅ ពោធិសត្វថា: ខន្តិ ហាវេ ភាសតិ ធាតករជា ៗ ព្រះបាទពរុណនាគរាជ ប្រាប់ថា ហៃ:ចៅពិធូរ

អ្នកប្រាជ្ញអើយ អញនេះមានចិត្តអំណត់អត់មិនខឹង នឹងសត្រូវឡើយ ព្រះបាទសុបណ្ណគ្រុឌរាជប្រាប់ថា ហៃលោកពិធូរអ្នកប្រាជ្ញអើយ អញនេះមានចិត្តអំណត់អត់នូវសំរេកតំណាខផង សម្តេចឥន្ទ្រាធិរាជសរសើរប្រាប់ថា ហៃលោកពិធូរអ្នកប្រាជ្ញអើយ អញនេះប្រាសលះបង់នូវបញ្ចកាមគុណ ទើបប្រសើរ ព្រះបាទធនញ្ជយកោរព្យរាជ ប្រាប់ថា លោកពិធូរបាអ្នកប្រាជ្ញអើយ អញនេះប្រឡេះលែងបង់នូវស្រីព្រះស្នំក្រមការបរិវារផង មានកង្វល់អំពល់តិចឡើយ ។ រីពោធិសត្វស្តាប់ ព្រះបន្ទូលព្រះមហាក្សត្រទាំង ៤ ព្រះអង្គ សរសើរដំណើរសីលគ្នាទៃ ៗ សំដែងថ្លែងប្រាប់អម្បាលនោះហើយ ទើបព្រះអង្គពោធិសត្វ អ្នកសូត្រជាបទព្រះគាថា : សព្វានិ ឯតានិ សុភាសិតានិ ។ បពិត្រមហារាជទាំង ៤ ព្រះអង្គអើយ នាព្រះអង្គ មានព្រះបន្ទូលនោះពីរោះ ៗ ពេក នឹងរកព្រះអង្គឯណាមានព្រះបន្ទូលមិនពីរោះដល់តិចនោះគ្មានឡើយ មហារាជអើយ នាគំណើតគុណសីលទាំង ៤ ចំពូកនោះ ថាបើស្ថិតនៅបុគ្គលឯណាហើយ រីបុគ្គលនោះ ប្រសើរក្រៃពេកហោង មហារាជ ខ្ញុំនឹងពុំហ៊ានទូលទេ ទូលថ្វាយនោះក្រែងពុំសព្វព្រះរាជហឫទ័យ ដូច្នេះខ្ញុំនឹងឧបមាថ្វាយវិញ នោះទើបព្រះអង្គសព្វព្រះរាជហឫទ័យក្រៃវិសេសបាន មហារាជ ព្រះអង្គបន្ទូលនេះ គឺសឹងតែចាំសីលនោះស្មើគ្នា ឧបមាដូចជាងធ្វើកង់រទេះ កាលណាបើកាត់ឈើអំពីព្រៃមកហើយ យកមកបាំងកោសរូសចេញស្រេច ស្រាប់គាបបោះ

បញ្ចូលកាប់ពាក់កន្លែងស្រេច សឹងតែឈើទាំងៗ ទឹងគ្នា គគីរ ខ្លុង ធ្នង់ ក្រាប អាចមកក្រឡឹងផងទឹងគ្នានោះ តោះយោបទឹងពាក់ក្បាច់ម្ដេចៗ ក្ដី ឥតមានជម្លោះប្រកែកជជែកទឹងគ្នាដល់គិតទៀយ ឯគគីរទឹងថាអញជាគគីរ ការណ៍អ្វីទឹងទៅរត់ក្រលីង ទឹងខ្លុង ឯធ្នង់ទឹងថាអញជាធ្នង់ ការណ៍អ្វីអញទឹងទៅរត់ក្រឡឹងទឹងក្រាប មហាពជ មិនដែលមានគិតថាដូច្នោះទៀយ សឹងរត់ក្រឡឹងស្មើគ្នា ឯសីលមហាពជ ទាំង ៤ ព្រះអង្គនោះ សឹងស្មើគ្នា ហោង មហាពជអើយ អ្នកឯណាថាបើបានស្ថិតដោយនូវធម៌ទាំង ៤ ជំពូកនេះហើយ រីអ្នកនោះសឹងថាជាប្រសើរសមឧត្តមថ្លៃ ពួជលោកនេះ ហោង ៗ រីមហាក្សត្រទាំង ៤ ព្រះអង្គនោះសោត ស្ដាប់ពាក្យពោធិសត្វ ហើយ មានព្រះរាជហឫទ័យនោះត្រេកអរសាទរទរក្រៃពេក ហើយសរសើរ ចម្លើយឆ្លើយប្រស្នានៃពោធិសត្វសូត្រជាបទព្រះគាថា : ត្វំ នុ សេ ដ្ឋា ត្វមនុត្តរោ សី ៗ ថាហៃហៅពិធូរអ្នកប្រាជ្ញអើយ ទៅប្រសើរអ្វីមាលព្យាយ ទៅចេះធម៌ ទៅដឹងធម៌ ទៅជាអ្នកប្រាជ្ញ អាចកាត់សន្ទិះកង្ខា វិចិកិច្ឆា នៃយើង អ្វីទឹងមានទើសទាល់សល់ជំពាក់ដល់គិតនោះគ្មានទៀយ ឧបមា ដូចជាងអារកុក មានរណារមុតមាំល្អ អារជាចំរៀក មិនឲ្យមាន ស្រៀកគល់មួយចំណិតសក់ទៀយ មហាក្សត្រទាំង៤ព្រះអង្គ សឹងសរសើរពោធិសត្វ នូវប្រការអម្បាលនោះហើយ អណ្ដាប់នោះ សម្ដេចឥន្ទ្រាធិរាជសឹងយកសំពត់ទុកុលទិព្វ មានសាច់នោះស្ដើងដូចផ្សែងភ្លើង ទៀរ

ល្អ ដូចផ្កាកិលបុស្សព្រោសលែងមន្ទិល ខឹងកាត់ថ្លៃពុំបានឡើយ ហើយបូ-
ជាធម៌ទេសនាហោង រីព្រះបាទសុបណ្ណត្រកូជ សឹងយកសុពណ៌មាលា
មាសបូជាពោធិសត្វសូត្រជាបទព្រះគាថា: សុវណ្ណមាលំ សតបត្ត
ជលិំ ថាហៃទៅពិចូរអ្នកប្រាជ្ញអើយ អញត្រេកអរទឹងចម្លើយប្រស្នាទៅ
ហើយអញយកនូវសុពណ៌មាលាមាសដ៏មានគ្រប់កនោះ ១០០ ស្រទាប់
ដ៏មានកេសរនោះរំលេចរចនា ទៅទៅនូវកេនៈនោះមួយពាន់ អញបូជាធម្ម
ទេសនាទៅហោង រីព្រះបាទពរុណនាគកជ យកកែវមនីរត្ន ខឹងកាត់ថ្លៃពុំ
បានឡើយ សឹងមានពន្លឺរស្មី ដូចភ្លើងរុងរឿង បង្កើតគេជះជាគ្រឿងប្រដាប់
សំកប់ព្រះស្សូគ្គនោះ អញយកមកបូជាធម្មទេស្នាទៅហោង ៗ រីព្រះបាទ
ធនញ្ជ័យកោរព្យកជ សឹងយកដំរីសេះរទេះ គ្រប់ បូជាធម្មទេស្នាពោធិ
សត្វសូត្រជាបទព្រះគាថា: គវំ សហស្សំ ឧសភញ្ច ឆាគំ ៗ ហៃ
ទៅពិចូរអ្នកប្រាជ្ញអើយ អាត្មាត្រេកអរ ទឹងចម្លើយទៅហើយ អញយក
គោឧសភកជមួយពាន់ នូវដំរីដ៏ប្រសើរថ្លៃ នូវរទេះទឹមសេះ ១០ នូវស្រុក
ធំ ១៦ បូជាធម្មទេស្នាទៅហោង ៗ វិមហាក្សត្រទាំងបួនព្រះអង្គ បូជា
ធម្មទេស្នាពោធិសត្វស្រេចហើយ លាទៅកាន់ព្រះនគរ អាត្មាទៃ ៗ
ហោង ៗ សីលវិភងគក្ខណ្ឌំ ឆដ្ឋំតិ វិទីងស្រដីព្រះមហាក្សត្រទាំង ៤
វិភពសីលទឹងគ្នានោះ ពោធិសត្វអ្នកកាត់សេចក្តីមិញ ក៏ស្រេចនូវប្រការអំ
បាលនេះហោង ៗ តេសុ ឆាតកដស្ស ករិយា វិមលាទេវី-

ណាម ៗ បពិត្រអើយ នាមហាក្សត្រទាំង ៣ នោះ យើងមិនស្រដីឡើយ យើងនឹងស្រដីតែព្រះបាទពារុណនាគរាជ កាលបើបានទៅដល់ពិភពនាគនាយហើយ ព្រះបាទពារុណនាគរាជនោះ មានព្រះរាជទេវី ១ ព្រះអគ្គទ្រង់ព្រះនាមឈ្មោះនាងវិមលាទេវី នាងរមិលមើលពុំឃើញកែវមណីរត្ន នៅព្រះសូរគ្គព្រះបាទពារុណនាគរាជនោះ ដូច្នោះហើយ បានដណ្ដឹងថា បពិត្រព្រះសម្មតិទេព មហារាជអើយ នាកែវមណីរត្នជាគ្រឿងប្រដាប់សំរាប់ ព្រះសូរគ្គព្រះអគ្គ តើបាត់ទៅឯណា ពុំឃើញហ្ន៎ ? ព្រះបាទពារុណនាគរាជស្ដាប់ហើយ ឆ្លើយថា ហៃនាងវិមលាទេវីអើយ នាកាលអញឡើងទៅកាន់មនុស្សលោកនាយនោះ ក៏អញបានស្ដាប់ធម៌ទេសនា ទៅពិធូរអ្នកប្រាជ្ញ ជាកូននៃបន្ទូព្រាហ្មណ៍នោះ នាងអើយពិរោះសោះសាក្រែពេក នាងអើយអញពុំអាច ដើម្បីទប់ទល់កាត្ថាភាពនោះបានឡើយ អញយកកែវមណីរត្ននោះ បូជាធម៌ទេសនានៃទៅពិធូរអ្នកប្រាជ្ញ នាងអើយមិនប៉ុន្តែអញឡើយ សម្ដេចឥន្ទ្រាធិរាជក៏យកសំពត់ទុកុលទិព្វ បូជាធម៌ទេស្នា ទៅពិធូរអ្នកប្រាជ្ញ ព្រះបាទសុបណ្ណគ្រុឌរាជ យកសុពណ្ណរាជមាលាមាស បូជាធម្មទេស្នាទៅពិធូរអ្នកប្រាជ្ញ ព្រះបាទធនញ្ជ័យកោរព្យរាជ យកគោឧសភរាជមួយពាន់ នឹងដំរីជ័យ នូវរទេះទឹមសេះ ១០ នឹងស្រុកធំ ១៦ បូជាធម៌ ទៅពិធូរអ្នកប្រាជ្ញដែរ ៗ នាងអើយ រីទៅពិធូរអ្នកប្រាជ្ញនោះ ចេះសំដែងធម្មទេស្នាផ្អែមល្ហែមពិរោះសោះសាមហិមា

ក្រៃពេក នាងអើយ រីឯស្តេចក្នុងអំឡុងសកលជម្ពូទ្វីបនោះ តែងចូលចិត្តចង់ស្តាប់ធម្មទេសនា មិនអាចដើម្បីនឹងទៅកាន់ស្ថានលំនៅអាត្មាឯងទីទៃ ៗ ឡើយ បំផុតកលដំរីចុះប្រេង នោះមកចង់ស្តាប់សព្ទពិន ព្រះបាទឧទេនរាជ មិនអាចដើម្បីនឹងទៅកាន់ស្ថានលំនៅកន្លែងអាត្មាទីទៃៗ ឡើយៗ រីនាងវិមលាទេវី ឮពាក្យថា ចៅពិធូរអ្នកប្រាជ្ញចេះសំដែងថ្លែងធម៌ទេសនានោះផ្អែមល្ហែមពីរោះដូច្នោះហើយ នាងគិតក្នុងព្រះរាជហឫទ័យ នៃនាងនឹងចង់ស្តាប់ធម្មទេសនាចៅពិធូរអ្នកប្រាជ្ញនោះ ម៉្លោះហើយនាងថ្វាយបង្គំប្រណម្យទូល ព្រះបាទពារុណនាគរាជ ថាបពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ សូមតានព្រះអង្គឲ្យទៅនាំចៅពិធូរអ្នកប្រាជ្ញនោះមកឲ្យសំដែងធម្មទេសនា ហើយខ្ញុំនឹងស្តាប់បន្តិចហ: ព្រះបាទពារុណនាគរាជស្តាប់ពាក្យនាងវិមលាទេវី ស្រដីដូច្នោះហើយ ព្រះអង្គឆ្លើយតបទៅវិញថា ម្នាលនាងវិមលាទេវី នាងអើយ ឥតអ្នកឯណា ១ ក៏នឹងអាចទៅនាំចៅពិធូរអ្នកប្រាជ្ញនោះមកអំពីកណ្តាលដំនុំអស់ស្តេចមួយរយ ទឹង ១ នោះមកដល់ពិភពនាគនេះបានឡើយ នាងអើយ មានស្តេចមួយរយ ទឹង ១ នូវជាអំឡុង ក្នុងសកលជម្ពូទ្វីប តែងនឹងស្តាប់ធម្មទេសនាកម្រអ្នកឯណាក៏នឹងទៅនាំមកបានឡើយ នាងថា ចៅពិធូរអ្នកប្រាជ្ញនោះ ងាយដោយតាមនាង ៗ ស្រដីម្តេចដូច្នោះ ៗ នាងវិមលាទេវីស្តាប់ព្រះបន្ទូលព្រះបាទពារុណនាគរាជ នូវប្រការអំពាលនោះហើយ ទើបនាងមានយោបល់

ឆ្ងើយល់ក្នុងព្រះរាជហឫទ័យក្សត្រីនាងថា បើអញស្រដីតែពាក្យទទេនោះ មិនបានអេះ ថាបើអញធ្វើជាឈឺ ថាអញចង់ស៊ីថ្លើមចៅពិជូរអ្នកប្រាជ្ញនោះ វិញហើយតើ ស្តេចនឹងលែងទៅយកឲ្យអញបានហះ កាលណាបើនាង គិតទូវប្រការអំបាលនោះហើយ នាងធ្វើជាឈឺធ្ងន់ៗ ពន់ប្រមាណ នាង ចូលទៅក្នុងល្វែងមានសិរីសួស្តី ហើយនាងផ្តាំអស់ស្រីព្រះស្នំផងទាំង-ឡាយថា ម្នាលគ្នាយើងផងទាំងឡាយអើយ ថាបើព្រះមហាក្សត្រ ស្តេចមានព្រះបន្ទូលរកអញ ចូរអ្នកទាំងឡាយថ្វាយបង្គំប្រណម្យទូលឲ្យ បានទ្រង់ជ្រាបថាអញមានជម្ងឺឈឺធ្ងន់ពន់ប្រមាណ នាងផ្តាំអស់ស្រីៗ ព្រះស្នំអំបាលនោះហើយ ទើបនាងចូលទៅផ្ទំ លើគ្រែឡាព្រះបន្ទំបរម-សុខសួស្តីហោង។ រីព្រះបាទពារុណនាគរាជ ទតព្រះនេត្រស្មោះត្រោះទៅមិន យល់នាងវិមលាទេវីមកគង់ ដូចកាលប្រក្រតីឡើយ ទើបស្តេចមានព្រះ រាជឱង្ការដេណ្ដឹងទៅកាន់អស់ស្រីទាំងឡាយ ថាហៃអស់គ្នាយើងទាំង ឡាយអើយ រីនាងវិមលាទេវី តើនាងទៅឯណា ក៏មិនមកគាល់អញដូច ប្រក្រតីសព្វមួយដង អស់ស្រីទាំងឡាយ ក្រាបថ្វាយបង្គំប្រណម្យទូល ថាបពិត្រព្រះសម្មតិទេពមហារាជអើយ ព្រះអង្គមិនជ្រាបសភាពជានាង អផ្សុកទេហះៗ ព្រះអង្គ ស្តេចស្តាប់ហើយឆ្លើយថា អញមិនដឹងឡើយៗ យីព្រះអង្គអើយ នាងមានជម្ងឺ អផ្សុកជាទុក្ខកិចអីព្រះអង្គៗ ព្រះបាទពារុណ នាគរាជ ព្រះអង្គជ្រាបសភាពជានាងវិមលាទេវី អផ្សុកដូច្នោះហើយ

ព្រះអង្គមិនអាចដើម្បីនឹងទប់ទល់ដល់អាត្មាភាពនោះបានឡើយ ស្ដេចលើ
លាចូលទៅក្នុងព្រះរាជមន្ទីរហើយស្ដេចគង់ខាងក្រែក្រឡាបន្ទំ នាងវិមលា
ទេវីហើយ ស្ដេចយកព្រះហស្តថ្វៃមកបោសអង្អែលព្រះសិរសីនាងហើយ
មានព្រះបន្ទូលដណ្ដឹងទៅ សូត្រជាបទព្រះគាថា: បណ្ឌុកាសិយា
សិ ធុត្តលា វិមលេ ។ ហៃនាងវិមលាទេវី ដ៏ជាស្រីមានរូបឧត្តមសម
នូវនរលក្ខណា នាងមានរូបនោះល្អ កម្រមាន ២ នៅនាពិភពនាគនេះ
វិមលានាងមានជម្ងឺឈឺអីហើយនាង នាងឈឺក្បាលឬនាងឈឺផ្ទៃ ឬមួយ
នាងឈឺឥស់សរសៃទាំង ៣០ នាងមិនប្រាប់បង ។ នឹងរកពេទ្យមេមុតឆាប់
ធុត មករកថ្នាំថាំបំបាត់រក្សាដោះបញ្ចេញជម្ងឺអំពីអាត្មានាង វិមលា ហេតុអ្វី
នាងមានរូបនោះស្គាំងស្គមថយកម្លាំង ឡើងទាំងសម្បុរមិនយល់ ដូចអំ
ពីមុន យល់ចំឡែកប្លែកទើងក្នុកបងហ៎ះណ៎ានាង ។ នាងវិមលាទេវីស្ដាប់
ព្រះបន្ទូល ព្រះបាទពរុណនាគរាជ នូវប្រការអម្បាលនោះហើយ ថ្វាយ
បង្គំប្រណម្យទូលទៅមហាក្សត្រសូត្រជាបទព្រះគាថា: ធម្មោ មនុជេ
សុ មាតិធំ ជនិន្ទ ។ បពិត្រព្រះអង្គដ៏ជាស្ដេចធំឧត្តមកន្លងនៃអ្នកផងទាំង
ឡាយអើយ ធម្មតាកើតជាស្រីនៅនាលោកយនេះហើយ រីអ្នកប្រាជ្ញផង
អំពីបូរាណ លោកពោលថា មានចំណង់ស្រី ៣ ប្រការ: ចំណង់មួយ
នោះ ចង់ឲ្យមានប្ដី ចំណង់មួយមានប្ដីហើយ ហាក់តែចិត្តចង់ឲ្យប្ដីនោះ
មានយសខ្ពង់ខ្ពស់ឧត្ដុងឧត្ដមថ្លៃក្រៃលែងអ្នកផងទាំងឡាយ រីចំណង់មួយ

ចង់ឲ្យមានសម្បត្តិទ្រព្យរបស់ឲ្យច្រើន ហើយនឹងប្រដាប់ស្អាងឲ្យថ្កើងរុង
រឿងប្រពៃ រីចំណង់មួយនោះ ក្រៃលែងនឹងចំណង់ស្រី ៣ ប្រការ ជាត
ក្រញ្ញុរ បពិត្រព្រះអង្គដ៏ជាធំឧត្តមក្រៃលែងអ្នកផងទាំងឡាយអើយ រីក្តី
ប្រាថ្នា ចំណង់ខ្ញុំមួយនោះ ក្រៅវិស័យក្រៃលែងនឹងចំណង់ស្រី ៣ ប្រការ
នោះ កាលខ្ញុំចាប់ផ្ដើមមានជម្ងឺឈឺនោះព្រះសាបមាត់ខ្ញុំ រីសាបមាត់គេទាំង
ឡាយ គេចង់ធ្មួរ ព្រះអង្គអើយ រីសាបមាត់ខ្ញុំនេះ ពុំដូចកាលដាល
ជាចង់ធី ឯថ្លើមទៅពីដួរអ្នកប្រាជ្ញវិញ អាចបាននាមកដោយនូវធម៌ ខ្ញុំ
ធីថ្លើមទៅពីដួរអ្នកប្រាជ្ញនោះ ថាបើពុំបាននាំមកដោយនូវធម៌ ឲ្យខ្ញុំធីថ្លើម
ទៅពីដួរអ្នកប្រាជ្ញនោះឡើយ ក៏ខ្ញុំនឹងស្លាប់បង់ចោលព្រះអង្គដ៏ជាតម្លៃងក្រ
ឡានោះ ប្រាកដហោង ។ ឯព្រះបាទពរុណនាគរាជ ស្ដាប់នាងវិមលា
ស្រដីដូច្នោះហើយ ព្រះអង្គលោមនាង សូត្រជាបទព្រះគាថា : ចន្ទំ ខោ
ត្វំ វិមលេ ធោបាឡាយ សិ ។ ថាហៃនាងវិមលាទេវីប្អូនស្រីសម្លាញ់
បងអើយ នាងប្រាថ្នាចង់យល់ព្រះអាទិត្យ ព្រះច័ន្ទ គាពបាន បងនឹង
ប្រែកាឡា និម្មិតកាត្តា ជាព្រះអាទិត្យ ព្រះច័ន្ទ បងនឹងឲ្យនាងយល់
ដូចព្រះអាទិត្យ ព្រះច័ន្ទ កម្រមាន នូវកិកពនាគនេះ ចូរនាងប្រាថ្នាចង់
យល់ខ្យល់អស់គគ្គុងទៅក៏ ក៏បងនឹងត្រកងថមនាងឡើង ឲ្យអស់ស្រី
ព្រះស្នំសៅដៃផងទាំងឡាយ កាន់នូវផ្លិតកន្ទុយសត្វ មកបក់ផ្លាយនាង
ហើយ បងនឹងបង្ហាញនាងថា នាងអើយនេះឯងហៅខ្យល់ឥតអង្គនិមល

ឥឡូវនេះនាងប្រាថ្នាម្ដេចចង់ស៊ីថ្លើមទៅពិធូរអ្នកប្រាជ្ញនោះ នាងអើយតែគួរទៅពិធូរអ្នកប្រាជ្ញនោះមិញ កម្រនឹងបានយល់ហ៊ះចំណង់បើថ្លើមទៅពិធូរអ្នកប្រាជ្ញនោះ មហាកម្រក្រៃក្រណាស់ហោង នាងអើយកម្រអ្នកឯណាមួយ មានអំណាចនឹងអាច ទៅនាំទៅពិធូរអ្នកប្រាជ្ញនោះ បានមកដល់ពិភពនាគនេះឡើយ ។ ឯនាងវិមលាទេវីនោះ ស្ដាប់ព្រះបន្ទូល ព្រះបាទពរុណនាគរាជ នូវប្រការអម្បាលនោះហើយ ក្សត្រីនាងគិតក្នុងចិត្តឯងថា បើអញមិនបានស្ដាប់ធម៌ទេសនានៃទៅពិធូរអ្នកប្រាជ្ញនោះឡើយ សំអញក្ស័យជីវិត ប្រាកដកាលឥឡូវនេះឯងពុំខានឡើយ ។ នាងគិតនូវប្រការអំបាលនោះហើយ នាងប្រែក្រោយឲ្យមហាក្សត្រហើយ នាងយកព្រះសុភគនោះមកគ្របព្រះភ័ក្ត្រ ហើយនាងផ្ទំស្ងៀមទៅហោង ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប. ព.

# ជម្ងឺមីក្រូ - និងជម្ងឺវិទ្យុ

(វិចារណកថា)

លោក ដេង-ជ្រីវ និពន្ធ

មុននឹងដោះស្រាយបញ្ហានេះ គួរគប្បីរកបុព្វហេតុដែលនាំឲ្យមាន « មីក្រូ » និងគោលបំណងធំ ស្តីពីការផ្សាយដំណឹងតាមវិទ្យុ ។

មីក្រូនេះ ជាមធ្យោបាយពង្រីកសំឡេងឲ្យបានឮខ្លាំង ។

សួរថា: ហេតុដូចម្តេចក៏គេត្រូវការឲ្យសំឡេងលាន់ឮខ្លាំងជាងប្រក្រតី?

ឆ្លើយថា: ចំពោះរឿងនេះ គឺបណ្តាលមកពី ទី ១ សំឡេងនោះជាការចាំបាច់ ព្រមទាំងមានប្រយោជន៍ដល់ជនកាន់តែច្រើន ដែលត្រូវការចង់ឮ និងចង់ស្តាប់- ទី ២ សំឡេងនោះឮមិនខ្លាំង មិនច្បាស់នឹងមិនជ្រួតជ្រាបសព្វត្រចៀកនៃអ្នកត្រូវការ ។ អាស្រ័យហេតុនេះ ទើបគេបង្កើតឲ្យមានមីក្រូពង្រីកសំឡេងនេះឡើង ពាក្យខ្មែរសព្វថ្ងៃ ហៅប្រដាប់នេះថា « ឧគ្ឃោសនកណ្ឋ » ។ ពាក្យ « មីក្រូ » ជាភាសាបារាំង ។

ឧទាហរណ៍ ដូចជាមានពិធីឧឡារិកមួយ ហើយមានឥស្សរជន

ជាអាទិ៍គឺសម្តេចឪ ព្រះបិតាឯករាជ្យជាតិ ទ្រង់សព្វព្រះរាជហឫទ័យថ្លែង អ្វីទៅកាន់កូនចៅព្រះអង្គ ព្រោះព្រះរាជតារបស់ព្រះអង្គ មានសារសំខាន់ពន់ពេក ដូចម្ហូបចំណីប្រកបដោយឱជារសដ៏ថ្លៃថ្លា ជនណាក៏ដោយ មិនថាប្រុសឬស្រី មិនថាក្មេងឬចាស់ រមែងពេញចិត្តគ្រប់ជញ្ជក់ចង់ឮចង់ស្ដាប់យ៉ាងក្រៃលែង ៗ ដោយមនុស្សចំនួនច្រើនអនេកត្រូវការចង់ឮ ចង់ស្ដាប់ព្រះរាជតានោះ ហើយដោយសម្ដេចមានព្រះសូរសៀងមិនអាចជ្រួតជ្រាបដល់អ្នកត្រូវការគ្រប់គ្នា ព្រោះសំឡេងមនុស្ស ទោះបីអ្នកនោះមានកម្លាំងពូកែយ៉ាងណា ក៏មិនអាចស្ទុះឮទៅបានឆ្ងាយដូចផ្សាយតាមឧគ្ឃោសនកណ្ឋឡើយ ហេតុនេះហើយ បានជាគេត្រូវតែប្រើឧគ្ឃោសនកណ្ឋ ដើម្បីបំពងនិងពង្រីកសំឡេងឲ្យឮខ្លាំងនិងឆ្ងាយ តម្រូវតាមសេចក្ដីត្រូវការ ។

សួរថា : ចុះបើគ្រាន់តែនិមន្តព្រះសង្ឃបួន.ដប់អង្គមកធ្វើពិធីអ្វីមួយខាងសាសនា នៅក្នុងក្រុមគ្រួសារខ្លួន មានភ្ញៀវយ៉ាងច្រើន ១០០ នាក់ប៉ុណ្ណោះ តើប្រើឧគ្ឃោសនកណ្ឋ ទើងបានផលដូចម្ដេច ? ខ្លាចក្រែងអ្នកស្រុកផ្ទះជិតខាងមិនដឹង មិនឮថាខ្លួនបានធ្វើការកុសលឬ ? ខ្លាចក្រែងភ្ញៀវស្ដាប់ព្រះសង្ឃសូត្រមន្ដឬទេស្នា មិនឮឬ ?

ឆ្លើយថា : ចំពោះសំនួរខាងលើ គឺមានសភាពដូចមិនសូវសម ។ បើតាមការសង្កេត នៅក្នុងភូមិនីមួយ ៗ មុននឹងធ្វើបុណ្យអ្វី ៗ ទំនៀមបង្គាប់សាមីជនឲ្យដើរដកបញ្ញាតិជាដកប ៗ ដូច្នេះបញ្ហាស្ដីពីរឿងថាក្រែងញាតិ

មិនជឿនផង ពុំបានទៅទេ ។ បញ្ហាមួយទៀត ដែលថាក្រែងគៀរស្តាប់ព្រះសង្ឃពុំឮ ក៏ហាក់ដូចជាគ្មានន័យដែរ ព្រោះមនុស្ស ១០០ នាក់ បើតាមការពិសោធន៍ អាចស្តាប់សំឡេងធម៌ព្រះសង្ឃបានច្បាស់ កុំឲ្យតែមានគេក្មេងស្រែកប្រឡែងគ្នាឡូឡាពេក ។ ក្នុងសម័យមុន តើមានមីក្រូណា ក៏គេអាចធ្វើបុណ្យបានដោយស្រួល រហូតដល់បុណ្យសមាធផង ។ បើអីចឹង មនុស្សភាគច្រើននិយមប្រើឧគ្ឃោសនកណ្ឌក្នុងសម័យនេះ ដើម្បីអ្វី? ឬមួយមកពីគេមានប្រាក់ច្រើនចាយមិនអស់ ហើយគេមានសទ្ធាជ្រះថ្លាត្រូវការបូជាម្ចាស់ឧគ្ឃោសនកណ្ឌផង ? បើយោបល់នេះជាការពិត គួរគប្បីអ្នកម្ចាស់បុណ្យ ចែកចាយធនធានខ្លួនដល់ភ្ញៀវផងទើបសម ព្រោះសុទ្ធសឹងជាអ្នកបុណ្យដូចគ្នា ។

រឿងអាពាហ៍ពិពាហ៍ ក៏មានទំនងដូចគ្នានឹងការធ្វើបុណ្យដែរ គឺថាបើមានរៀបការនៅទីណាមួយ ៗ មនុស្សអ្នកជិតខាងគេទទួលទានដំណេកពុំបានឡើយ ។ បើគេរៀបការ ១ យប់ ១ ថ្ងៃ អ្នកជិតខាង ទោះបីគ្មានចិត្តចង់ ក៏តោងតែចូលក្នុងពិធីនេះជាមួយគេអស់ ១ យប់ ១ ថ្ងៃដែរ ។

សួរថា : ចូលជាមួយនឹងគេដូចម្តេច បើខ្លួននៅផ្ទះដដែល ហើយគ្មានការទាក់ទងក្នុងរឿងរៀបមង្គលការសោះ ?

ឆ្លើយថា : ឧគ្ឃោសនកណ្ឌ វាដឹកឲ្យត្រូវតែចូល ។ បើគេខានដេក ១ យប់ ខ្លួនក៏ត្រូវតែខានដេក ១ យប់ដូចគ្នា ។ ការស្រែកច្រៀងកំចាំង

ពិរោះ ទាំងមិនពិរោះ ការស្រែកអំពាវនាវរកសម្ភសមស្លាបព្រា រកជប ស្រា ...សម្រែកអស់នេះ វាមកចូលរុករកគួរពេញតែក្នុងផ្ទះអ្នកដទៃ ដែលជាហេតុឲ្យអ្នកនេះរវល់ជាមួយ រហូតដល់ចប់ ។

សួរថា : ហេតុម្តេច ក៏គេចូលចិត្តយកទុគ្លាសនកណ្ឌ មកប្រើក្នុងពិធីអ្វីមួយជាឯកជនម្ល៉េះ ?

ឆ្លើយថា : វាគ្មានហេតុដ៏ចាំបាច់អ្វីទាំងអស់ទេ នេះគឺជាជម្ងឺធ្ងន់ទេតើ ព្រោះមនុស្សភាគច្រើន ពេញចិត្តនឹងការកោតសរសើរ ទោះបីខ្លួនមិនគួរដល់ការសរសើរក៏ដោយ និយមការហឺហាហឹកហ៊ាក់ ចង់ឲ្យគេឯងដឹងឮថាខ្លួនធ្វើនេះឬធ្វើនោះ ហើយមិនបានពិចារណាឲ្យយល់ច្បាស់ ថាការប្រព្រឹត្តិរបស់ខ្លួនសមហេតុផលឬទេ? រួចគិតស្មានថាការគាប់ប្រសើរណាស់ ដែលមានផ្សាយសំឡេងឲ្យឮខ្លាំង តាមទុគ្លាសនកណ្ឌ ទោះបីសំឡេងនោះៗ មានអត្ថប្រយោជន៍ក្តី មិនមានក្តី គួរក៏ពុំគួរក៏ ធ្វើឲ្យអ្នកជិតខាងរំខានយ៉ាងណាក្តី ក៏សាមីជនមិនបានគិតដល់ម្តង ធ្វើយ៉ាងណាឲ្យតែមានការគុក្កាំងខ្លួរឡូក រំដើបរំជួល ផ្អើលគេនឹងតែប៉ុណ្ណោះ ។

មែនពិត ប្រសិនបើចង់ណាស់ បើពេញចិត្តណាស់ ក៏ធ្វើទៅចុះ តែសូមមេត្តាកុំឲ្យហួសមាត្រា ។

ឯការផ្សាយដំណឹងតាមវិទ្យុជាតិ ក៏មានសភាពប្រហែលគ្នានឹងរឿងខាងលើនេះដែរ ។ ការផ្សាយដំណឹងនេះ ជាការចាំបាច់ មិនមែនជាការ

បន្ទាប់បន្សំទេ ។

សួរថា : ហេតុម្ដេចក៏គេផ្សាយដំណឹងតាមវិទ្យុជាតិ ?

ឆ្លើយថា : ព្រោះជាដំណឹងដែលមានអត្ថប្រយោជន៍ទូទៅដល់សាធារណជន ថែមទាំងសាធារណជនអន្តរជាតិផង មានជាអាទិ៍គឺដំណឹងស្ដីពីនយោបាយក្នុងប្រទេសនិងក្រៅប្រទេស ដំណឹងស្ដីពីការគេសានជាតិរឿងកំសាន្តចិត្ត ដំណឹងស្ដីពីមរណភាពនៃឥស្សរជន ។ល។ បណ្ដាដំណឹងទាំងប៉ុន្មានដែលមានចុះផ្សាយក្នុងវិទ្យុជាតិ មានដំណឹងមួយដែលគួរលើកយកមកពិចារណា គឺដំណឹងមរណភាព ។ ឯដំណឹងដទៃ ខ្ញុំយល់ថាសុទ្ធសឹងជាការគួរគប្បីទាំងអស់ ដែលជាពិកេះចុមិនពិកេះនោះ ជាការៈនៃអ្នកនិពន្ធ ។

សួរថា : ហេតុដូចម្ដេច ក៏យកដំណឹងមរណភាពមកផ្សាយឲ្យសាធារណជនដឹង មិនត្រឹមតែសាធារណជនខ្មែរទេ គឺរហូតដល់សាធារណជនអន្តរជាតិថែមទៀត ។ តាមធ្លាប់ដឹងមក ដំណឹងស្លាប់នេះ (ក្នុងប្រទេសដទៃ ខ្ញុំមិនបានស្គាល់ទំនៀមទម្លាប់គេជាក់ច្បាស់) ក្នុងប្រទេសកម្ពុជា គេមិនសូវចូលចិត្តបន្ស្ដាប់បន្ទាទេ ហេតុអ្វីក៏យកមកផ្សាយ ? ពេលព្រឹក ក្រុមវិទ្យុជាតិមិនអនុញ្ញាតឲ្យផ្សាយដំណឹងមរណភាពទេ ។ មានអ្នកខ្លះទៀតឃើញមនុស្សស្លាប់ មិនកោនទាំងចូលដិតផង ។

ឆ្លើយថា : តាមធម្មតានឹងការពិសោធន៍ គេយកដំណឹងនេះមកផ្សាយតាមវិទ្យុខានមិនបាន ដោយហេតុអ្នកស្លាប់នោះជាឥស្សរជន ជាអាទិ

គឺព្រះមហាក្សត្រ ឬនាម៉ឺនធំទាំងតួង ព្រោះជនទាំងនេះ ខ្លះមានប្រជាប្រិយភាព ខ្លះជាទីគោរព ជាទីស្នេហាសក្ការបូជានៃប្រជាពលរដ្ឋ ខ្លះត្រូវមានការទាក់ទងរវាងកិច្ចការរាជការនានា ។ ពុំនោះសោត ព្រះសង្ឃមានព្រះឋានសមណសក្តិខ្ពង់ខ្ពស់ ឬជាចៅអធិការនិងគ្រូសូត្រដែលមានសិស្សគណច្រើន ។ ទោះបីដំណឹងមរណភាពជាដំណឹងអពមង្គល ក៏ចំពោះជនខាងលើ គប្បីតែផ្សាយឲ្យគេដឹង ព្រោះដើម្បីជាដំណឹងដល់ប្រជាពលរដ្ឋនិងអ្នករាជការនានា ។ ឬដល់សិស្សគណលោកដែលនៅឆ្ងាយ ព្រមទាំងដល់ឧបាសកឧបាសិកាដែលធ្លាប់គោរពបូជាលោក ។

មានដំណឹងមួយទៀតដែលគួរផ្សាយឲ្យសាធារណជនដឹងដែរ គឺមរណភាពនៃមហាចោរ ដែលធ្លាប់តែធ្វើទុក្ខធ្វើបាបដល់អ្នកស្រុកជិតខាង ឬអ្នកស្រុកទូទៅ ។ បើកាលណាដំណឹងនេះផ្សាយទៅ នាំឲ្យមានការឈប់ព្រួយបារម្ភផង នាំឲ្យជនានុជនធូរទ្រូង មានចិត្តសប្បាយរីករាយក្នុងការប្រកបមុខរបរ ដើម្បីជីវភាពធម្មតាផង ។

សួរថា : ចុះជនសាមញ្ញ តើមានប្រយោជន៍អ្វីនឹងយកដំណឹងមរណភាពនៃជននោះ មកផ្សាយតាមវិទ្យុជាតិ ?

ឆ្លើយថា : បើតាមការត្រិះរិះ និងការសង្កេតទៅ ឃើញថាឥតមានផលប្រយោជន៍អ្វីទាល់តែសោះ ព្រោះខ្លួនបុគ្គលម្នាក់ៗ មានប្រជាប្រិយភាពឯណា? មានការទាក់ទងនិងសាធារណជនឯណា ? មានតែបងប្អូន

កូនចៅខ្លួនក្នុងស្រុកប៉ុណ្ណោះទេ ដែលត្រូវការដឹង បើនាំឲ្យខាតប្រយោជន៍ទៅវិញនោះ មានប្រាកដមែន ព្រោះផ្សាយម្តង ៗ ត្រូវបង់ថ្លៃឲ្យក្រុមវិទ្យុជាតិ បើក្រុមវិទ្យុមិនយកថ្លៃ ក៏គួរនឹកដល់ការរិះគន់ពីជនដទៃផង ៗ

ចំពោះរឿងនេះ គួរឲ្យអស់សំណើចពន់ពេកណាស់ ៗ បានជាអស់សំណើច ព្រោះខ្ញុំនឹកដល់រឿងមួយដូចតទៅ ៖

«ដំណាលថា មានលោកគ្រូចៅអធិការមួយអង្គ លោកតែងគោរពវិន័យណាស់ ៗ វិន័យហាមមិនឲ្យព្រះសង្ឃប្រើបាត្រធ្លុះមានទំហំតាំងពីប៉ុនភ្នែកមាន់ឡើងទៅ ។ ព្រះតេជព្រះគុណអង្គនេះ កាលណាឆាន់ចង្ហាន់រួចហើយ លោកតែងលើកបាត្របញ្ចាំងថ្ងៃសំឡឹងខាងក្នុងមើល ក្រែងបាត្រលោកធ្លុះធំហួសកម្រិតដែលវិន័យហាមឃាត់មិនឲ្យប្រើ ៗ ម្ល៉ោះហើយ តែឆាន់រួចលោកនិយមលើកបាត្រសំឡឹងមើលជាដរាប មិនដែលលោះថ្ងៃណា ៗ

ចំណែកព្រះភិក្ខុសង្ឃជាសិស្សគណរបស់លោក ដោយគោរពគ្រូ ឃើញគ្រូធ្វើដូច្នោះ ក៏នាំគ្នាធ្វើតាម គ្មានពិចារណា គ្មានសួរបញ្ជាក់អ្វីសោះ ៗ

ខាងក្រោយដែលព្រះតេជព្រះគុណចៅអធិការនោះសុគតទៅ ព្រះសង្ឃជាសិស្សគណទាំងប៉ុន្មាន នៅតែប្រព្រឹត្តតាមទំនៀមទម្លាប់គ្រូរបស់ខ្លួនតមក កាលណាឆាន់រួច នាំគ្នាលើកបាត្របញ្ចាំងថ្ងៃសំឡឹងមើលជាធម្មតា ទោះបីបាត្រមិនធ្លុះក៏ដោយ ៗ

លោកគ្រូចៅអធិការថ្មី មានព្រះហឫទ័យធ្ងល់ពន់ពេក ចំពោះព្រះសង្ឃក្នុងវត្តនោះ តែងឆាន់រួច តែងនាំគ្នាលើកបាត្របញ្ច្រាំងថ្ងៃ ហើយសំឡឹងមើលទៅក្នុង ។

មាន ១ ថ្ងៃ លោកគ្រូចៅអធិការថ្មី ប្រជុំអស់ភិក្ខុសង្ឃក្នុងអារាម ហើយសួរថា : ដែលអស់លោក កាលណាឆាន់រួច នាំគ្នាលើកបាត្របញ្ច្រាំងថ្ងៃមើល តើអស់លោកធ្វើនេះប្រយោជន៍អ្វី ? ធ្វើតាមលោកណា ? មានវិន័យបង្គាប់ឲ្យធ្វើឬ ?

ព្រះភិក្ខុ ១ អង្គ ដែលមានវោហារគ្រាន់បើឆ្លើយថា : ពានព្រោស ដែលយើងខ្ញុំធ្វើនេះ គឺធ្វើតាមព្រះសពទេតើ ព្រោះព្រះសព កាលលោកគង់ព្រះជន្មនៅឡើយ តែងតែធ្វើយ៉ាងនេះ នៅពេលដែលលោកឆាន់រួច ។

ព្រះតេជព្រះគុណចៅអធិការថ្មី ដោយលោកឆ្លាតវាងវៃ ក៏យល់ភ្លាមថាដែលព្រះសពបានធ្វើនោះ មកពីលោកខ្លាចក្រែងបាត្រលោកធ្លុះធំហួស ដែលវិន័យបានហាមឃាត់ ហើយភិក្ខុសង្ឃដែលធ្វើតាម គឺធ្វើដោយសេចក្ដីងងិត ធ្វើដោយគ្មានការពិចារណា ។ ទើបលោកចៅអធិការ មានពុទ្ធដីកាប្រាប់ហេតុផលស្ដីពីការលើកបាត្រ នៃព្រះសព ឲ្យភិក្ខុសង្ឃទាំងនោះដឹង ។ តាំងពីពេលនោះមក លោកសង្ឃក្នុងវត្ត អៀនខ្លួនក៏ឈប់ប្រព្រឹត្តដូចជាន់មុនទៀត ។

ឧទាហរណ៍នេះ បញ្ជាក់ឲ្យឃើញថា មុននឹងធ្វើអ្វី គួរពិចារណាត្រិះរិះ

សិន គួរពោលសួរឲ្យដឹងថា ដែលគេធ្វើឯបេះបុងចុះ តើដើម្បីប្រយោជន៍អ្វី ? បើមិនបានគិត មិនបានពិចារណា មិនបានពោលសួរទេ ហើយស្រាប់តែធ្វើតាមគេទៅ នឹងបណ្ដាលឲ្យមានលទ្ធផលអាក្រក់ក៏មាន នឹងបណ្ដាលជាកម្មវត្ថុខាងសំណើចនៃជនដទៃក៏មាន ខាងការរិះគន់ក៏មាន ដូចរឿងលោកសង្ឃលើកបាត្រមើលខាងលើនេះឯង ។

ចំពោះជម្ងឺមីក្រូ ដែលសាធារណជននិយមធ្វើ ក្នុងឱកាសពិធីបុណ្យបន្តិចបន្តួច និងក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ការណ៍នេះ បណ្ដាលឲ្យមានលទ្ធផលអាក្រក់ពីរយ៉ាង : ទី ១ ធ្វើឲ្យអ្នកជិតខាងរំខាន ទី ២ នាំបង់ខាតបច្ច័យឥតប្រយោជន៍ ដ្បិតបច្ច័យជាវត្ថុក្រ មិនគួរគប្បីចំណាយដោយមិនសមហេតុសមផលឡើយ ។ ឯការរំខានទៀត ក៏មិនមែនជាល្អ ការណ៍នេះនឹងបង្កើតឲ្យមានបរិយាកាសអាប់អួរ រវាងអ្នកជិតខាង ។

ចំពោះការផ្សាយដំណឹងមរណភាព តាមវិទ្យុជាតិ រឿងនេះនាំឲ្យខាតបង់បច្ច័យឥតផលផង និងនាំឲ្យគេរិះគន់ដល់ការមិនមានវិចារណញ្ញាណយើងផង ព្រោះយើងជាអ្នកសាមញ្ញ ៗ គេមិនដែលស្គាល់ឈ្មោះមុខ ស្នាដៃជាប្រយោជន៍សាធារណៈ ក៏គ្មាន ។

រួមសេចក្ដី: ការនិយមប្រើមីក្រូក្នុងពេលមានបុណ្យ និងពេលរៀបការបន្តិចបន្តួចព្រមទាំងការចុះផ្សាយតាមវិទ្យុជាតិ នូវមរណភាពនៃជនសាមញ្ញទុកជាជម្ងឺមួយក្នុងប្រទេស ដែលគួរតែបំបាត់ កុំឲ្យមានតទៅទើបប្រពៃ ៗ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង-វាត់ របៀបរៀន

(តមក)

---

អគ្ឃាត្ម ន បុំ. អាត្មាដ៏ក្រៃលែង សត្វប្រសើរ ។ – ចេតសិ បុំ. អ្នកចំរើនអគ្ឃាត្មនិ ។– ជ្ញាន ន បុំ. កិរិយាចេះនូវអគ្ឃាត្មនិ – ទត្ត. គុ. ដែលឃើញអគ្ឃាត្មនិ – រតិ បុំ. ជនអ្នកពេញចិត្តចំរើនអគ្ឃាត្មនិ ។

អគ្ឃាត្មោត្តរកាណ្ឌ ន បុំ. កណ្ឌក្រោយនៃ អគ្ឃាត្ម-រាមាយណៈ ។

អគ្ឃាត្មិក គុ. ដែលប្រកបដោយអាត្មនដ៏ក្រៃលែង ។

អគ្ឃាបក បុំ. សាស្ត្រាចារ្យ ។

អគ្ឃាបន ន បុំ. កិរិយារៀន (គម្ពីរវេទ) ។

អគ្ឃាប្យ គុ. ដែលគប្បីរៀន ។

អគ្ឃាយ បុំ ការស្វាធ្យាយ (គម្ពីរវេទ) ពេលស្វាធ្យាយ វគ្គ ។

អគ្ឃារុហ៍ ក្រិ. ឡើងទៅក្រៃលែង សេចឡើង ដំឡើងថ្នាក់ លើកទៅតាំយកទៅ ។

អគ្ឃារោបណ ន បុំ. កិរិយាចង (ខ្សែ) ដំឡើង ។

អគ្ឃាវាហនិក ន បុំ. សម្បត្តិភរិយា (ដែលការហើយនាំពីផ្ទះខ្លួនទៅផ្ទះស្វាមី) ។

អជ្ឈាសិ ក្រ. អង្គុយក្រៃលែង កាន់ដំណែង នៅរួមសុខទុក្ខ គួល (ធ្វើការ) ដើរមើល ។ – អជ្ឈាសិត គុ. ដែលអាស្រ័យនៅ ។ នបុំ. កិរិយាអាស្រ័យនៅ កិរិយាកាន់មុខដំណែង ។

អជ្ឈាសថ នបុំ. អធ្យាស័យ ទីសំណាក់ ។

អជ្ឈាសិតព្វ គុ ដែលគប្បីទទួលបន្ទុក ។

អជ្ឈាសិន គុ. ដែលអង្គុយក្រៃលែង ដែលតាំងនៅ ។

អជ្ឈុរសិ ក្រ. រិ ពូធំទ្រូង ។

អជ្ឈុបិត គុ ដែលនៅ ដែលកាន់កាប់ ។

អជ្ឈុបិតេ ក្រិ. វិ. ពីព្រឹកព្រាង ។

អជ្ឈុឍ គុ. ដែលកើតឡើង ដែលផ្សាយក្លិន ។ ដែលកំណត់ទុក ។ បុំ. កូនមុនការ ។ ឡា ស្រី. ប្រពន្ធដែលមានប្ដីរៀបការម្ដងទៀត ។

អជ្ឈុប្បិ ក្រ. លាត សន្ធឹង ។

អជ្ឈេតព្វ អជ្ឈេតេយ្យ គុ ដែលគប្បីសិក្សា ។

អជ្ឈេធិត គុ. ដែលពន្លក ។

អជ្រៃ គុ ដែលមិនទៀងទាត់ អនិច្ច ។

# រឿងអាប៊ូលហ្វាអ៊ីរ៉ស៍

(ក)

លោក ប៉ាយ-ល្អុត គំណានក្រស្ត

ប្រែរៀបរៀង

នៅពេលក្រោយពីអស់ស្រីស្រើឆ្ការ ដែលអន្ទុយហាបហាយនោះបេញអស់ទៅ ការណ៍នេះពុំមែនអាចកំបាំងទេ នាងកនហ្វាឌនិយាយមកកាន់ខ្ញុំថា ៖

-(ក) .- អើ ! អ្នកប្រុសសំឡាញ់អើយ ! ឥឡូវអ្នកប្រែក្លាយខ្លួនអ្នក ទៅជាបុរសមានចិត្តត្រឹមត្រូវហើយឬនៅ ? ការពិតត្រេះរិះពិចារណា ដណ្ដឹងសួរហើយសួរទៀត ក្នុងខ្លួនអ្នកគេឲ្យឃើញខុសត្រូវក្នុងប៉ុន្មានថ្ងៃក្រោយនេះ តើបានក្រេនរំឭកចិត្តរឹងរូសកំណាចយ៉ាងកំសាកថោកទាបនៃអ្នក ឲ្យងាកត្រឡប់ជាចិត្តសមបំណងខ្ញុំហើយ ឬនៅឡើយទេ ? ។ នាងបន្ទន់សម្លេងនាងយ៉ាងផ្អែមល្ហែមមុត កន្ទុយភ្នែកបោលយ៉ាងត្រជាក់ស្លុតទៅចំភ្នែកខ្ញុំ (អា ) ដែលជាហេតុបណ្ដុះសេចក្ដីហោកស្ដាយអាណិតដល់កក្រស្រស់ញញឹមនេះ ពាល់តែខ្ញុំឃ្មាត់ព្រលឹង ៗ ខ្ញុំដេកដួលគាំងស្មារតី នៅជើងពាដបល្ល័ង្ក . . . នាងស្រីស្មុះប្រញាប់ប្រញាល់មកទ្រលើកខ្ញុំ ។ នៅពេលដែលខ្ញុំភ្ញាក់ខ្លួនបើកភ្នែកវិញ ខ្ញុំឃើញនាងឈ្ងោកមកលើខ្ញុំ ទាំងទឹកមុខនាងសោប់សេល់ខ្លាំង ...

ខ្ញុំអង្វរករសុំអ្នកស្រី កុំភ័យព្រួយបារម្ភណ៍អ្វីនឹងបុរសកំសត់មួយនេះ ៗ នាងបានធ្ងើយមកខ្ញុំវិញ ទទូចៈហើយទទូចទៀត ប្រាសប្រាល់អន្ទះអន្ទែងយ៉ាងខ្លាំងថា ៖

(ក) – ឱ ! ខ្ញុំខុសខ្លួនហើយ ! ខ្ញុំយល់ថាប្រាកដជាមានអ្វីមួយជាទីជាប់ចិត្តអ្នកប្រុសដោយស្នេហា ជាងខ្ញុំហើយមើលទៅ !

(គ·)– ទេ! ទេ! កែវព្រលឹងអើយ ! មានតែប្អូនទទងវង់តែមួយនេះប៉ុណ្ណោះទេ ជាទីពេញចិត្តខ្ញុំលើសអ្វីៗ ទាំងអស់ ៗ តែសូមកែវបណ្ដូលចិត្តបងពិចារណាមើលចុះ ៖ បងបានប្រគល់កាយចិត្តថ្វាយចំពោះព្រះដ៏មានបុណ្យទៅហើយ តើមានអ្វីមួយត្រូវធ្វើខ្លួនបងឲ្យទាបថោកលើសទៅទៀត ប្រសិនបើបងជាមនុស្សខ្សោយដល់ទៅធ្វើកិត្តិយសខ្លួនឲ្យសៅហ្មងដូច្នេះ ?

(ក) – ណ្ហើយ ! កុំនិយាយ ! អ្នកឯងជាមនុស្សចិត្តលាមកអាក្រក់ ! ដោយហេតុអ្នកមិនប្ដូជាកាយចិត្តអ្នកឲ្យខ្ញុំ នេះជាភស្តុតាងបង្ហាញឲ្យឃើញច្បាស់ថា អ្នកឥតស្រឡាញ់ខ្ញុំពាល់តែសោះ ៗ បើដូច្នោះសូមអ្នកអញ្ជើញទៅចុះ ខ្ញុំខ្មាស់ណាស់ ខ្ញុំអង្វរករអ្នកតទៅទៀតពុំរួចទេ ៗ ខ្ញុំអស់ស្នាបស្នង់អ្វីតទៅទៀតហើយ ខ្ញុំត្រូវបោះបង់អ្នកហើយ អ្នកជាមនុស្សអកតញ្ញូ-អសប្បុរស - - - ចាប់ពីថ្ងៃនេះតទៅ អ្នកត្រូវឈប់មកជួបខ្ញុំ ៗ ត្រូវអ្នករង់ចាំស្ដាប់បង្គាប់របស់ខ្ញុំ បន្តិចទៀត អ្នកប្រាប

ហើយ  តើសេចក្តីវិនិច្ឆ័យរបស់ខ្ញុំនោះយ៉ាងណា ? ។

(ក).– និយាយផុតមាត់ភ្លាម  នាងស្រ្តីក៏ដើរចេញមួយរំពេចពីមហាគេហដ្ឋានទាំងចិត្តរំភើបខ្លាំង ដំណើរមានគេទម្លុក ។ ខ្ញុំក៏មានចិត្តរំភើបស្មើនឹងនាងដែរ ។ ក្នុងពេលនោះ ខ្ញុំគិតភ្លាមថា តើអញត្រូវតែតាមប្រកណា ? ធ្វើម៉េចទៅ បើមានគេយាមល្បាតខ្ញុំជុំវិញជានិច្ចដូច្នេះ ។ ខ្ញុំរកតែទៅជំរាបលោក ហារ៉ុបក៏ពុំបានផង ថាខ្ញុំឋិតនៅទីណា ហើយមានអាសន្នដល់ខ្លួនខ្ញុំយ៉ាងណា . . . ។  រាល់ថ្ងៃ  ខ្ញុំរង់ចាំស្តាប់ តើគេកាត់ទោសខ្ញុំយ៉ាងណា . . . រង់ចាំ ៗ ៗ ៗ អស់បីសប្តាហ៍ះពុំឃើញមានលេចឮអ្វីសោះ ។ សេចក្តីវេទនាកាយចិត្តខ្លាំងពេកដូច្នេះនាំឲ្យខ្ញុំកើតទុក្ខខ្លោចផ្សាអត់ទ្រាំស្ទើរពុំបាន ស្លាប់ទៅវិញគាប់ប្រសើរជាង ។

ខ្ញុំ! នៅពេលព្រឹកថ្ងៃមួយ នាកាល ខ្ញុំស្លៀកពាក់រួចភ្លាម ស្រាប់តែខ្ញុំឃើញតាសាតាស៊ីប្រាំ ឬប្រាំមួយនាក់របស់នាងគនហ្សារុ ចូលមកក្នុងបន្ទប់ខ្ញុំ ។ អ្នកទាំងនេះនាំមនុស្សមួយពួកប្រដាប់ដោយសំលៀកបំពាក់ផ្សេងគ្នាពីអ្នកនៅកោះ សេរេនឌីប ។ អ្នកម្នាក់នោះសំណាសំសួនប្រហែលជានាយគេ ឈរសម្លឹងមុខខ្ញុំមួយសន្ទុះ ហើយដើរឈានជំហានមួយ ៗ ក៏បង្គាប់ខ្ញុំឲ្យដើរតាមគាត់ទៅ ដោយប្រើសម្លេងខ្លាំង ៗ ជាបង្គាប់បញ្ជាមធ្យត ឥតត្រូវការស្តាប់ពាក្យសួររបស់ខ្ញុំឡើយ ។ យើងទាំងអស់នាំគ្នាដើរកាត់ប្រាសាទ ។ នាកាលជិតនឹងចេញពីបរិវេណប្រាសាទ

ខ្ញុំសួរទៅអ្នកម្នាក់ថា ៖ ចុះលោកនាំខ្ញុំទៅឯណា ? – ប្រាប់អ្នកពុំបានទេ បន្តិចទៀត អ្នកនឹងដឹងហើយ !

X X X

(ក) ·— ដូច្នេះ ខ្ញុំត្រូវដើរតាមមនុស្សទាំងនោះ រហូតដល់កំពង់ទឹកក៏ចុះសំពៅជាមួយនឹងគេ ។ គេរៀបចំភ្លាមលើកយុថ្កាបើកក្ដោងចេញដំណើរទៅ ។

កាលណាយើងទៅដល់កណ្ដាលសមុទ្រ ចៅកែសំពៅប្រាប់ខ្ញុំថា ពីដើមគាត់ជាពលរដ្ឋនៃព្រះរាជាណាចក្រនាមគូលកុង្គ ហើយថា លោកស្រីកនហ្វាឌបានឲ្យខ្ញុំ(ក) ទៅគាត់ ដើម្បីធ្វើជាទាសា ក្នុងលក្ខខណ្ឌថា គាត់មិនត្រូវអនុញ្ញាតលោះឡើយ ឲ្យខ្ញុំត្រឡប់ទៅបាសរ៉ាវិញ ។

នេះហើយគឺការសងសឹករបស់នាងកនហ្វាឌ ។

ខ្ញុំមានសេចក្ដីក្រៀមក្រំខ្លាំង កាលខ្ញុំនឹកថា ខ្លួនខ្ញុំលែងឃើញមាតុភូមិ លែងឃើញឪពុកខ្ញុំ ។ ក៏ប៉ុន្តែ ខ្ញុំធ្វើខ្លួនខ្ញុំជាទាសាត្រឹមត្រូវ មានសណ្ដាប់ធ្នាប់ល្អ មានភក្ដីភាព ក្នុងការបំរើចៅកែខ្ញុំ ។ ចៅកែនេះជាមនុស្សមានចិត្តល្អ ហើយប្រាជ្ញវាងវៃ ។ ខ្ញុំពុំមែនរវៃតែបាតការឲ្យត្រឹមត្រង់បំផុត តាមបង្គាប់គាត់ប៉ុណ្ណោះទេ ខ្ញុំខំសង្កេតមើល តើចៅកែចង់អ្វី ខ្ញុំបំពេញចិត្តគាត់ភ្លាម ហើយខ្ញុំឃើញថា ចៅកែលោកកាន់តែសប្បាយចិត្តនឹងខ្ញុំឡើង ៗ រៀងរាល់ថ្ងៃ ។

យើងធ្វើដំណើរជុំវិញកោះ សេរេនឌីប ដើម្បីទៅចូលក្នុងឈូង

សមុទ្រ បេងកាល ពីទិសខាងជើង ។ ឈូងសមុទ្រនេះធំជាងគេទាំងអស់ នៅអាស៊ីទ្វីប ហើយក្នុងឈូងសមុទ្រនេះ មានព្រះកជាណាបក្រចំនួនពីរ គឺៈបេងកាល និងគួលក្កុង ។ នៅពេលយើងកាច់ចង្កូតសំពៅចូល ស្រាប់តែមានខ្យល់ព្យុះមួយ បក់បោកមកយ៉ាងខ្លាំងក្លា ជាមហាភ័យតែម្តង ។ យើងចង់ទាញវែតក្តោងយ៉ាងណាក៏ដោយ យើងចង់បញ្ឈៀងតែម យ៉ាងណាក៏ដោយ យើងចង់បើកជាចំណិតគ្រសក់យ៉ាងណាក៏ដោយ ...(ល) ឃើញថាឥតប្រយោជន៍ទាំងអស់ ។ កម្មករសំពៅបញ្ចេញវិជ្ជាសិល្បៈ ចំណេះចន្ទិចចន្តួចអស់ ឃើញអស់ដៃចាញ់ចេះនឹងគស្ហ . . . សំពៅក៏អណ្តែតតាមខ្យល់ទៅ ។ មធ្យោបាយចុងក្រោយបំផុតគឺ ដើម្បីចៀសវាងកុំឲ្យសំពៅលិចលង់ក្នុងមហាសាគរ យើងត្រូវឈប់ចូកបែវធ្វើម្ទ៉ៃទាំងអស់ ហើយបណ្តោយតាមតែរលកមានរលកជកពពារធំ ៗ រលកបណ្តើរកូនដោះក្រមុំផងក៏មាន ពោរពួនបក់បោកយកទៅឯណាក៏តាមយថាកម្មទៅចុះ- . - បេះតែអណ្តែតទៅ ៗ ៗ លុះតែឃើញកោះជ្វានិងកោះស៊ូម៉ាត្រា បែរមកនៅពីខាងត្បូងយើងទៅវិញ គិតពីកន្លែងដើមរបស់យើងមកទីនេះ ប្រហែលចម្ងាយ ៦០០ ល្យើ (ប្រហែល ២.៤០០ គីឡូម៉ែត្រ) ហើយបើគិតត្រឡប់ទៅផ្លូវដែលយើងធ្វើដំណើរនោះវិញ ប្រហែលឆ្ងាយជាងនេះទៅទៀត ឃើញថាយើងបិតនៅទន្ទឹមកោះម៉ូលុក គឺខាងត្បូងកោះ ហ្វីលីពីន (ម៉ានីល) ឯណោះ នៅក្នុងសមុទ្រឆ្ងាយលន្លង់លះឡោចធំពេង

ជាច់សង្វៀន ដែលពួកយើងទាំងអស់គ្នាមិនដែលស្គាល់សោះ ។
ប្រមាណបីយប់បីថ្ងៃ ខ្យល់ក៏បានស្រាកបន្តិច ។ បក់ឲ្យទិសល្អ យើងបើកសំពៅបានស្រួល យើងរីករាយសប្បាយ ៗ តែមិនបានប៉ុន្មាន ស្រាប់តែយើងមានសេចក្តីខកខ្វល់ចិត្ត ដោយយើងបានពើបពះប្រទះរឿងចំឡែកមួយដែលពុំគួរជឿបាន ។

ឯរឿងនេះគឺដូច្នេះ :

យើងបានលើកក្តោងត្រឡប់មករកផ្លូវដើមយើងវិញ ធ្វើដំណើរដេតមកជពរកោះជ្វា គឺយើងមកពីទិសឯកើត គ្រានោះយើងបានឃើញនៅក្បែរយើង នូវមនុស្សប្រុសមួយលែងខ្លួនផ្ទាំង អាក្រាតទទេ តោងបណ្តែតខ្លួននឹងក្តារមួយសន្ទឹក ៗ មនុស្សនោះស្រែកហៅយើងឲ្យជួយ ៗ យើងស្រាយសំប៉ានកូនទូកតូចឲ្យមនុស្សនោះឡើង ស្រង់យកមកលើសំពៅ ៗ ម្ចាស់អើយសេចក្តីមេត្តានេះ នាំឲ្យយើងមានទុក្ខសោកយ៉ាងសំបើម ៗ

មនុស្សនោះចំណាស់ប្រហែលអាយុ ៤០ ឆ្នាំ មានមាឌដងខ្លួនធំខ្ពស់ជាអស្ចារ្យ ក្បាលពព្រើសដាងក្រឡទឹកត្រីបន្តិច សក់ក្រាស់រួញតាក់កណ្តាញ់រុំព័ទ្ធទៅវិញទៅមកដូចជាឈ្មូត ភ្នែកដូចខ្លា ប្រមុះសំប៉ែតប្រហោងត្រហូ ៗ មាត់រាមានគែមម្នាង ៗ ជិតដល់ត្រចៀក ។ កាលណាហាមាត់ម្តង ៗ ឃើញធ្មេញវែង ៗ ស្រួច ៗ ដៃកំរើកញ័រ ៗ ជានិច្ច បាតដៃធំៗ

នៅចុងម្រាមដៃ មានក្រចកវែងខុប ៗ ហើយវែងជាទីបំផុត ទឹកមុខវាជាមនុស្សអសប្បុរសពោរពេញទៅដោយទោសៈ អាចប្រែក្លាយភ្លាម ៗ ឲ្យទុក្ខភ័យដល់យើង ថ្វីបើយើងមានសេចក្តីអាណិតអាសូរដល់វាអំបាញ់មិញនេះ ។ នាកាលបានឈរទល់មុខលោក ឌីហាអូស្ស ចៅកៃយ៉ងភ្លាម មនុស្សនោះមានវាចាថា : សេដ្ឋី អើយ ! ខ្ញុំបានរួចសជីវិតដោយសារលោក កុំតែបានលោក ខ្ញុំស្លាប់បាត់ទៅហើយ ! ។

(ឌ) - ពិតប្រាកដហើយ បើអ្នកគ្មានសំណាងជួបនឹងយើងទេ អ្នកត្រូវលង់លិចស្លាប់ជាខ្មោចហើយ ! ។

មនុស្សនោះឆ្លើយថា : ហ៊ឺ ! ខ្ញុំលង់ទឹកស្លាប់ ! មើលខ្ញុំឲ្យច្បាស់ ខ្ញុំមិនមែនស្លាប់ដោយលង់ទឹកទេ ។ ខ្ញុំចង់នៅកប់ឆ្នាំក្នុងទឹកក៏បាន គ្មានជាការណ៍អ្វីទេ ការណ៍ដែលនាំឲ្យខ្ញុំរមួលខ្លួននេះ គឺខ្ញុំឃ្លានបាយ ខ្ញុំឃ្លានណាស់ ស្ទើររហែករហុយក្រពះទៅហើយ ។ ដប់ពីរម៉ោងទៅហើយ ខ្ញុំឥតបានទទួលទានអាហារសោះ គឺរយៈពេលវែងហួសហេតុទៅហើយ ចំពោះមនុស្សអ្នកស៊ីច្រើនដូចខ្ញុំ ។ ដូច្នេះ តាមតែលោកអភ័យទោសទៅចុះ សូមមេត្តាឲ្យទានខ្ញុំ ដើម្បីលើកកម្លាំង កុំទៅរកចំណីម្ហូបអ្វីល្អនោះ តាមតែស្អី ក៏ខ្ញុំទទួលទានបានដែរ ។

អ្នកទាំងអស់កំពុងឈរមើលស្រឡាំងកាំង លោកឌីហាអូស្សបង្គាប់ឲ្យរៀបម្ហូបអាហារ សម្រាប់ចំនួនមនុស្សប្រាំមួយនាក់បរិភោគហើយ

ឲ្យយកខោអាវមកឲ្យមនុស្សនោះស្លៀកពាក់ផង ។

— ខោអាវ! អរគុណហើយលោក ខ្ញុំជាមនុស្សស្រាតដូច្នេះជា ដរាប !

- ល្អហើយ ! កាលណាអ្នកឯងនៅតែម្នាក់ឯង នោះខ្ញុំឃើញថាប្រពៃ តែនេះ បើអ្នកនៅជាមួយនឹងយើងទាំងអាក្រាតដូច្នេះ ដូចជាពុំសមរម្យ! ននលគគអីចឹងទេ !

អូ ! បន្តិចទៅ ក៏អ្នកឯងសាំងក្នែកទៅហើយ !

សេចក្ដីតបវិញទាំងគីរលដូច្នេះ បញ្ជាក់ឲ្យយើងយល់បានថា មនុស្សនេះមានខួរក្បាលពុំសូវស្រួល ។ ដោយសេចក្ដីស្រេកឃ្លានបេះតែ តឿនមនុស្សនេះអន្ទះអន្ទែងសុំឲ្យរៀបបាយឆាប់ៗ ទន្ទ្រំជើងលើសំពៅ ក្រហឹមទាំងធ្មេញ ក្នែកក្រហាមរលលៀនថ្ងៃ ។ នាកាលម្ហូបអាហារមកដល់ វាតាំងស្ទុះក្លួតទៅពមញាត់ៗ អស់រលីងក្អាម ហើយសុំមេត្តាថែមទៀត ។ លោក ឱហាអូស្ស បង់ដឹងចុះប៉ុន្មានទៅទើបវាឆ្អែត! ក៏បង្គាប់ឲ្យរៀបតុ ដូចមុនទៀត តុទី ២ នេះក៏អស់ធិញក្អាមទៅទៀត ។ យើងស្មានថា ប្រហែលគ្រប់គ្រាន់ហើយ តែខុសស្រឡះ វាសុំយ៉ាងតឹងរឹងឲ្យថែមទៀត ។

(នៅមានត)

# រឿងល្បើកខ្លាហ្លុងតែន

ប្រែពីភាសាបារាំងដោយ លោក ជេង-ជ្រឹវ

(គ)

---

## ៩២) រទេះនឹងសត្វរុយ

មានសេះប្រាំមួយ យ៉ាងមាំ ៗ ទំអូសរទេះមួយឡើងទួល ផ្លូវស្ងួតតែខ្សាច់ដីពិបាក ហើយមានថ្ងៃចាំងមកពីគ្រប់ទិស ៗ

ស្រី ៗ លោកសង្ឃ-ចាស់ ៗ នាំគ្នាចុះអស់ សេះទំប្រឹងបែកញើស ហូរញើសហត់ហុះ ស្ទើរផុតដង្ហើម ៗ រុយមួយហើរមកជិតសេះ មានបំណងនឹងញុំាងសេះឲ្យដើរដោយសូរស្វាបនៃអាត្មា សុះទៅខាំសេះនេះម្តងសេះនោះម្តង ហើយគិតថាវានឹងធ្វើរទេះឲ្យលឿនទៅបាន ជួនហើរទៅទំលើបន្ទោល ជួនហើរទៅទំលើច្រមុះនាយសារថី ៗ

នៅពេលដែលរទេះកម្រើកបរទៅ ហើយដែលវាឃើញមនុស្សទាំងឡាយនាំគ្នាដើរតាម រុយយល់ថាជោគជ័យនេះ ជាស្នាដៃរបស់វាតែម្នាក់ឯង វាហើរទៅហើរមក យ៉ាងរហ័សរហួន ឧបមាដូចជាព្រិទ្ធបាល នៅពេលចម្បាំង សុះទៅចាត់ការគ្រប់កន្លែង បង្ខំឲ្យទាហានសុះចូល ដើម្បីនឹងយកជ័យជំនះបានឆាប់ ៗ

នៅពេលនោះ រុយពោលត្អូញត្អែរថា វាទំធ្វើតែម្នាក់ឯង ថាវាជាអ្នកយកចិត្តទុកដាក់ទាំងអស់ ថាគ្មានអ្នកណាម្នាក់ជួយសេះសោះ គឺថាលោក

សង្ឃគិតតែឆ្ងៀតពេល អានសៀវភៅធម៌ ស្រីគិតតែប្រៀង តើពេលហ្នឹង ឬ ត្រូវគិតពីចម្រៀង ! នាងរុយស្ទុះហើរវិតចុះវិតឡើង នាំឲ្យតែអផ្សុកទៅនឹងត្រចៀកមនុស្សទាំងនោះ ។

ជាអវសាន រទេះក៏បានទៅដល់លើទួល ! ឃើញដូច្នោះ រុយពោលថា៖ ឥឡូវ ត្រូវយើងសំរាកដកដង្ហើមឲ្យស្រួលបន្តិចចុះ ! ខ្ញុំខំប្រឹងខ្លាំងណាស់ តាំងពីយើងទាំងអស់គ្នា នៅឯវាល ផ្លូវបម៉េ៎ះ ដូច្នេះសូមលោកសេះឲ្យថ្លៃឈ្នួលមក ។

ចំពោះរឿងនេះ មានជនជាច្រើន ធ្វើជារហ័សរហួនចូលលាយឡំក្នុងកិច្ចការទាំងឡាយ គឺហាក់ដូចជាខ្លួនជាអ្នកធ្វើការចាំបាច់គ្រប់ទីកន្លែង តែតាមការណ៍ពិត គឺធ្វើឲ្យតែទើសទែងគេគ្រប់ទីកន្លែងវិញសោះ គួរគប្បីតែកំចាត់ចោលចេញ នូវជនបែបនេះ ។

## ៩៣) មច្ចុរាជ និង អ្នកជម្ងឺដកបង្កាមាន់

អ្នកដកបង្កាមាន់ម្នាក់ អាយុជាងមួយរយឆ្នាំហើយ ចេះតែត្អូញត្អែរដាក់មច្ចុរាជថា មច្ចុរាជប្រញាប់មកបង្ខំគេឲ្យទៅឆាប់ម្ល៉េះ រកតែលៃពេលធ្វើលិខិតប្រគល់មរតកស្ទើរមិនទាន់ យ៉ាងហោចណាស់ក៏ត្រូវឲ្យដំណឹងមុនដែរ ។ អ្នកដកបង្កាមាន់នោះពោលថា៖ តើមកបង្ខំគេឲ្យទៅភ្លាមៗ ដូច្នេះ មានយុត្តិធម៌ឬទេ ? ត្រូវមច្ចុរាជឯងបង្អង់បន្តិចសិន ប្រពន្ធខ្ញុំមិនព្រមឲ្យខ្ញុំទៅ ដោយគ្មានគេហៅទៅជាមួយផងឡើយ ហើយខ្ញុំនៅមានចៅ

ម្នាក់ដែលខ្ញុំត្រូវរៀបចំឲ្យវាមានផ្ទះសំបែង មច្ចុរាជត្រូវដឹងថា ខ្ញុំត្រូវនៅកាកពីផ្ទះធំមកទៀត ឲមច្ចុរាជបវរ! អ្នកឯងប្រញាប់អ្វីម៉្លេះ ។

មច្ចុរាជឆ្លើយតបទៅអ្នកជកបង្កាមាន់នោះវិញថា : នែលោកតា ! ខ្ញុំពុំមែនមកពញាក់លោកតាឯណា ។ លោកតាពោលត្អូញត្អែរអំពីការបង្ខំរបស់ខ្ញុំ ដោយឥតសមហេតុ-ផល : ចូរគិតមើល ! លោកតាមិនមែនមានអាយុ ១០០ ឆ្នាំ ហើយទេឬ ? ចូរលោកតាចង្អុលប្រាប់ខ្ញុំនូវមនុស្សពីរនាក់ ដែលមានអាយុចំណាស់លោកតា នៅទីក្រុងប៉ារីស៍ (Paris)[១] ហើយរកមនុស្សចំណាស់បែបនេះទៀត ចំនួន ១០ នាក់ ក្នុងប្រទេសបារាំង តើមានឬទេ ? បើលោកតាប្រាប់មក ខ្ញុំត្រូវជូនយោបល់ខ្លះដល់លោកតា ជាយោបល់ដែលញុំាងឲ្យលោកតាយល់ដូចតទៅ: គឺថាខ្ញុំបានឃើញលិខិតប្រគល់មរតកលោកតាធ្វើរួចហើយ ចៅលោកតាមានគ្រួសារហើយ ផ្ទះលោកតាសង់ស្អាតហើយ ។ រឿងដើរ – កម្រើក – សញ្ញាមនោសញ្ចេតនា ទាំងអស់នេះ ឃ្លាតចេញពីលោកតាហើយ ។ តើហ្នឹងមិនមែនហៅថាគេឲ្យដំណឹងដល់លោកតាទេឬ ? អណ្តាតលែងដឹងរសជាតិ ត្រចៀកស្តាប់អ្វីមិនឮ អ្វីគ្រប់សព្វហាក់ដូចជាស្ងួតស្រពោន ចំពោះលោកតា ហើយកាលវេលាមានសភាពច្រើនហួស ចំពោះលោកតា ។ ស្តាយសម្បត្តិ ដែលឈប់ជាប្រយោជន៍ដល់ខ្លួន ។ ខ្ញុំសូមបង្ហាញចំពោះលោកតា នូវមិត្តភក្តិលោកតាដែលខ្លះស្លាប់ ខ្លះកំពុងជកបង្កា

១– រដ្ឋធានីនៃប្រទេសបារាំង ។

មាន់ ខ្ទះកំពុងឈឺ តើរៀងទាំងនេះ មិនមែនជាការឲ្យដំណឹងទេឬ? ដូច្នេះ សូមលោកតាអញ្ជើញ កុំតក់ធ្វើអ្វី មិនជាប្រយោជន៍អ្វីដល់កជការទេ ដែលលោកតាថា បង្អង់បន្តិច ដើម្បីធ្វើលិខិតប្រគល់មរតកនោះ ។

មច្ចុរាជយល់ត្រូវ ។ ខ្ញុំប្រាថ្នាថា អាយុប៉ុណ្ណោះហើយ គេត្រូវតែថយចេញពីជីវភាព ដូចជាគេថយចេញពីកន្លែងជប់លៀង ដោយថ្លែងអំណរដល់ម្ចាស់ផ្ទះ ហើយគេត្រូវតែរៀបចំបង្វេចរបស់គេ ទុកឲ្យស្រប ព្រោះ តើគេអាចនឹងពន្យារពេលឈប់បានប៉ុន្មាន ក្នុងការធ្វើដំណើរនេះ ?

បពិត្រលោកតា! សូមលោកតា កុំកន្ទក់កន្ទេញ សូមលោកតា ក្រឡេកមើល យុវជនទាំងនោះស្លាប់ សូមលោកតា ក្រឡេកមើលយុវជនទាំងនោះដើរ សូមលោកតា ក្រឡេកមើលយុវជនទាំងនោះតែង្ហោះទៅរកតែសេចក្ដីស្លាប់ ទោះបីសេចក្ដីស្លាប់ប្រកបដោយកិត្តិយស ទោះបីស្លាប់ល្អ ឬស្លាប់អាក្រក់ គឺទៀងពិតជាស្លាប់ហើយ ។ ខ្ញុំបានអំពាវនាវប្រាប់លោកតាច្រើនលើកហើយថា ខ្ញុំមិនមានការបន្ទរបន្ទួយចំពោះមុខឆាវខ្ញុំនេះទេ អ្នកខ្លាចស្លាប់ជាងគេ រមែងស្លាប់ដោយសេចក្ដីស្ដាយច្រើនៗ

---

អ្នកមានចិត្តអាណិត តែងពោលពាក្យជាទីគាប់ចិត្ត អ្នកក្លៀវក្លា តែងមិនពោលអួតខ្លួន អ្នកឲ្យទាន តែងឲ្យទានមិនរើសមុខ អ្នកមានប្រាជ្ញប្រតិភាព តែងមិនកោងកាច ។

— ហិតោបទេស —

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ ។
> យូរ-អ៊ុន

ចូចូក៏ប្រើហែហួអៀននាំទាហាន ២០០០ នាក់ជាកងមុខ ហើយចេញពីបន្ទាយធំទៅមុន មានបំរើសេះស៊ើបដំណឹងត្រឡប់ទៅប្រាប់ហែហួអៀនថា ឥឡូវនេះអៀវហៀមលើកកងទ័ពមកតាំងបន្ទាយ ដែនស្រុកឡាំកេងច្រើនណាស់ ហែហួអៀនឮដូច្នោះ ក៏ឲ្យបោះទ័ពតាំងបន្ទាយនៅទីនោះ អៀវហៀមដឹងថា ហែហួអៀនលើកកងទ័ពហ្លួងចូលមកតាំងបន្ទាយនៅដូច្នោះ ក៏ប្រើឈៀងគីលើកទាហានចេញទៅខឹងច្បាំងតយុទ្ធគ្នានឹងហែហួអៀន ៗ ឃើញដូច្នោះ ក៏លើកទាហានចេញទៅត្រៀមចាំនៅមុខបន្ទាយ ហើយបរសេះចូលទៅប្រយុទ្ធគ្នានឹងឈៀងគីបាន ៣ ក្បួន ហែហួអៀនក៏យកដាវកាប់ត្រូវឈៀងគីដាច់ពាក់កណ្តាលខ្លួន ជាពីរកំណាត់ស្លាប់ ។

អៀវហៀមឃើញឈៀងគីស្លាប់ក៏ខឹងណាស់ លោតឡើងសេះចេញទៅតស៊ូនឹងហែហ៊ួអៀនបាន ៣០ ក្បួន នៅមិនទាន់ចាញ់ឈ្នះ ហែ-ហួអៀនធ្វើជាញាក់សេះថយតែទៅក្រោយ អៀវហៀមមិនដឹងកលក៏

ដេញបណ្តោយតាមទៅ ហែហ្វូងអៀនញាក់សេះត្រឡប់មក គាប់ត្រូវអៀវហៀមធ្លាក់ពីលើសេះស្លាប់ ទាហានទាំងពួងក៏បាក់បែកខ្ចាត់ខ្ចាយអស់ទៅ ។

មានបំរើសេះទៅប្រាប់ចូចូថា ហែហ្វូងអៀនមានជ័យជំនះហើយ ចូចូក៏មានចិត្តសោមនស្សណាស់ ទើបលើកទ័ពហ្លួងកន្ទុងចូលទៅតាំងបន្ទាយនៅជិតស្រុកហាន់តុង ទៀវឡូដឹងដូច្នោះ ក៏ប្រឹក្សានឹងទាហានទាំងពួងថា អៀវហៀមក៏ដល់នូវសេចក្តីស្លាប់ទៅហើយ ឥឡូវចូចូក៏លើកទ័ពហ្លួងកន្ទុងចូលមកជិតស្រុកយើងណាស់ អ្នកទាំងអស់គ្នានឹងជួយរិះគិតប្រការម្តេច ? :ង៉ៀមផោថា ម៉ាឈៀវនោះប្រែចិត្តចេញពីលោកហើយ នៅតែបាំងតេក ព្រោះឈឺទៅផងមិនបាន ឯបាំងតេកនោះមានចូដៃខ្លាំងពូកែណាស់ទាំងចិត្តក៏សុចរិតពិតត្រង់ ខ្ញុំបាទបានឮសំដីនិយាយសរសើរគុណលោកថា កាលម៉ាឈៀវគាំបែកពី ចូចូមកទីពឹងបុណ្យលោកនៅទីនោះ បាំងតេកក៏បានសេចក្តីសុខ ដោយសារគិតតែធ្វើការតបស្នងសងគុណលោកមិនដាច់ពីមាត់ បើដូច្នេះ គួរតែលោកឲ្យហៅខ្លួនបាំងតេកមកប្រើការឲ្យលើកពលយោធា ចេញទៅតនឹងចូចូទើបបាន ។

ទៀវឡូបានឮដូច្នោះ ក៏មានចិត្តសោមនស្សណាស់ ឲ្យបំរើទៅហៅបាំងតេកមកឲ្យបំណាច់រង្វាន់ជាច្រើន ហើយថា យើងត្រូវឲ្យអ្នកចេញទៅច្បាំងនឹងទាហានចូចូបានទេ ? ។ បាំងតេកឆ្លើយថា ខ្ញុំបាទនឹងសុំធ្វើការតបស្នងសងគុណលោកត្រាតែអស់ជីវិតចុះ ។ វេលានោះ ទៀវឡូ

កំបាត់ទាហានឲ្យប៉ាំងតេក ១ ម៉ឺន ។ ប៉ាំងតេកក៏លាទៀវឡូនាំទាហានចេញទៅ លុះទៅដល់ប្រទល់ទ័ពគ្នា ក៏ឲ្យតាំងបន្ទាយជាមាំមួន ហើយប៉ាំងតេកក៏ឡើងសេះនាំទាហានទៅដល់មុខបន្ទាយចូឆូ ហើយស្រែកចំអកបញ្ឈឺចិត្តឲ្យចូឆូជាពាក្យអាស្រូវភាសាផ្សេង ៗ ។ ចូឆូបានឮដូច្នោះក៏សួរទាហានថា ទាហានទៀវឡូនេះឈ្មោះអ្វី ? ។ មានទាហានម្នាក់ស្គាល់ច្បាស់ប្រាប់ថា ឈ្មោះប៉ាំងតេក ។

ចូឆូឮដូច្នោះ ក៏នឹករលឹកឡើងបានថា ប៉ាំងតេកនេះមានថ្វីដៃខ្លាំងពូកែណាស់ គឺជាទាហានម៉ាឈៀវ កាលគ្រាច្បាំងគ្នានៅដំបន់ស្វឹងអ៊ុយហោ ដែលមកនៅនឹងទៀវឡូនេះ ព្រោះសេចក្ដីប្រចាំចិត្ត ឯម៉ាឈៀវក៏រត់ចូលទៅនៅនឹងឡៅពីឯស្រុកសែឈួនទៅហើយ យើងត្រូវរិះគិតយកខ្លួនប៉ាំងតេកមកទុកធ្វើការជាមួយផង ថាហើយក៏បង្គាប់ទាហានតាំងពួងថា ប៉ាំងតេកនោះមានកម្លាំងនឹងថ្វីដៃខ្លាំងពូកែណាស់ បើអ្នកកាល់គ្នានឹងចេញទៅច្បាំងនោះទោះបីប៉ាំងតេកនោះនឹងចាញ់ប្រៀបយ៉ាងណា ក៏កុំធ្វើអន្តរាយឲ្យដល់ក្ស័យជីវិតឡើយ ចូរប្រយ័ត្នគិតតដៃឲ្យល្មមតែប៉ាំងតេកថយកម្លាំងចុះ ហើយនឹងកេទបាយចាប់ខ្លួនឲ្យបានទាំងរស់ នាំមកឲ្យយើងឲ្យបាន ។

ទៀវខាប់ទទួលប្រសាសន៍ហើយ ក៏ឡើងសេះចេញទៅច្បាំងនឹងប៉ាំងតេកបាន ៤ ក្បួន ទៀវខាប់ក៏ថយរត់ចូលបន្ទាយ ហែហ៊ូអៀនក៏បរសេះចូលច្បាំងនឹងប៉ាំងតេកបាន ៧ ក្បួន ហែហ៊ូអៀនក៏ថយសេះរត់ត្រឡប់មក

ក្រោយវិញ  ស៊ុឡុងក៏បរសេះចូលប្រយុទ្ធនឹងប៉ាំងតេកបាន ១០ ក្បួន ស៊ុឡុងក៏ធ្វើជាថយរត់ចូលទៅក្នុងបន្ទាយវិញ  ទៅធូក៏បរសេះកាំដាវចេញទៅច្បាំងនឹងប៉ាំងតេកបាន ៥០ ក្បួន  ទៅធូក៏ញាក់សេះថយត្រឡប់មកវិញៗ ប៉ាំងតេកបានជ័យជំនះអស់ពួកទាហានបួនទាំង ៤ នាយ  ហើយក៏នាំទាហានចូលទៅក្នុងបន្ទាយវិញ ។

ឯនាយទាហានបួនទាំង៤នាក់ក៏នាំគ្នាស្មើថា  ប៉ាំងតេកនោះចំណានក្នុងការសង្គ្រាមណាស់ ។ បួនធូក៏មានសេចក្ដីត្រេកអរ  ទើបប្រឹក្សាប្រាថ្នានឹងចង់ដឹងគំនិតនាយទាហានទាំង ៤ នាក់នោះ  នឹងគិតប្រការម្ដេច ទើបនឹងយកខ្លួនប៉ាំងតេកឲ្យមកនៅនឹងយើងបាន ។ ការសៀងឆ្លើយថា ខ្ញុំបានដឹងថា  ទៀវឡនោះមានទីប្រឹក្សាម្នាក់ឈ្មោះអៀវស៊ុន  ឯអៀវស៊ុននោះជាមនុស្សលោភទ្រព្យសម្បត្តិណាស់  ប្រាថ្នាតែនឹងរកទ្រព្យយកមកទុកជាប្រយោជន៍ខ្លួន  សុំឲ្យលោកគិតតាក់តែងរករបស់ទ្រព្យឲ្យនាំយកទៅឲ្យអៀវស៊ុនឲ្យអៀវស៊ុនគិតញុះញង់ទៀវឡថា  ប៉ាំងតេកនោះមិនមានចិត្តនឹងគិតច្បាំងទេ  គិតតែនឹងប្រែចិត្តក្បត់ពីទៀវឡ ។ ក៏គង់នឹងមានសេចក្ដីសង្ស័យនឹងប៉ាំងតេក  រួចសឹមលោកគិតតទៅ  គង់នឹងបានខ្លួនប៉ាំងតេកដោយងាយ ។

បួនធូថាអ្នកគិតដូច្នេះ  ត្រូវណាស់  តែយើងនឹងឲ្យនរណានាំរបស់ទាំងនោះ ចូលទៅឲ្យអៀវស៊ុនក្នុងស្រុកហាន់តុងនោះបាន? ។  ការសៀង

ថាពេលព្រឹកស្អែក បើឃើញប៉ាំងតេកចេញមកច្បាំង ឲ្យលោកធ្វើជាបោល បន្ទាយរត់ចេញទៅ ប៉ាំងតេកក៏គង់នឹងចូលទៅក្នុងបន្ទាយនោះ ហើយលោកត្រូវរកមនុស្សណាដែលចេះនិយាយស៊ីម៉ាំមួន ឲ្យយកមាសប្រាក់មកផែជាផែនបន្ទុះឲ្យបំរើលាក់ទុកក្នុងដៃអាវ ហើយបង្គាប់ថា បើទាហានប៉ាំងតេកបែកត្រឡប់ចូលទៅក្នុងស្រុកវិញ ក៏ឲ្យបំរើនោះបន្ទំចូលទៅជាមួយនឹងបានយករបស់ទាំងនោះទៅឲ្យអៀវស៊ុង ដល់ពេលយប់កាលណាសឹមលោកលើកទាហានចូលទៅប្លន់បន្ទាយ ប៉ាំងតេកក៏គង់នឹងបែកធ្លាយរត់ចូលទៅក្នុងស្រុកវិញ ។ ចូទួយល់ឃើញត្រូវផង ក៏ចាត់ទាហានដែលមានប្រាជ្ញាម្នាក់ឲ្យធ្វើតាមពាក្យកាសៀង ហើយឲ្យស៊ីឡុងនឹងទៅធូជាកងបញ្ចោត ឲ្យទៀវទាប់នឹងហៃហួអៀនលើកទាហានទៅពួនបង្កប់នៅសងខាងផ្លូវ ។ នាយទាហានទាំង ៤ នាក់ ក៏ធ្វើតាមពាក្យចូទួបង្គាប់គ្រប់ប្រការ ។

ឯប៉ាំងតេកនោះ លុះឃើញទៅធូនឹងស៊ីឡុងលើកទាហានចូលទៅ ក៏នាំទាហានចូលប្រយុទ្ធគ្នានឹងទៅធូ ស៊ីឡុងក្នុងកណ្តាលទ័ព ។ ស៊ីឡុងនឹងទៅធូក៏ធ្វើជាថយត្រឡប់ទៅវិញមិនបានចូលបន្ទាយ ។ ប៉ាំងតេកក៏លើកពលពារទំលាយតាមទៅដល់មុខបន្ទាយចូទួ ។ ក៏នាំទាហានរត់ចេញពីបន្ទាយ ប៉ាំងតេកក៏លើកទាហានចូលទៅក្នុងបន្ទាយ រើសបានគ្រឿងសស្ត្រាវុធ នឹងស្បៀងអាហារជាច្រើនណាស់ ប៉ាំងតេកមានចិត្តកំរើប

ឲ្យតាំងគុះត្រៀមទុក លុះពេលកណ្ដាលយប់ក៏នាំទាហានទាំងពួងស៊ីផឹកនៅក្នុងបន្ទាយទ្រហឹងអឺងកង ។

ឯស៊ុយឡុងនិងនៅផ្លូក៏នាំទាហានចូលពីខាងទិសឯជើង ហែហ្វូអៀននាំទាហានចូលពីទិសឯកើត ទៀវខាប់នាំទាហានចូលពីទិសឯលិច ជា ៣ បែក ទុកតែទិសឯត្បូងបើកចំហ ព្រោះជាផ្លូវនឹងចូលទៅឯស្រុកហាន់តុង ។ លុះបានឮស្គរផាវជាសំគាល់កាលណា ក៏នាំគ្នាដុតបន្ទាយឲ្យឆេះឡើងជា ៣ អន្លើ ហើយចរពលចូលលុកក្នុងបន្ទាយនោះ ។

ខណៈនោះ ប៉ាំងតេកតទល់ពុំឈ្នះ ក៏នាំទាហានរត់ចេញទៅតាមទ្វារទិសឯត្បូង ចូលទៅក្នុងស្រុកហាន់តុងវិញ ទាហានចូឆោម្នាក់ដែលចាំនៅក្នុងបន្ទាយនោះ ក៏ចូលទៅតាមដល់ស្រុកហាន់តុងផង លុះទៅដល់ហើយ ក៏ទៅរកអៀវស៊ុនយកគ្រឿងមាសប្រាក់នោះទៅជូន ហើយជំរាបថា ត្បិតចូឆោជាទីវ៉ុយកុងជំនិតជំណឹងថា លោកមានគម្រោងប្រាជ្ញាជាទីអស្ចារ្យស្រឡាញ់គ្នានឹងទៀវឡូ សុំឲ្យលោកស្មោះសរជួយរិះគិតញុះញង់ឲ្យទៀវឡូមានសេចក្ដីសង្ស័យនឹងប៉ាំងតេក ឯផ្លូវមេត្រីរបស់លោកនឹងវ៉ុយកុងនោះ គង់នឹងមានតទៅមុខទៀត ។

អៀវស៊ុនឃើញមាសនឹងប្រាក់ក៏មានចិត្តសោមនស្សត្រេកអរពេកប្រមាណណាស់ ប្រាប់មកទាហាននោះថា អ្នកឯងវិលទៅប្រាប់ចូឆោការដែលប្រាថ្នាមកទាំងប៉ុន្មាន យើងនឹងជួយរិះគិតឲ្យបានដូចចិត្តទាំងអស់

ទាហាននោះគឺលាទៅប្រាប់ចូឆ្នូគ្រប់ប្រការ ចូឆ្នូដឹងដូច្នោះក៏អរណាស់ ។

ឯអៀវស៊ុងក៏ចូលទៅញុះញង់ទៀវឡេថា ប៉ាំងគេកនោះចេញទៅ

វាយបន្ទាយចូឆ្នូបានរបស់ទ្រព្យច្រើនណាស់ លុះនឹងទំនៅចំប្រាំងនឹងចូ-

ឆ្នូគេទៅ ខ្លាចក្រែងលោកដឹងការណ៍ថាបានរបស់ទ្រព្យទុក ប៉ាំងគេកក្លែង

ធ្វើជាពោលបន្ទាយបែកព្វាយរត់ត្រឡប់មកវិញ ប្រាថ្នាតែនឹងយករបស់

នោះមិញ មកលាក់ទុកជាប្រយោជន៍ខ្លួន ។

ខណៈនោះ ទទួលប៉ាំងគេកចូលទៅគំនាប់ទៀវឡេ ហើយពណ៌នា

សេចក្ដីដែលបានទៅធ្វើការបែករត់មកឲ្យទៀវឡេស្ដាប់គ្រប់ប្រការ ។ ទៀវ

ឡេបានឮហើយ ក៏ពិគ្រោះមើលឃើញសមប្រកបនឹងពាក្យអៀវស៊ុង

និយាយ ក៏មានសេចក្ដីខឹងខ្លាំងណាស់ បង្គាប់ទាហានឲ្យយកខ្លួនប៉ាំង

គេកទៅសម្លាប់ចេញ ងៀមផៅចូលទៅអង្វរសូមទោស ទៀវឡេក៏

និយាយនឹងប៉ាំងគេកថា យើងព្រមលើកទោសខ្លួនតាមងៀមផៅសុំម្ដងចុះ

តែពេលព្រឹកស្អែកនេះ ត្រូវនាំទាហានចេញទៅចំប្រាំងទៀត បើគ្មាន

ជ័យជំនះ លះបង់បន្ទាយរត់ចូលមកដូចម្ដងនេះ យើងនឹងឲ្យកាត់ក្បាលខ្លួន

ចេញជាប្រាកដ ។ ប៉ាំងគេកស្ដាប់ហើយក៏មានសេចក្ដីត្រេកអរណាស់

ទទួលបង្គាប់ទៀវឡេ ហើយលាថយចេញទៅចាត់ចែងទាហានត្រៀម

បម្រុងការ ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

## អារម្ភកថា

ស្រាវជ្រាវដោយ លោក ឌុ·តាម

---

ព្រះរាជនិពន្ធរាមកេរ្តិ៍នេះ ជាឈ្មោះសៀវភៅមួយដែលខ្ញុំបានឃើញ នៅលើក្របសៀវភៅដែលព្រះគ្រូវិជ្ជាធរ ព្រះនាមឌៅ អ្នកប្រែរៀបរៀង ។ លោកប្រែតាំងពីថ្ងៃអាទិត្យ ១០ កើតខែអស្សុជ ឆ្នាំកុរ បញ្ចស័ក ត្រូវនឹងថ្ងៃទី ២០ តុលា ឆ្នាំ ១៩២៣ ចប់នៅថ្ងៃពុធខែមាឃ ៤ កើត ឆ្នាំជូតឆស័ក ព.ស. ២៤៦៧ ត្រូវនឹងថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩២៥ ។

ព្រះគ្រូវិជ្ជាធរព្រះនាម ឌៅ សុគតនៅវត្តកុណ្ឌាលោម ។ លោកបានប្រែរៀបរៀងរឿងរាមកេរ្តិ៍រួចហើយ លោករក្សាទុកដោយមិនដែលឲ្យនរណាខ្ចីចម្លងឬអាន ព្រោះលោកខ្លាចបាត់របស់លោក ។ ពេលដែលលោកមានព្រះជន្មនៅឡើយ ចិត្តខ្ញុំចង់អានចង់ចម្លងរឿងរាមកេរ្តិ៍នេះជាពន់ពេក តែមិនដឹងជាធ្វើដូចម្ដេចនឹងយកអានបាន ។ ចិត្តរបស់ខ្ញុំនៅតែប៉ងចង់បានរាមកេរ្តិ៍នេះយកមកផ្សាយឲ្យជនទូទៅបានជ្រាបផង ។ មិនត្រឹមតែខ្ញុំសុំអានទេ គ្រាន់តែខ្ញុំសុំលោកមើលឲ្យឃើញច្បាស់នូវកងសៀវភៅ ក៏លោកមិនបើកខ្ចីឲ្យមើលដែរ ព្រោះលោកខ្លាចបាត់ខ្លាចខូច ។ នេះសរឲ្យឃើញថា លោកទុកដាក់គង់វង់របស់លោកមែន ។

ចុះហេតុអ្វីបានជាពេលនេះ ព្រះរាជនិពន្ធកមកេរ្តិ៍ត្រូវបានយកមកបោះពុម្ពផ្សាយវិញ ?

ព្រះវិជ្ជាធរ អនិច្ចធម្មទៅ សៀវភៅនេះនៅក្នុងការគ្រប់គ្រងរបស់ភិក្ខុ សរ-មាង ។ តែសូមជ្រាបថា ពេលដែលអត់ពីព្រះគ្រូអង្គនេះ សៀវភៅកមកេរ្តិ៍របាត់របាយទៅកន្លែងនេះខ្លះ កន្លែងនោះខ្លះ ដល់ខ្ញុំមកពីសហរដ្ឋអាមេរិកវិញ ខ្ញុំទៅសុំពីភិក្ខុ សរ-មាង យកមកទុកជាសម្បត្តិផ្ទាល់ខ្លួន ។ ព្រះភិក្ខុអង្គនេះជាអ្នកស្រឡាញ់អក្សរសាស្ត្រ លោកយល់ច្បាស់នូវដំរៃនៃអក្សរសាស្ត្រ លោកក៏ឲ្យមកខ្ញុំ ។ ភាគដែលបាត់ទៅខ្លះ ខ្ញុំទៅតាមរកយកមកបានគ្រប់ភាគវិញ ។

រចៀបសរសេរ

សៀវភៅនេះ សរសេរលើក្រដាសស៊ើង ដែលយើងហៅថាក្រដាសចិន ហើយខ្ទង់ម្រាក្សណ៍ក្រឡបទ្យើងចំនួន ១០៧ ខ្សែ ។ ដល់មកសម័យក្រដាសសម្បូណ៌ លោកព្យាយាមចម្លងទុកក្នុងសៀវភៅធំស្រួលអាន តែលោកចម្លងបានតែ ១ សៀវភៅ លោកក៏ទទួលអនិច្ច-ធម្មទៅ ។

ព្រះរាជនិពន្ធកមកេរ្តិ៍នេះ លោកសរសេរជាពីរបែបគឺ៖

១ – ពាក្យកាយ

តាមខ្ញុំសង្កេតមើលពាក្យនៅក្នុងរឿងនេះ ខ្ញុំតែងជួបប្រទះដូចសំដី

នៅក្នុងរឿងកាមកេរ្តិ៍ដែលបោះនៅពុទ្ធសាសនបណ្ឌិត្យ ហើយមានពាក្យខ្លះមិនមាននៅក្នុងវចនានុក្រមខ្មែរយើងផង តែខ្ញុំបានយកវចនានុក្រមសំស្ក្រឹតមកពិនិត្យមើលទៅ ឃើញថាមានឈ្មោះ យក្ស ឬ បក្ស នោះ ៗ មែន ទើបខ្ញុំកត់ទុកដាក់ទៅក្នុងបទានុក្រម ៗ នៅមានពាក្យខ្លះទៀតច្រើនតែពាក្យដែលមាននៅសិលាចារឹកខ្មែរយើងសម័យអង្គរ ៗ

## ២ – ពាក្យកាព្យ

សំដីនៅក្នុងកាមកេរ្តិ៍នេះ មានខ្លះសរសេរជាកាព្យ ខ្លះសរសេរពាយដូចខាងលើ តែទុកជាសរសេរពាយ ក៏នៅតែជួនរណ្តំគ្នាដែរ ៗ ខ្ញុំសូមជូនប្រយោគកាព្យខ្លះគឺ :

រីកដងិតទរឿងកាមកេរ្តិ៍ រិះរកាមរឿងគុំពិសយ៍
មិនជាខ្លឹមសារព្រះត្រៃទ័យ កុំទុកព្រះទ័យជាទីតាំង ៗ
បើស្តាប់ឲ្យធាប់ក្រឡាប់ចិត្ត ចូរគិតអនិច្ចាពីអនិច្ចំ
សញ្ញាវិញ្ញាណមានសញ្ញ គ្រប់ទាំងស្រីប្រុសមានវិជ្ជា ។

ដោយខ្ញុំយល់ឃើញថាកាមកេរ្តិ៍ដែលបោះផ្សាយពីពុទ្ធសាសនបណ្ឌិត្យមិនគ្រប់គ្រាន់ ខ្ញុំក៏យករឿងនេះមកចុះក្នុងកម្ពុជសុរិយាម្តង ៗ ដូច្នេះខ្ញុំអនុញ្ញាតឲ្យចុះក្នុងកម្ពុជសុរិយា តែមួយលើកទេ ហើយរក្សាសិទ្ធិមិនឲ្យចម្លងចេញទៅបោះពុម្ពឬគូរឡើយ ។

# ព្រះរាជនិពន្ធរាមកេរ្តិ៍

## តាមការស្រាវជ្រាវរបស់ ឧ.តាម

(រក្សាសិទ្ធិមិនឲ្យចម្លង មិនឲ្យថតរូបឡើយ)

---

## ភាគ ១

ព្រះរាជនិពន្ធរាមកេរ្តិ៍ខ្សែរ ១ និយាយតាំងតែពីហិរណយក្ស មូរផែនដី លុះទៅព្រះបាទអនោមាទត្ត ប្រគល់រាជសម្បត្តិឲ្យព្រះបាទអជ្ឈបាល ដល់ទៅអសុរព្រហ្មឡើងទៅសូមពរពីព្រះឥសូរ លុះដល់ទៅត្រីបូរាមឡើងទៅចំអ ចំអន់ឲ្យស្រីសួគ៌ ។

*ទីនេះសំដែងពីហិរណយក្សទៅសូមពរពីព្រះឥសូរគាត់ពិធីបានខ្លាំងពូកែ ព្រះឥន្ទព្រះព្រហ្មស្ថានសួគ៌ ១៦ ជាន់ក៏ក្រែងខ្លាចអំណាចបារមីមិនមានអ្នកណាហ៊ានតថ្វី រួចគាត់មូរផែនដី ទ្វីបឧត្តរកោ អមរគោយានទី ក៏បានស្រេចហើយ វាមូរក្បៀតនាំយកផែនដីទៅបាតាល ។*

*កាលនោះពួកទេវតា គ្រប់ស្ថានភ័យរំជួល នាំគ្នាចុះមក លុះដល់ស្ថានគិរីកៃលាសថ្វាយបង្គំទូលព្រះឥសូរថា ហិរណយក្សវាញាំញីស្ថានទាំង ១៦ ជាន់លើក្រោម ហើយមិនតែប៉ុណ្ណោះវាមូរទាំងផែនដី ឥឡូវនេះ វានាំចុះយកទៅបាតាល ទេវបុត្រទេវតាមារព្រហ្មនឹងអន្តរាយស្លាប់វិនាសអស់ហើយ ។ សូមទ្រង់ព្រះករុណាជួយជីវិត អ្នកទាំងអស់ផង គ្រានោះព្រះឥសូរបានស្ដាប់ហើយ ទ្រង់ខ្ញាល់ ហើយមានបន្ទូលថា អាហិរណយក្សនេះ វាមិនកាន់ពាក្យសត្យដូចបណ្ដាំអញ នឹងទុកវាពុំបាន ក៏ទ្រង់ប្រើព្រះនារាយណ៍ឲ្យទៅបំផ្លាញអសុរហិរណយក្ស សម្លាប់បង់ទៅ ។*

កាលនោះព្រះនាគយណ៍ ទទួលព្រះឱង្ការហើយ ថ្វាយបង្គំហោះចុះទៅបាតាល លុះដល់ ទើបឃើញហិរណយក្សសំដែងឫទ្ធិគៀរផែនដីទាំង ៣ ហើយព្រះនាគយណ៍ក៏និម្មិតខ្លួនទៅជាជ្រូកស ចង្កូមពេជ្រដេញខ្វេះអសុរ កាលនោះ ហិរណយក្សឃើញជ្រូករត់ជម្រង់ចូលមក អសុរក៏ទ្រង់ក្រេវក្រោធណាស់ ភ្នែកឡើងក្រហមដូចភ្លើង ទន្ទ្រំដើងលាន់ឮទាំងត្រៃយចក្រ ព្រោះមិនដឹងជាព្រះនាគយណ៍ អសុរក៏ចូលដេញវាយជ្រូក កាលនោះជ្រូកព្រះនាគយណ៍ ក៏ចូលប្រយុទ្ធជាញជ័យ ទ្រង់ខ្វេះដើងដៃខ្លួនអសុរដួលជាប់ជាតិ បីកំណាត់ស្លាប់ទៅ ។ សម្លាប់ស្រេច ជ្រូកព្រះនាគយណ៍ក៏យកផែនដីមកលាទុកដូចដែលវិញ ។ ហើយទ្រង់ប្រែកាឡាជាព្រះនាគយណ៍វិញ កាន់ដំបងពេជ្រហោះឆ្ពោះទៅលើមេឃ ហើយដល់សមុទ្រក៏ទ្រង់ចុះមកគង់នៅឆ្នេរសមុទ្រជាកណ្ដាលជាធំទូលាយ ក៏ចូលទ្រង់បទ្ទំតាំងពិធីលើបល្ល័ង្កនាគព្រួតចឹកកាយបរិកម្មតាមពិធីការហើយ ក៏បង្កើតផ្ទះផ្កាឈូកពីផ្ចិតព្រះអង្គ តមកកើតជាកុមារប្រុសមួយឈ្មោះ នៅកុងដួងបទុម ហើយព្រះនាគយណ៍ក៏ទ្រង់ត្រេកអរណាស់ បេះយកកុមារពោះយកមក លុះដល់ ទើបចូលទៅគាល់ព្រះឥស្វរ យកកុមារថ្វាយហើយទូលពីការសម្លាប់ហិរណយក្ស សត្រូវគ្រប់តាមដំណើរហើយ ។ ព្រះឥស្វរឃើញកុមារនោះ ក៏ទ្រង់មានព្រះទ័យនោះត្រេកអរ ហើយទើបមានព្រះបន្ទូលថាអាហិរណយក្សវាស្លាប់ទៅ ត្រៃយលោកក៏បានសុខសប្បាយ

ស្មោះសរ ឯអង្គកុមារនេះក៏ពូជពង្សវង្សព្រះនារាយណ៍ ទឹងកើតជាដើម ពង្សក្រសត្រ ប្រសើរលើសលោកក្នុងជម្ពូទ្វីបជាធំក្រៃលែង ទឹងបាន រំលត់ទុក្ខចង្ក្រាបក្នុងលោកានៃត្រតាភពហោង ៗ ត្រាសហើយទើបមាន ទេវទុង្ការបង្គាប់ទៅព្រះឥន្ទ្រា ឲ្យចុះទៅកសាងព្រះនគរក្នុងទំជម្ពូទ្វីប ឲ្យ ទុត្តមវុង្សរឿងមង្គលសួស្តីពិជ័យជានី កាលនោះព្រះឥន្ទ្រាក៏ក្រាបថ្វាយបង្គំ ទទួលព្រះទុង្ការព្រះឥសូរ ហើយហោះត្រឡប់មក កាន់ស្ថានពិមានវិញ ក៏គន់លើបល្ល័ង្កកែវ ទ្រង់បង្គាប់ព្រះមាតុលីឲ្យកេណ្ឌហ្វូនទេពទេវាឲ្យនាំ គ្នាចុះទៅ ៗ សាងជានី ៗ កាលនោះព្រះមាតុ.បីថ្វាយបង្គំហើយដោយ ត្រេកអរថយមក ទើបចាត់ពួកទេវតាជាបរិវារសុទ្ធតែមានប្រាជ្ញាក្លៀវក្លា ហាន ពួកមួយកាន់ទង់មយូរនាំមុខ ពួកមួយកាន់ទង់ពណ៌ស៊ុមរូបកេសរ រាជសីហ ពួកមួយកាន់ទង់រូបមករពណ៌ខៀវ ពួកមួយកាន់ផ្កាបទុម ៣ ហែហាមអមស្តេចដំរីឰរាវ៉ណព្រមគ្នារង់ចាំស្តេចទឹងចរលីលា ៗ កាលនោះ អង្គសម្តេចមាយរាឡទេវរាជស្តេចចុះស្រង់ព្រះគង្គាជំរះអង្គ នាងទេពកញ្ញា នៅចាំបំរើស្រង់ស្រេចទើបស្តេចមកគង់លើ ឰរាវ៉ណពេជ្រយន្តរថដំរី ហើយហោះចុះមកដល់ជម្ពូទ្វីប ក៏ទ្រង់ត្រឡេកគ្រប់ទិសានុទិសទៅទើប ឃើញទិសបូណ៌កូម៌ក៏នពសុធាជាល្អត្រឹមត្រូវ មានមហាឥសី ៤ អង្គទ្រង់ ព្រឹទ្ធបរិកម្មចំរើនឈាន ក៏ទ្រង់បញ្ឈប់ពួកទេវបរិវារក៏ទ្រង់ចុះពីឰរាវ៉ណ ក៏ចូលទៅកាន់ព្រះមហាឥសី ក៏ថ្វាយបង្គំនមស្ការ ហើយទ្រង់សួរថា

ព្រះមហាឥសីដែលព្រះអង្គមកសាងព្រឹទ្ធនៅក្នុងព្រៃនេះ មកបានប៉ុន្មានឆ្នាំហើយ ទាំង ៤ អង្គក៏បានសេចក្តីសុខទុក្ខដូចម្តេច ហើយទ្រង់ព្រះនាមាអ្វីខ្លះ ទើបមហាឥសីទាំងបួនបានស្តាប់ហើយទើបទូលតបទៅវិញថា អាត្មាទាំងបួនរូបនេះមកនៅសាងព្រឹទ្ធ ក្នុងព្រៃអរញ្ញនេះប្រមាណកប់បានមួយសែនឆ្នាំហើយ រីឯនាមករនោះ អាត្មាឈ្មោះអាចុន្ទុតារី ១ អង្គមួយនោះឈ្មោះយុត្តអក្ខរ: អង្គមួយនោះទៀតឈ្មោះទេហាឥសី អង្គមួយនោះឈ្មោះ យាគ: ឥសីមានតបតេជឫទ្ធិស្មើគ្នា ៗ ទើបមហាឥសីក៏សួរទៅព្រះឥន្ទ្រវិញ ហេតុដូចម្តេចក៏បានជាស្តេចចុះមកព្រមទាំងទេវបរិវារជាអស្ចារ្យណាស់ ៗ កាលនោះព្រះឥន្ទ្រាធិរាជបានស្តាប់ ក៏ទូលតបពុទ្ធដីកាព្រះមហាឥសី ដែលខ្ញុំមកទាំងនេះ ព្រះអាចារ្យត្បិតអង្គព្រះឥសូរជាម្ចាស់ ឲ្យខ្ញុំមកសាងព្រះនគរពេជណាទីថ្វាយទេវរាជកុមារ ព្រះឥន្ទ្រក៏ទ្រង់សម្តែងហេតុតាំងតែពីដើមដល់ចុងរឿងមកថ្វាយមហាឥសី មហាឥសីក៏ជ្រាបសេចក្តីសព្វគ្រប់ ក៏ត្រេកអរ ទើបមានពុទ្ធដីកាថាព្រៃនេះល្អប្រសើរណាស់ ឈ្មោះហៅថា ណាពវតី នៅខាងទិសបូព៌ាត្រូវដោយលក្ខណាណាទី អាត្មានឹងប្រាប់នាមតាមឈ្មោះនគរទុកឲ្យជាមង្គលសិរីសួស្តីប្រសើរ ចូរយកឈ្មោះព្រៃនេះនិងនាមអាត្មាទាំង ៤ ដាក់ផ្គុំផ្សំគ្នាឈ្មោះហៅថាក្រុងស្រីអយុធ្យាណាពវតីហោង នឹងបានជាត្រេកពេកអន្ទើនរឿងទៅ ៗ កាលបើព្រះឥន្ទ្របានស្តាប់ព្រះឥសីប្រាប់ ដូច្នោះហើយក៏

ចូលចិត្ត ទើបប្រើឲ្យព្រះវេស្សកម្មទេវបុត្រនិម្មិតសាងធ្វើ ព្រះនគរឲ្យឧឡារិកអធិកឧត្តមរុងរឿងធំទូលាយពណ្ណរាយល្អល្អះ ។ គ្រានោះព្រះវេស្សកម្មទេវបុត្រទទួលទេវង្ការស្រេច ហើយក៏នាំគ្នាទៅឈរនៅត្រង់មុខស្ថានទេពារក្ស ជាល័ក្ខព្រៃនោះ ក៏ទ្រង់សំដែងឥទ្ធិឫទ្ធិក៏និម្មិតសាងជាព្រះនគរស្រេចមួយរំពេច វិមានប្រាសាទទាំងប៉ុន្នោះល្អរុងរឿងកំពស់ស្មើនិងអាកាសក្តីប្រាលវេទ្នាលសុទ្ធសឹងតែកែវកែមរកតា ហើយមានរោងរថឆ្វេង ស្តាំ បន្ទប់ ស្រីស្នំក្រមការសេនាអមាត្យទាហានមានសេះដំរីជាដើមគ្រប់បរិបូណ៌ស្រេចមានកំផែងកដក់ង ហើយមានស្រះស្រង់ឧទ្យាន ហើយទើបប្រកបតាមនគរតាំងជាមង្គលសួស្តីបពណ៌នាមក ហើយយកទ្វីបទាំង ៤ មកនៅជាបរិវារពល ប្រជានុរាស្ត្រទាំងឡាយសប្បាយរុងរឿងហើយស្តេចរើសស្រីស្នំក្រមការយកឲ្យតែល្អគ្រប់លក្ខណ៍បញ្ចពិធកល្យាណី ប្រមាណ ៥ ម៉ឺន ៦ ពាន់ ។ លុះសាងព្រះនគរស្រេច អង្គព្រះឥន្ទ្រាធិរាជក៏នាំហ្វូងទេពទេវទំទៅក៏កៃលាស លុះដល់ហើយក៏នាំគ្នាថ្វាយបង្គំព្រះឥសូរទូលតាមសេចក្តី ដែលទ្រង់ប្រើឲ្យទៅសាងព្រះនគរនោះជាស្រេចហើយសូមទ្រង់ជ្រាប ។ ព្រះឥសូរក៏បានជ្រាបហើយក៏ត្រេកអរណាស់ ទើបត្រាស់ទេវង្ការថា ម្នាលទៅ ចូរអ្នកចុះទៅត្រង់ក្រុងស្រីអយុធ្យាឆាពវតី រាជស្ថានជាកំពូលលើសលោកាមហាប្រសើរ ទៅឯងជាពូជពង្សវង្សត្រកូលព្រះនារាយណ៍ទៅនិងបានបង្ក្រាបអសុរគត ទើបព្រះនាទនាម

សន្មតឲ្យឈ្មោះជាអនោមាទន្តទេវសុរិវង្ស ទ្រង់ប្រទានព្រះទម្រង់ នូវសេរ ព្រះខ័ន្ធត្រីពេជ្រជ័យ ហើយទ្រង់ឲ្យពរប្រសិទ្ធិឲ្យមានតបៈតេជៈឫទ្ធិអានុ-ភាព កុំឲ្យសត្រូវណាមកតឫទ្ធិបានឡើយ ហើយឲ្យរុងរឿងវឌ្ឍនាការ មង្គលសួស្តីហោង ។ ព្រះអនោមាទន្តក៏ក្រាបថ្វាយបង្គំទទួលពរពីព្រះឥសូរ នឹងទេពអាវុធទាំងពួងស្រេចហើយ ក៏ទូលថាសូមទ្រង់ព្រះករុណាជួយ ទំនុកបំរុងរក្សាផង ទើបព្រះឥសូរបង្គាប់ទៅព្រះឥន្ទ្រាធិរាជនិងទេវបុត្រ ទេវតាទាំងពួងថា ឲ្យយកគ្រុឌរាជ ជាយានឲ្យទៅអញ្ជើញ ហែទៅ សោយរាជ្យក្នុងវេលាថ្ងៃ នេះជាថ្ងៃមង្គលឫក្សល្អត្រូវប្រគល់នគរឲ្យទៅ អញ្ជើញសោយរាជ្យ ព្រះឥន្ទ្រក៏ទទួលព្រះឱង្ការហើយថ្វាយបង្គំលាមកចាត់ ចែងរៀបចាំដង្ហែព្រះអនោមាទន្ត រួចអនោមាទន្ត ក៏ទ្រង់គ្រឿងប្រដាប់ ប្រដាស្រេចហើយក៏កាន់ធ្នូសរជ័យត្រីពេជ្រ ហើយព្រះឥន្ទ្រលុះបានជ័យ ឫក្សពេលាក៏នាំអនោមាទន្តហោះចុះមក ដល់នគរក្រុងស្រីអយុធ្យាក៏អភិ-សេកឲ្យសោយរាជសម្បត្តិជាសុខក្សេមក្សាន្ត ហើយតាំងចាត់រើសរកយក ស្រីពីឧត្តរកុរុទ្វីបមក ឈ្មោះនាងមណីកេសរល្អលុះត្រចង់ត្រចះដូច ដួងព្រះចន្ទមកធ្វើជាព្រះអគ្គមហេសីធំ ហើយមានស្រីព្រះស្នំក្រមការមួយ ម៉ឺនប្រាំមួយពាន់ជាកំណាន់គាល់បំរើ មួយទៀតមានសេនាពល ហានសេនា បតីមន្ត្រីតូចធំគ្រប់ប្រការ ថ្វាយរាជកុមាររក្សាធានីស្រេចហើយ ទើប ព្រះឥន្ទ្រថ្វាយជ័យថ្វាយពរ ទាំងទេពនិករអមរមេឃក៏ថ្វាយស័ព្ទសាធុការ

ហោង ៗ រួចហើយព្រះឥន្ទ្រនិងទេវតាក៏ហោះទៅកាន់ស្ថានពិមានវិញ ហោង ៗ លុះដល់ព្រះអនោមាទន្តស្តេចក៏សោយរាជ្យគង់ក្នុងនគរស្រីអយុធ្យា ក៏ទ្រង់មានតេជៈតបៈឫទ្ធីទូទៅក្រៃលោកទាំងបី ក៏ពឹងបុណ្យសម្ភារព្រះបារមីគ្រប់នគរ ពួកបច្ចាមិត្រតែឮក៏កោតក្រែងស្ញែងស្ញប់ព្រឺរោមា ទាំងពួកពិទ្យាធរកិន្នរយក្សគ្រុឌ គន្ធព្វគន្ធព នគរតូចធំ ក៏សឹងតែខ្ញុំខ្លាចទាំងអស់ហោងស្តេចគង់ជាសុខក្សេមក្សាន្តសម្រាន្តព្រះអង្គ

នេះនឹងសំដែងតទៅ ពីសហម្បតិព្រហ្មនៅក្នុងពិមានរតនមណីមានសេចក្តីសុខគ្រប់ទិវារាត្រី លុះមួយថ្ងៃក៏មានសេចក្តីរលឹកនឹកដល់ សហ-មល្បីវនដ៏ជាសុរិវង្សពង្សា ដែលឲ្យទៅសោយរាជ្យនៅនគរក្រុងកោះលង្កា ដែលរត់ខ្លាចចក្រព្រះនារាយណ៍ទៅនៅនគរបាតាលដែននគរលង្កាទ្វីបនោះ មិនមានអ្នកណារក្សាជាស្ថានស្ងប់ស្ងាត់សូន្យឈឹងយូរមកជាអន្លង់ ក៏នឹកស្តាយវង្សព្រហ្មនឹងអស់ទៅ បើដូច្នោះអញនឹងគិតសាងនគរឲ្យរុងរឿងឡើងវិញទុកជាល័ក្ខណ៍នគរបវរាភជាតិ ៗ ព្រហ្មគិតហើយទើបមានទេវបញ្ជាត្រាស់បង្គាប់ទៅព្រហ្មជាបរិវារឲ្យរៀបហង្សមាសជាជំនិះ អញនឹងជិះចុះទៅសាងនគរលង្កាទ្វីប ៗ ទើបអជាព្រហ្មទទួលឱង្ការក៏ថ្វាយបង្គំលាថយមកកេណ្ឌពួកព្រហ្មសុទ្ធតែមានឫទ្ធិអានុភាពក្លាហានពួកមួយកាន់ទង់នាំពលព្រហ្មបរយាត្រា មួយពួកទៀតសុទ្ធតែកាន់ស្វេតច្ឆត្រហែឆ្វេងស្តាំ ពួកខ្លះកាន់ទង់រូបក្ងោក ហែខាងហង្សមាស ពួកមួយទៀត

ហែកាន់ខ្សែរៀងកាយជុំវិញមានត្រៃស័ង្ខនាគពាឡគង់ជាដើមហែស្តេចចុះ មក ។ កាលនោះ ព្រះបាទសហម្បតិព្រហ្មក៏គង់លើហង្សមាសទុកាស ចុះមក ឃើញភ្នំទិលក្រឡាខ្ពង់ខ្ពស់កំពស់អាកាសធំ ក្រៃលែងនៅ កណ្ដាលពិភពជាទីជាប្រស្ពាន សម្បូរពណ៌ខៀវដូចនិលវត្ថាចុងកំពូលភ្នំ នោះមានបក្ខក្អែក មហាការ្យសិទ្ធិឫទ្ធិក្រៃ ភ្នំនោះប្រសើរណាស់ ទើប ព្រហ្មប្រើព្រះ វេស្សនុព្រហ្ម និម្មិតសាងសុទ្ធតែកែវសុវណ្ណមណីរត្ន ដោយឫទ្ធិសក្តា មានកំផែងសព្វគ្រប់ជាស្រេច សាងប្រាសាទបីកំពូល ប្រាំល្អដូចជាស្ថានត្រៃត្រឹង្ស ទើបយកនពមហាសមុទ្រជាបន្ទាយជុំវិញ ចាត់ពួកហ្វូងត្រីជានាយកងល្បាតដើងទឹក ត្រីធ្មាមមកពិទ្ធនជាគយចាំ ល្បាតខាងក្រោម ខាងក្រោយព្រះមហាសមុទ្រនោះឲ្យភីសៀយក្សរក្សា ហើយចាត់ឫទ្ធិកាល្យអសុរយុំពលយោធា មួយសែនកោដិក្រវែលរក្សា ខាងផ្លូវអាកាសផ្លូវសួគ៌ គន្ធឧ ក្រវែលរក្សានៅខាងបក្រពឡ ចាត់ចែង រៀបចំនគរជារូបស្រេច ។ ទើបព្រះបាទសហម្បតិព្រហ្មទ្រង់សន្មត នាមនគរ ឲ្យឈ្មោះហៅថានគរក្រុងលង្កាទ្វីប ទើបចាត់យកអសុរ ពួកមារពីភ្នំបក្រពឡ អស្សគណ្ឋ មកជាសេនាគាមាត្យពលរេហ៍ចាំង-អស់មួយសែនកោដិកុម្ភណ្ឌ ស្រេចហើយទើបត្រាស់ប្រាប់ទៅធតា ព្រហ្ម ដ៏ចេះចំណានខាងសៃយវេទមន្តនោះ ចុះមកសោយពជ្យគ្រង សម្បត្តិសុរីវង្សត្រកូលតរៀងមកក្នុងត្រៃលោកហោង ។ អង្គធតា

ព្រហ្មបានស្តាប់ទេវឱង្ការ ក៏លើកករអញ្ជលីទូលតបទៅវិញ ដែលព្រះអង្គ
ទ្រង់មេត្តាករុណានោះព្រះគុណធ្ងន់ជាបំផុតលើសិរសា ទ្រង់ត្រាស់ប្រើ
ហើយ ក៏ទទួលតាមព្រះឱង្ការ កាលនោះព្រះបាទសហម្បតិព្រហ្មបាន
ស្តាប់ហើយក៏ត្រេកអរសោទរណាស់ ទើបឲ្យនាងមល្លិកា ទ្រង់បញ្ចពិធ
កល្យាណី ជាស្រីមានលក្ខណាមកធ្វើជាអគ្គមហេសី ហើយរើសស្រី
ទេពកញ្ញាព្រហ្មយកមកធ្វើជាស្នំក្រមការ បំរើគាល់ហ្វៀមួយម៉ឺនប្រាំមួយ
ពាន់ជាប្រក្រតី ៗ ហើយសហម្បតិព្រហ្មទ្រង់ព្រះពានត្រីសូរដំបងពេជ្រ
មានឫទ្ធិអានុភាព ហើយប្រទានឆត្រជ័យសំរាប់ព្រះនគរ ប្រាប់ថាបើកើត
មានពួកបច្ចាមិត្រលើកមកច្បាំងយកធានីកាលណាហើយ ឲ្យយកឆត្រ
ជ័យ តែបើកបាំងព្រះនគរ នឹងបាំងពន្លឺព្រះអាទិត្យបាត់ងងឹតដូចយប់ ពួក
សត្រូវនោះនឹងមើលមកក្រុងយើងពុំឃើញ ខាងយើង មើលទៅឃើញពួក
សត្រូវទាំងអស់ ឆត្រជ័យនេះមានអានុភាពណាស់ ទេវបុត្រទេវតា
ឥន្ទព្រហ្មអសុរកេតទាំងប៉ុន្មានក៏ខ្វបខ្វាចអំណាចឫទ្ធិ ៗ កាលនោះព្រះបាទ
បតុរកេត្រព្រហ្មក៏ក្រាបថ្វាយបង្គំ ទទួលត្រីសូរដំបងពេជ្រហើយ រៀនវេទ្យ-
មន្តក៏ចាំបានអស់ដូចសេចក្តីហើយក៏ត្រេកអរសោមនស្សណាស់ហោង ៗ
ព្រះបាទសហម្បតិព្រហ្មក៏ប្រគល់រាជសម្បត្តិនគរក្រុងលង្កា ឲ្យហើយក៏ឲ្យ
ពរសព្ទសាធុការថាឲ្យអ្នកមានសិរីសួស្តីមង្គលវឌ្ឍនាការ ឈ្នះអស់សត្រូវ
ទាំង ១០ ទិសកុំឲ្យមកបៀតបៀនផ្តួនាបាន ឲ្យពរស្រេចហើយស្តេចក៏

ឡើងគង់លើហង្សមាសហោះឡើង ទៅកាន់ប្រាសាទវិមានស្ថានអាត្មា
វិញហោង ឯព្រះបាទចតុរក្ត្រគ្រប់គ្រងសោយរាជសម្បត្តិ នៅក្រុង
លង្កាទ្វីបនិងនាងមល្លិកាជាអគ្គមហេសី នូវស្រីស្នំក្រមការទាំង ១.៦០០០
ជាសុខក្សេមក្សាន្តសម្រាន្តព្រះទ័យជូនជាស្ថានត្រៃត្រឹងរ្យាស្ងួត លុះយូរ
បន្តិចទៅ នាងមល្លិកាជាអគ្គមហេសី ក៏ទ្រង់គភ៌គ្រប់ទសមាសក៏ប្រសូត
ព្រះរាជបុត្រាមួយ កើតទៅជារូបអសុរមុខ ១ ដៃ ៤ ព្រះបិតាមាតាទាំង
ពីរ ក៏ត្រេកអរសោមនស្សសោទរហើយ ក៏ប្រទានឈ្មោះហៅថា
ឡាក្សទៀន ព្រហ្មមានឫទ្ធីអានុភាពពុល្យខ្លាយ សាយសព្វគ្រប់នគរ
ទាំងអស់ហោង ។

នេះនឹងនិយាយអំពី ព្រះបាទអនោមាទន្ត ទ្រង់សោយរាជសម្បត្តិ
បានមួយម៉ឺនឆ្នាំ មានព្រះរាជបុត្រាមួយទ្រង់ព្រះនាមឈ្មោះព្រះបាទ អជ្ឈ-
បាល មានឫទ្ធិអានុភាពណាស់ ឮខ្ចរទៅដល់ទ្វីបទាំង ៣ ក៏ខ្ទបទ្វាប
អំណាចព្រះបារមីព្រះអង្គហោង ហើយព្រះបាទអនោមាទន្ត អភិសេក
ព្រះរាជបុត្រា ឲ្យសោយរាជសម្បត្តិគ្រងស្នងរូបស្រេច ស្តេចក៏ទ្រង់សុវណ្ណ
គត់ទៅ ។

(នៅមានត)

# រឿងព្រេងបិនៈ (តមក)

Le Renard roi (Conte Tibétain)

## ចចកក្រែងធ្វើជាស្តេច

*លោក ប៉ាយ-ប៊ុក ប្រែពីភាសាបារាំង*

---

តាំងពីយូរណាស់មកហើយ មានចចកមួយល្មោភខាងអាហារពន់ប្រមាណ បានចូលទៅក្នុងភូមិមួយ ដើម្បីនឹងលួចមាន់គេជាអាហារ ។ ទៅដល់ជិតពេងរម្យាស់ (ផ្ទះ) ចចកក៏ធ្លាក់ទៅក្នុងផាំងខ្ទះរម្យាស់នោះ ។ ចចកបានរត់ចេញពីផាំងខ្ទះបោលចូលទៅក្នុងទីលំនៅរបស់ខ្លួន ។ ចចកដែលមានខ្លួនជ្រលក់ផ្ទះ ក៏មានសភាពគួរលើបរលោងចាំងថែងដូចត្បូង ។ ចចកបានបោលទៅដល់ក្នុងព្រៃមួយ ។ មានពួកចចកឯទៀត បានមើលមកចចកដែលបោលនោះ ឃើញប្លែកអស្ចារ្យ ។ ពួកចចកទាំងនោះក៏សួរចចកដែលប្លែកនោះថា :

« អ្នកឯងជាសត្វអ្វី ? »

ចចកប្លែកនោះ ក៏តបថា : ខ្ញុំជាសត្វនាមថា « អ្នកពាក់មកុដរាជ » (Porte Couronne) ។ ព្រះចៅអធិករាជនៃមហាមេឃ បានឲ្យខ្ញុំមកធ្វើជាស្តេចនៃចតុប្បាទទាំងឡាយ ។

ពួកចចកទាំងឡាយ ក៏យកព្រះរាជឧង្ការទៅផ្សាយចំពោះសត្វទាំងឡាយ ។ សត្វទាំងឡាយក៏មកមើលមហារាជរបស់ខ្លួន ឃើញប្លែកពីសត្វចតុប្បាទទាំងឡាយ ។ ពួកសត្វទាំងនោះ ក៏ព្រមព្រៀងគ្នាលើកចចកដែល

ភ្ជាក់ភ្នែកផ្ទះនេះ ជាមហាពជរបស់ខ្លួន ។

អ្នកពាក់មកុដពជ ក៏ឡើងជិះអស្សតរ តាំងសិង្ហជាព្រះពជង្គរ:ហើយ មានសត្វចតុប្បាទជាបរិវារជាច្រើន បានធ្វើព្រះពជដំណើរ ទៅតាមទិស ជនបទនៃប្រទេសរបស់ខ្លួន ។

តមក អ្នកពាក់មកុដពជ បានមានបន្ទូលឲ្យហៅខ្លាធំនិងសត្វចតុប្បាទ ឯទៀតៗ ឲ្យចូលមកក្រាបបង្គំគាល់ ។

មានកាលមួយថ្ងៃ អ្នកពាក់មកុដពជ នឹករលឹកដល់មាតារបស់ខ្លួន ដែលស្ថិតនៅជ្រលងភ្នំឆ្ងាយ ហើយមានបំណងឲ្យមាតានេះមកសោយ សម្បត្តិនិងកិត្តិយសរបស់ខ្លួន ។ អ្នកពាក់មកុដពជ ក៏បានត្រាស់ប្រើ ចចកមួយឲ្យយកព្រះពជបុត្រហោយទៅជូនមាតាថា ៖មាតាខ្ញុំ! សូម មាតាអញ្ជើញមកប្រញាប់ កូនមាតាឥឡូវនេះ បានសោយពជ្យជាស្ដេច ហើយ ។

មាតានៃអ្នកពាក់មកុដពជ លុះបានទទួលព្រះពជសាររលឹកកូន ហើយ ក៏សួរទៅអ្នកនាំសារថា :

« តើកូនដែលជាទីស្នេហារបស់ខ្ញុំយ៉ាងណាទៅ ឥឡូវនេះ តើរស់ នៅបែបណាខ្លះ ? »

ចចកនាំសារតបទៅមាតាចចកមហាពជវិញថា :

« កូននោះសព្វថ្ងៃ មានជីវភាពចុំថ្កើងរុងរឿងអស្ចារ្យពន់ពេក !

ជីវភាពនោះ មានសភាពអធិកអធមត្រចះត្រចង់ជាអស្ចារ្យណាស់ ។

កណ្តាលព្រះរាជសេវកាមាត្យ មានសត្វសិង្ហ ខ្លា ដំរី ហើយមានសត្វចចកទាំងឡាយ ជាព្រះរាជបរិវារ ។ កូននោះធ្វើកិច្ចការស៊ីតាមទំនើងចិត្តហើយ មួយថ្ងៃៗ ឮតែពាក្យជេរប្រទេចផ្តាសាសត្វ ដែលស្ថិតនៅជុំវិញខ្លួន គ្រាន់តែមានពាក្យខុសឆ្គងបន្តិចបន្តួច កូននោះក៏ខឹងទោមស្រ ជាខ្លាំង... ។

ចចកមាតា មិនពេញចិត្តនឹងកូន ចំពោះអាកប្បកិរិយា ដែលធ្វើបែបនេះ ។

ចចកមាតា ក៏ប្រាប់ទៅចចកនាំសារវិញថា : បើធ្វើអាកប្បកិរិយាបែបនេះ ខ្ញុំមិនទៅទេ ឲ្យទៅប្រាប់ចចកកូនខ្ញុំចុះ ។

ពេលដូច្នេះ ចចកមាតា ក៏ស្ថិតនៅទីកន្លែងដដែល មិនទៅណាមកណាសោះឡើយ ។

តែចចកនាំសារ បានយល់តាមសេចក្តីពិត នូវរឿងអ្នកពាក់មកុដរាជសព្វគ្រប់ប្រការ ។ ដល់ចចកនាំសារវិលត្រឡប់មកកាន់វាំងចចកមហារាជវិញ ក៏ពោលថា :

ខ្ញុំដឹងរឿងទាំងអស់ហើយ ។ បើតាមសេចក្តីពិត អ្នកពាក់មកុដរាជ គឺជាចចកធម្មតាដូចគេយើងដូច្នេះ ខ្ញុំដឹងហើយ ព្រោះខ្ញុំបានឃើញចចកជាមាតា មានរូបរាងទ្រង់ទ្រាយដូចចចកទាំងឡាយពិត ។

កុងពេលនោះ ពួកសត្វដែលស្ថិតនៅអមបបកមហាកជ ក៏មាន ចិត្តពោមនស្សឥតឧបមា ហើយក៏ចង់បញ្ជាក់តើបបកមហាកជនេះ ជាបបក ធម្មតាឬ? មានបបកមួយស្រែកថា :

«សូមឲ្យបបកទាំងឡាយស្រែកទាំងអស់គ្នាឡើង! បើអ្នកពាក់មកុដ កជជាបបកធម្មតា មុខជាលោកស្រែកមានសូរសព្ទដូចបបកយើងហើយ ។

ពួកបបកទាំងឡាយក៏ស្រែកព្រម ៗ គ្នា ។

បបកដែលក្លែងខ្លួនជាស្តេច កុងពេលដែលគង់លើខ្នងដំរីដើរប្រពាត សប្បាយ ដល់ឮសម្រែកបបកទាំងឡាយដូច្នោះ ក៏ស្រែកតាម ។

ដំរីឮសូរសម្រែកនោះ ក៏ឈប់លែងដើរតទៅទៀត ក៏យល់ជាក់ ច្បាស់ថា អ្នកពាក់មកុដកជនេះ ជាបបកក្លែងក្លាយ ហើយក៏មានចិត្តខឹង មហិមា ។

ដំរីពោលថា : «ម្តេចក៏ឯងហ៊ានមកជិះលើខ្នងអញ អាព្រហីន... ថាដូច្នោះហើយ ដំរីក៏គ្រវាត់បបកមហាកជធ្លាក់ដល់ផែនប្រថពី រួចយកជើង ជាន់ក្ស័យជីវិតមួយរំពេចនោះទៅ ។

ចប់រឿងបបកក្លែងធ្វើជាស្តេច នៅមានរឿងទី ១៤ «រឿងកូនអូត» តទៅទៀត ។

ទំនៀមទម្លាប់ នៃខេមរជាតិ
ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
ព្រោះខេមរជាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

## ល្ខោន បាមោជ័យ

ឈ្មោះល្ខោនបាមោជ័យ ទើបតែលេចមានឡើងនៅក្នុងរវាងក្រោយសង្គ្រាមលោកលើកទី ១ ។ សម័យនោះឯង ប្រទេសយើងក៏ឧប្បត្តិកើតឡើងជាវង់ល្ខោនបែបថ្មីមួយប្រភេទហៅថា បាមោជ័យ ដែលជាពាក្យគាន ក្លាយតាមសៀមមកពីពាក្យបាលី «បាមោជ្ជ» និងសំស្ក្រឹត «ប្រាមោទ្យ» មានន័យថា «របាំគួររីករាយ» ប៉ុន្តែសៀមរំលែកជើង «យ» ចេញពីតួ «ទ» ទៅ ហើយប្រកបគ្នា ទ និង យ ទៅជា «ទ័យ» ទទួលសៀម អាន «ទ» ជា «ជ» ទៅទៀត ទ័យ ក៏ក្លាយទៅជា «ជ័យ» រហូតមក ។

កាលល្ខោននេះមកដល់ក្នុងប្រទេសយើងដំបូង ដោយជាការប្លែកផង អ្នកស្រុកយើងក៏នាំគ្នាអបអរសាទរទទួលរាប់អានយ៉ាងគគ្រឹកគគ្រេង គឺថា នៅតាមស្រុកភូមិក្រៅពីរាជធានីក្តី ក៏និយាយចេញឈ្មោះរបាំនេះរឿយៗ ។ អ្នកខ្លះដែលជាអ្នកកំប្លែង ឬជាអ្នកស្រឡាញ់សិល្បៈរបាំពិត ៗ នោះ ក៏បានចូលខ្លួនទៅក្នុងវង់របាំនេះថែមទៀតផង ។ ហេតុមួយទៀតដែលនាំឲ្យបានលេចឮឈ្មោះល្ខោនបាមោជ័យខ្ចរខ្ចាយយ៉ាងរហ័សណាស់ គឺល្ខោន

នេះ មានតួកូនកំសុទ្ធតែជាស្រី ៗ គឺអ្នកធ្វើជាតួប្រុសក៏ជាមនុស្សស្រីដែរ ឯប្រុស ៗ វិញ មានមុខងារគ្រាន់ជាអ្នករៀបចំឆាក លេងភ្លេង នឹង ធ្វើជាតុក្កតាប៉ុណ្ណោះ ៗ អាស្រ័យដោយតួសុទ្ធតែស្រីនេះឯងដែលនាំឲ្យកើតជាទស្សនីយភាពចំឡែក ធ្វើឲ្យអ្នកស្រុកទាក់ចិត្តពន់ពេក នេះម្យ៉ាង ម្យ៉ាងទៀតដោយរបៀបសម្ដែង ឬសាច់រឿងដែលគេយកមកសម្ដែងនេះសោតក៏សុទ្ធសឹងរឿងថ្មី ៗ ក្នុងបច្ចុប្បន្ន ត្រូវចំសេចក្ដីចូលចិត្តរបស់អ្នកស្រុកសម័យថ្មីផង ៗ និយាយឲ្យខ្លីល្ខោនបាមោថ័យនេះហើយ ដែលជាបែបល្ខោនសម័យថ្មីមួយរបស់ខ្មែរយើង ដែលកើតមានឡើងនៅក្នុងភាគខាងដើមនៃគ្រិស្តសតវត្សទី ២០ ៗ ប៉ុន្តែជាការគួរឲ្យស្ដាយពេក ព្រោះមានអាយុមិនបានប៉ុន្មាន ល្ខោននេះក៏បាត់ឈ្មោះបាត់សម្ដែងអស់ទៅវិញ ៗ ដោយការស្ដាយ ហើយដោយយល់ថាជំនាន់មុននៅប្រទេសយើងក៏បានឧប្បត្តិកជាល្ខោនបែបទំនើបថ្មី ( Théâtre moderne ) បានមួយបែបនឹងគេដែរនោះ យើងត្រូវតែកត់ត្រាទុកនូវរបៀបរបបនៃល្ខោនបាមោថ័យនេះទុកសម្រាប់ជាទិដ្ឋានុគតិបង្ហាញឲ្យអ្នកស្រុកជាន់ក្រោយ ៗ ទៅទៀត បានស្គាល់បានដឹង ពីរបៀបពីសម្រស់នៃសិល្បៈរបាំប្រភេទថ្មីនេះផង ៗ ការកត់ត្រាទុកក្នុងទីនេះ យើងរកបានដោយការស្រាវជ្រាវស៊ើបសួរប៉ុណ្ណោះ មិនមែនបានឃើញផ្ទាល់នឹងភ្នែកដូចជាយីកេ ឆៃយ៉ាំ ត្រុដិ ៗលៗ ឡើយ ព្រោះនៅគ្រាយើងតែងអត្ថបទនេះ របាំល្ខោនបាមោថ័យ

បាត់រូបស្នាព័ត៌មានណាចក្រយើងទៅហើយ ។ ហេតុនេះ បើមានការខ្វះខាតខ្វះ ឬសេចក្ដីពន្យល់គ្រង់អន្ទើខ្វះពុំសូវច្បាស់នោះ ក៏ពិតជាកើតឡើងដោយសារហេតុគ្រៅចេតនាតែប៉ុណ្ណោះ ដៀតឯកសារពយការណ៍ឲ្យពត៌មានពីរប៉ាំនេះមកដល់ក្រុមជំនុំយើង ក៏មានសួចស្ដើងដែរ (១) ។

ដូច្នេះយើងសន្នៃស្រទៀពត៌មានតាមឯកសារផង តាមការសាកសួរផ្ទាល់ពីចាស់ទុំដែលធ្លាប់ឃើញផ្ទាល់ភ្នែកផង អាចយកជាកំណត់សេចក្ដីបានដូចតទៅ ៖

## ក– អំពីគ្រឿងសម្ភារៈ

គ្រឿងសម្ភារៈសម្រាប់ប្រកបសិល្បៈនេះ ចែកចេញបានជាបីផ្នែក គឺ គ្រឿងភ្លេង អលង្ការ និងប្រដាប់តែងលំអឆាក ។ សម្ភារៈទាំងបីផ្នែកនេះ យើងសង្កេតឃើញដូចតទៅ :

១– គ្រឿងភ្លេង .– ប្រដាប់ប្រដាភ្លេងសម្រាប់ប្រកបរប៉ាំនេះ សុទ្ធសឹងជាគ្រឿងភ្លេងក្នុងវង់តន្ត្រីទំនើបថ្មីរបស់អឺរុប ដែលគេហៅថា អ័រកេស្ត្រ ( Orchestre )(២) មានត្រែធំ-តូច ស្គរធំ-តូច រុបរមបញ្ចូលគ្នា ដូចជាវង់ភ្លេងដែលខ្មែរយើងធ្លាប់ហៅថា ភ្លេងបារាំង ឬភ្លេងម៉ាឌីល ( មិន

---

១. ឯកសារលេខ ៦៧·០៥៨ របស់លោក កួយ.យក់ហួ ដែលជាអ្នកធ្លាប់កាន់កាប់ល្ខោនបាមោថ័យមួយវង់នៅខេត្របាត់ដំបង គឺវង់ល្ខោនអ្នកស្រីរៀម ជាម្ដាយក្មេករបស់លោក។

២. ជាវង់ភ្លេងបុរាណរបស់ក្រុមល្ខោនក្រិក ដែលលេងអមជាមួយចម្រៀងដែលច្រៀងជាក្រុម។

បាច់កប់រៀបពីរូបកង់គ្រឿងក្មេងនេះទេ ដ្បិតសព្វថ្ងៃ ក្មេងនេះកំពុងតែមាន ឥទ្ធិពលសាយសព្វពេញក្នុងស្រុកខ្មែរយើង ) ។

២- គ្រឿងអលង្ការ.- គ្រឿងអលង្ការរបស់ក្រុមល្ខោននេះពុំមាន អ្វីប្លែកដែលយើងមិនធ្លាប់ឃើញនោះឡើយ ព្រោះរឿងដែលគេយកមក សម្ដែងទាំងប៉ុន្មាន សុទ្ធជារឿងទំនើបថ្មីទាំងអស់ (តាមប្រលោមលោក ដែលមានស្រាប់ ឬមួយជាតែងឡើងថ្មី) ម្ល៉ោះហើយរឿងតែងកាយក៏ ស្របទៅតាមភាពធម្មតានេះដែរ គឺភាគច្រើនជាសំលៀកបំពាក់សាកល និយម (ខោឡេវ-អាវសឺមីសឬអាវប៉េគក ស្រីអាវម៉ូត សំពត់ហូលឬសំ ពត់ពណ៌តាមដំណើររឿង) ។ ជួនកាលក្រុមល្ខោននេះសម្ដែងរឿង បូរាណ តាមសាស្ត្រាខ្មែរយើងខ្លះដែរ ប៉ុន្តែមិនតាក់តែងខ្លួនទៅតាមបូរាណ សុទ្ធទេ គឺចេះយកតែអ្វីត្រង់ណាមួយមកសម្ដែងដែលតាក់តែងតាម បែបទំនើបថ្មីលាយលុកគ្នាផង ម្ល៉ោះហើយសំលៀកបំពាក់ក៏នៅតែជា បែបថ្មីដ៏ច្រើនពុំបាច់មានគ្រឿងចំឡែកអ្វីទៀតទេ ។ ជួនកាលខ្លះទៀតគេ លេងរឿងបូរាណរបស់អឺរ៉ុប ជាពិសេសគឺរឿងរបស់ជនជាតិបារាំង (១) មានរឿងព្រេងខ្លះ រឿងបែបប្រវត្តិសាស្ត្រខ្លះ ឯសំលៀកបំពាក់តែងកាយ ប្រដាប់អាវុធដែលតួកាន់ជាដើម ក៏និយមយកតាមលក្ខណៈសំលៀកបំពាក់ បូរាណរបស់បារាំងនោះទៅ ។

---

១– ព្រោះសម័យនោះ នៅក្នុងអាណានិគមបារាំង ហើយបារាំងកំពុងបង្ហាត់ខ្មែរឲ្យចេះ ចាំអក្សរសាស្ត្របារាំងផង ។

៣- ប្រដាប់តែងឆាក -តែជាសំខាន់សម្រាប់លំអឆាក គឺមានផ្ទាំងគំនូរដែលហៅថា «តាប៉ូ» ដែលមានជារូបភាពផ្សេង ៗ ៤-៥ បែប ហើយតាប៉ូនេះអាចមូរឡើង ឬលាចុះបានដូចតាប៉ូល្ខោនបាស័កដែរ ប៉ុន្តែល្ខោនបាស័កមិនបាច់តែងអ្វីថែមទៀត យកត្រឹមទេសភាពនៃតាប៉ូនេះតែម្តង ៗ ឯល្ខោនបាមោច័យ មានតាប៉ូនេះតិចទេ ព្រោះគេត្រូវធ្វើផ្ទាំងគំនូរជៀរកាត់ ( découpés ) ដូចជារូបផ្ទះ រូបខ្លោងទ្វារ រូបថ្មភ្នំជាដើម យកមកតម្រៀបជាបែបបទឲ្យទៅជាភាពមែនទែន ៗ ក្រៅពីនេះ មានគ្រែ តុ ទូ កៅអី ដំរៀបធ្វើជាបន្ទប់ភ្ញៀវបន្ទប់គេង តាមតែសាច់រឿងតម្រូវឲ្យ ៗ នៅចុងឆាកខាងក្រៅបំផុត គោងមានរាំងននធំមួយដ៏មានពុះចំកណ្តាលសម្រាប់បើកបិទ ៗ

## ១- អំពីរបៀបសម្តែង

### ១- ការរើសរឿង -.

អត្ថបទរឿងល្ខោន (pièce) នេះ ត្រូវតែសរសេរហ្មត់ចត់ ដូចអត្ថបទល្ខោនសម័យថ្មីសព្វថ្ងៃដែរ ហេតុនេះហើយ អ្នកតែងរឿង (Auteur ) គោងចេះប្រើល្បិចបច្ចេកទេសតាមបែបអក្សរសាស្ត្រសម័យថ្មី ខាងរឿងល្ខោន គឺត្រូវចេះរៀបចំឲ្យមានជាឈុត ជាឆាកត្រឹមត្រូវ(២) ពោលគឺក្នុង

២- ឈុត ប្រែពីបារាំងថា Acte ឆាកប្រែពីបារាំងថា Scène ។

មួយរឿងនេះត្រូវលេង ២ ម៉ោងកន្លះយ៉ាងយូរ ហើយក្នុង ២ ម៉ោងកន្លះនេះ ត្រូវចែកចេញជា ៣ ឬជា ៥ ឈុត ក្នុងមួយឈុត ៗ មានច្រើនឆាកទៅទៀត ។ តាមការនិយមមក បើរឿងវែងមាន ៥ ឈុត គឺ ១ ឈុតជាការបង្ហាញតួ ២ ឈុតជាការចោទបញ្ហា និង ២ ឈុតទៀត ជាការដោះស្រាយបញ្ហា នោះវិញ ។ ឯរឿងខ្លីមាន ៣ ឈុត គឺ ១ ឈុតបង្ហាញតួ ១ ឈុតបំផុសជាបញ្ហាឡើង ហើយ ១ ឈុតទៀតជាការដោះស្រាយបញ្ចប់ ។ ផ្លែរឿងនោះសោត គេនិយមយករឿងដែលមានដំណើរស្របទៅនឹងការពិតក្នុងជីវិតធម្មតាមែន ៗ មកអធិប្បាយ ប្រសិនជាយករឿងបែបបូរាណខ្លះ ក៏គេចោះយកតែអន្លើណាមួយដែលប្រកបដោយបញ្ហាច្បាស់លាស់មកសម្រួលឲ្យបានចប់សព្វគ្រប់ក្នុងរយៈជាងពីរម៉ោងនេះ ។ តាមទំលាប់មក រឿងបូរាណគេច្រើនតែយកពីរឿងបរទេសជិតខាងយើង ដូចជារឿង អ្នកឈ្នះដប់ទិស (របស់ភូមា) រឿងឥណាវ (របស់ម៉ាឡាយូ) រឿងមួយពាន់មួយយប់ (របស់អារ៉ាប់) និងរឿងនាងសន់ទ្រីយ៉ុង (របស់បាកាំង) ជាដើម ។

២– កាយវិការនិងបទចម្រៀង.–

កាលណាពោលពីកាយវិការ គឺសំដៅដល់តួ (ខ្មែរយើងច្រើនហៅថាកូនពាំ) តាំងប្រុសស្រី ។ ក្នុងពេលដែលចេញមកសម្ដែងជាផ្ទាំងរឿងណាមួយ តួត្រូវដើរចេញមកតាមសភាពធម្មតារបស់មនុស្ស គឺដើរ

លឿន ដើរយឺត ឬរត់តាមតែដំណើររឿងតម្រូវឲ្យ ឧបមាថា បើព្រួយ ដំណើរចេញមកក៏ព្រួយ បើប្រញាប់ចេញមកតាមប្រញាប់ ហើយបើរត់ប្រដេញប្រចាប់ ក៏គោនតែធ្វើឲ្យដូចកាយវិការមែនទែនដែរ ។ ការសន្ទនាគ្នា សុទ្ធតែជាសំឡេងធម្មតាពុំបាច់ច្រៀង ពុំបាច់ពត់សំឡេងឲ្យខុសប្លែកពីធម្មតាឡើយ ប៉ុន្តែបើត្រូវការថ្លែងសេចក្តីវែងកប់រៀបពីមនោសញ្ចេត-នា មានការក៏យក៏ប់ពីស្នេហា ពីទុក្ខព្រួយ ពីសេចក្តីនឹករឭកជាដើម ក៏មានច្រៀងជាមួយដែរ ។ របៀបច្រៀងនេះ ច្រើនតែបទទំនើបថ្មី ដែលពួកក្រុមភ្លេងគេតែងឡើងដោយខ្លួនគេ ដោយប្រឌិតយកបទពីបរទេសខ្លះ ពីបទបុរាណខ្មែរយើងខ្លះ ឧទាហរណ៍ដូចជាបទទោចយំ បទដួងចំប៉ា បទឡាវឡៀក បទសែនស្រណោះ បទចៅជក បទខ្មែរពាក់មាស បទសារ-យ៉ាំង, . . . កាលណាបើច្រៀងចប់ឬហៀបនឹងចប់ ទើបភ្លេងចាប់លេងទទួលព្រមគ្នាឡើងតាមបទដែលគួបានច្រៀងរួចមកហើយ ។

ដូច្នេះ សរុបទៅគឺ កាយវិការនៃល្ខោននេះ ជាកាយវិការត្រាប់តាមកាយវិការមែនៗ របស់មនុស្សគ្រប់ដំណើរប្រព្រឹត្តទៅនៃឥរិយាបថ មានការដេក ដើរ ឈរ អង្គុយ ។

៣- ការតុបតែងឆាក :-

ដូចបានពណ៌នាខ្លះមកហើយ ក្នុងផ្នែកប្រដាប់តែងឆាក ថាគេត្រូវមានអ្វីខ្លះ ។ សម្រាប់លំអឆាកល្ខោននេះ តែឥឡូវនេះត្រូវនិយាយជាបន្ត

ទៅទៀតអំពីរបៀបរៀបចំក្នុងការតុបតែងឆាក ។ របស់សំខាន់ជាងគេគឺ គាប៉ូវាំងនន និងរូបភាពជៀរកាត់ (Découpé) ។ គាប៉ូគេព្យួរទៅភ្ជាប់នឹងរនុងលើនៃដំបូលរោង បើមានចំនួនប៉ុន្មានក៏ដោយ ក៏ត្រូវតម្រៀបគ្នាពីមុខពីក្រោយជិត ៗ គ្នាតែកុំឲ្យប៉ះគ្នា ព្រោះនាំឲ្យពិបាកមូរឡើង ឬលាទំលាក់ចុះ ។ សងខាងមានខ្សែរតែហើយទំលាក់កន្ទុយខ្សែមកក្រោមសំរាប់មនុស្សម្នាក់ចាំរូតឡើងរូតចុះតាមពេលត្រូវការ ។

វាំងននបិទពីក្រៅបំផុតឆាកនោះ មិនមានខ្សែរតែរូតមូរឡើងលើដូចគាប៉ូទេ គឺមានកន្ទុយខ្សែចងជាយវាំងននត្រង់ព្រាសមុខគ្នាចំពាក់កណ្ដាល ហើយទាញវែកបើកទៅសងខាង ឬបិទវិញនៅពេលណាដែលអស់មួយឈុត ៗ (ជួនគេបើកឡើងលើក៏មាន) ។

ផ្ទាំងគំនូរជៀរកាត់ ដែលកាត់ជារូបផ្សេង ៗ នោះមានពីរបែប គឺមួយបែប ជាភាពបញ្ឈរ ពីក្ដារឆាកឡើងទៅទល់រនុងដែលសំរាប់ចងព្យួរគាប៉ូ គឺទៅទល់វាំងននរំកាយដែលព្យួរខាងលើជាច្រើនផ្ទាំងពីមុខពីក្រោយ សំរាប់ការពារកុំឲ្យទស្សនិកជនមើលឃើញដំបូលរោង ៗ រូបបញ្ឈរនេះម្ខាងជារូបសសរផ្ទះ ម្ខាងទៀតជាដើមឈើ ព្រោះសំរាប់ប្រើការពីរយ៉ាង គឺកាលណាជាឆាកក្នុងផ្ទះគេយកខាងរូបសសរផ្ទះ បើជាឆាកក្នុងព្រៃគេបំបែរត្រឡប់យកខាងរូបដើមឈើចេញមកក្រៅវិញ ។ មួយបែបទៀតរូបគំនូរជៀរកាត់ ដែលមានធ្នឹមឈើធ្វើជាគ្រោងទាញលាតសន្ធឹងសាច់សំពត់

ផ្ទាំងគំនូរផងនោះ មានជារូបភាពផ្សេងៗ ច្រើនយ៉ាង មានរូបដុំថ្ម រូបដើមផ្កា រូបផ្ទះស៊ុក ឬផ្ទះថ្ម មានទ្វារបង្អួចល្មមឲ្យមនុស្សដើរចេញចូលបានៗ រូបនេះមានតូចមានធំ តាមតែទំហំរូប ហើយបើកន្លែងណាមាននិយាយថានៅទីណា ដូចជាកន្លែងផ្ទះ ឬកន្លែងសួន ឬកន្លែងភ្នំ អ្នករៀបចំគេលើកយកផ្ទាំងនោះមកតាំងភ្លាមៗ ជាមួយកៅអីដែរ ។

ឯពន្លឺភ្លើងជាន់ដំបូងនៃល្ខោននេះ គេប្រើចង្កៀងគោមព្យួរ តែក្រោយមកប្រើភ្លើងអគ្គិសនីដែរ ដ្បិតគេលេងតែពេលយប់ ។

## គ – ប្រវត្តិល្ខោនបាមោជ័យ

ពិតមែនតែល្ខោននេះ ថយឥទ្ធិពលអស់ទៅមិនទាន់ជាយូរប៉ុន្មាន ប៉ុន្តែប្រវត្តិរបស់ល្ខោននេះ ហាក់ដូចជាចង់រលាយព្រិលៗ មើលលែងច្បាស់ទៅហើយ ដោយហេតុអ្នកស្រុកនៅសម័យនោះ គ្រាន់តែនាំគ្នានិយមទស្សនា ពុំសូវបានដេញដោល សញ្ជឹងរិះរកដើមកំណើតឲ្យវែងឆ្ងាយឡើយ រីឯអ្នកដែលបានដឹងផ្ទាល់ខ្លួនក្តី ក៏ពុំបានសរសេរកត់ត្រាទុកគង់ជាលាយលក្ខណ៍អក្សរទុកតមកដែរ សព្វថ្ងៃនៅសល់តែការបន្តតាំងដោយនិយាយនឹងមាត់ទទេប៉ុណ្ណោះ ។ តាមការស៊ើបសួរខ្លះអំពីចាស់ៗ ដែលចូលចិត្តនិងល្ខោននេះ ធ្លាប់បានឃើញនឹងខ្លួនធ្លាប់កាន់កាប់វង់ល្ខោននេះផ្ទាល់ខ្លួនតែម្តងផងនោះ យើងប្រមូលយកពត៌មានបានជាន័យថ្មីខាងក្រោមនេះ ។

នៅពេលផុតរលត់សង្គ្រាមលោកលើកទី ១ (១៩១៤-១៩១៨) ទៅ ក្រោយនោះបន្តិចក៏លេចឃើញមានរបាំល្ខោនបាមោជ័យកើតមានឡើងក្នុងស្រុកយើង ។ ទម្រង់របាំនេះចូលមកប្រទេសខ្មែរយើងឃើញពីរផ្លូវ គឺស្រុកសៀមនិងស្រុកយួន ។ កាលនោះស្រុកយួនក្តីស្រុកសៀមក្តី សុទ្ធសឹងជាប្រទេសខ្វះខាតខាងក្បួនខ្នាតសិល្បៈ ម្ល៉ោះហើយក៏រត់រកម្ចាស្រពយកសិល្បៈរបស់ប្រទេសជិតខាង ឬប្រទេសធំ ៗ ណាមួយយកមកធ្វើជាសិល្បៈផងខ្លួន ។ ហេតុនេះគួរតែដេញដោលសួរទៅរកមែកធាងឲ្យឃើញសព្វឫសគល់ពីដើមមកសិន ។

ប្រទេសយួនជាអ្នកបណ្តុះបណ្តាលវប្បធម៌ជាតិខ្លួនតាមបែបវប្បធម៌ចិន ជាកស្តុតាងគឺតួអក្សរ(១) ក្បាច់ចំឡាក់ សាសនា សិល្បៈនិងទំនៀមទំលាប់ទូទៅ ៗ សិល្បៈល្ខោនចិន ក៏ត្រូវយួនយកមកច្នៃរចនាជាសិល្បៈជាតិគេដែរ(២) ប៉ុន្តែរូបរាងគំនិតការនៅតែដដែល គ្រាន់តែប្លែកភាសាតែប៉ុណ្ណោះ ៗ ម្ល៉ោះហើយ គំនិតការឡើងច្រើនក្រោយសិល្បៈនៅជាប់ក្នុងជនជាតិយួនជានិច្ច តែវិធីការឡើងពុំមែនចេះតែធ្វើកើតបានភ្លាម ៗ ទេ តោងតែយកលំនាំរបស់នរណាមួយធ្វើជាបែបបទផ្តួចផ្តើមគំនិតផង ៗ ជូនជាពេល

១– សព្វថ្ងៃគេប្តូរជាតួអក្សររ៉ូម៉ាំង (Romanisé) វិញ តែអក្សរយួនពីដើមជាអក្សរចិនសុទ្ធ ខុសតែសំឡេងអានទេ ។

២- តាមសៀវភៅ (Théatres Vietnamiens Editons, de langues étrangéres, Hanoi) ថាកើតដើមដំបូងពីពួកឈ្លើយសង្គ្រាមជាតិចិន ។

បារាំងមកធ្វើជាអាណាព្យាបាល លើដែនតុងកឹង (វៀតណាមខាងជើង) ដែនអណ្ណាម (វៀតណាមកណ្ដាល) និងជាអាណានិគមលើដែនកូសាំងស៊ីន (វៀតណាមខាងត្បូង) បារាំងនាំយកល្ខោនគេដែលហៅថា «តេអាត្រ» មកផ្សាយលើទឹកដីយួនយ៉ាងពាសពេញស្រុក ជាពិសេសក្នុងមជ្ឈដ្ឋានមន្ត្រីរាជការ និងអ្នកមានទ្រព្យសម្បត្តិ ។ ចំណេរមក បណ្ដាជនអ្នកសិល្បៈយួន ក៏ធ្មៀតឱកាសប្រឌិតយកបែបល្ខោនបារាំងនេះបញ្ចូលថែមទៅក្នុងល្ខោនបុរាណខ្លួនជាល្ខោនច្រៀង (Théatre chanté) ដែលយកពីចិនមក នោះឲ្យទៅជាបែបល្ខោនសម័យថ្មីមួយឡើង មានច្រៀងតែតិចតួច គេនិយមនិយាយច្រើនទៅជាបែបល្ខោននិយាយ (Théâtre Parlé) វិញ ហើយឲ្យឈ្មោះថាកៃលឿង (១) ។ ល្ខោនកៃលឿង ក៏បានចូលមកលេងនៅស្រុកខ្មែរម្ដងៗដែរ ព្រោះកាលនោះយួន និងខ្មែរយើងស្ថិតនៅក្នុងបន្ទុករាជការផ្ដាច់ការបារាំងជាមួយគ្នា ។ អ្នកស្រុកខ្មែរទស្សនាល្ខោននេះទៅ ឃើញថាប្លែកក្អេកណាស់ដែរ នាំឲ្យអ្នកសិល្បៈស្រុកយើងសំគាល់ទុកខ្លះចំណុចខ្លះសំរាប់កាត់តែងបញ្ចូលក្នុងសិល្បៈយើងផង ។

ចំណែកប្រទេសសៀម សៀមនេះជាស្រុកទើបនឹងកើតថ្មីនៅរវាងសតវត្សទី ៨ នៃគ្រិស្តសករាជ ។ វប្បធម៌ខ្លួនរបស់សៀម សុទ្ធសឹងជាវប្បធម៌ខ្មែរស្ទើរតែទាំងអស់ មានតែបន្តិចបន្តួចដែលសេសសល់មកពីពួក

១ - តាមសៀវភៅ Théâtre Vietnamien ថា កៃលឿង មានឈ្មោះម៉្យាងទៀតហៅហាត់បៅ ។

ផ្ដក់សីនៅត្រង់នោះ ប្ដិតដោយមកពីខេត្តណាន់ចៅឯប្រទេសចិនមកជាមួយពួកជនជាតិថៃ (១) ដែលចូលមកស្ថាបនាអាណាចក្រនេះ ៗ ម្ល៉ោះហើយសិល្បៈរបស់សៀម ជាសិល្បៈខ្មែរទាំងស្រុងដែលពួកនេះបានចូលមកកត់ក្បាតពីសម័យអង្គរ ហើយដឹកនាំក្បួនខ្នាតយើងយកទៅ ៗ មិនតែប៉ុណ្ណោះ ពួកនេះបានកាត់តែងធ្វើជាវង់របាំគេឡើង គឺប្រឌិតយកវង់របាំក្បាច់ ដែលសំដែងជាឆាករឿងស្វា មានពាក់មុខ ប្រកបជាមួយភ្លេងពិណពាទ្យ ៗ គេដាក់ឈ្មោះរបាំនេះថា ល:ខោន (២) ហើយរបាំល:ខោននេះ មិនបានគង់វង្សយូរទេ ក៏ពួកសិល្បៈសៀម ដែលនិយមតាមសិល្បៈ ពួកអង់គ្លេសនាំគ្នាកែ ព្រោះពេលនោះសៀមកំពុងតែនិយមអារ្យធម៌បស្ចិមប្រទេសបែបអង់គ្លេសខ្លាំងណាស់ ៗ ការប្រឌិតបញ្ចូលថែមនេះមានបច្ចេកទេសខាងការតែងរឿង រៀបឆាក របៀបលេងទូទៅ ហើយ

---

១– ពួកថៃជាកុលសម្ពន្ធធំមួយនៅក្នុងប្រទេសចិនភាគខាងត្បូង ។

២– តាមលោកសឺដេស សរសេរចុះក្នុង Bulletin de la S.E.I. 3e et 4e Trimestre 1963 P.499 ថាពាក្យ “ខោន,, មកពីពាក្យខ្មែរ “ខោល,, ដែលជាស្វាធំមួយប្រភេទ ដ្បិតរបាំរាំរឿងស្វា គេឲ្យឈ្មោះថា របាំខោល ។ ក្លាយទៅសៀម ជាល្ខោន រួចបាត់សំឡេងរបាំ នៅតែ “ល:ខោន,, ។ សេចក្ដីសន្និដ្ឋាន ១ ទៀតថា មកពីពាក្យដើមខ្មែរហៅ របាំនគរ បានជាសៀមយកទៅ អានតាមសំឡេងសៀមថា “នៈខន,, គឺពាក្យនគរនេះឯង ឬមួយក៏ពាក្យនេះសៀមអានក្លាយមកពីពាក្យជ្វាថា “ឡាកុន,, ដែលប្រែថា រឿងរបាំ ។

សំគាល់ឈ្មោះថ្មីមួយថា « លះខោនលិកេ ឬ លិកេ » (១) ។ គឺជាលិកេនេះហើយ ដែលមានរបៀបសម្ដែង ចេះតែប្រែក្លាយបន្តិចម្ដង ៗ មកតាមបែបល្ខោនសម័យថ្មីអំពីអឺរ៉ុប ហើយគឺជាលិកេនេះទៀត ដែលកាឡៃមកជាលះខោន រួចពីនេះទៅជាលះខោនបាមោថ័យ ដូចជាយើងរាប់រៀបមកខាងលើស្រាប់ ។ លះខោនបែបនេះឯង តែងបាននាំចូលមកសម្ដែងក្នុងទឹកដីខ្មែរជារឿយ ៗ ដែរ ជាពិសេសនៅខេត្តបាត់ដំបង ព្រោះជាខេត្តនៅជិតព្រំដែនសៀម ហើយជួនកាលខ្លះ ពួកសិល្បៈខ្មែរយើងធ្លាប់ចូលទៅទស្សនាលះខោននេះឯខេត្តអរញ្ញដែលនៅជិតទល់ដែន គេអាចចេញចូលទៅមកបានដោយងាយ ។ ម្ល៉ោះហើយ ឥទ្ធិពលរបាំនេះក៏ចូលមកស្រុកខ្មែរ គឺបណ្ដាលចិត្តគំនិតខ្មែរឲ្យនឹកឃើញបង្កើតជាក្រុមល្ខោន (២) មួយប្រភេទថ្មីឲ្យឈ្មោះថា « ព្រាមោទ្យ ឬ បាមោទ័យ » ដែលក្លាយតាមសំឡេងសៀមគាន « ទ » ទៅជា « ថ » នោះ ទើបបានជាឈ្មោះថា « បាមោថ័យ » តរហូតមក ។

ដូច្នេះ ល្ខោនបាមោថ័យ យើងសន្និដ្ឋានបានថា ជាល្ខោនបែបទំនើបថ្មីមួយដែលខ្មែរយើងឧប្បត្តិកឡើង ក្នុងភាគខាងដើមនៃសតវត្សទី ២០ យើងនេះ គឺក្នុងរវាង គ. ស. ១៩២០ ដល់ ១៩៤០ ទើបអស់ឥទ្ធិពល

---

១- លិកេ នេះមិនលេងមានបែបផែនដូចយីកេខ្មែរយើងទេ គឺជាបែបផែនល្ខោនជាន់ថ្មីទៅវិញ ឯបែបយីកេជាន់ចាស់នោះក៏ហៅ យីកេ ដូចយើងដែរ ។ ២- ពាក្យល្ខោន ក្លាយពីពាក្យ លះខោនរបស់សៀម ។

ទៅវិញដោយសារមានល្ខោនបាសាក់ ឡើងពីស្រុកបាសាក់ ( កម្ពុជាក្រោម ) មកប្រណាំងប្រជែងយកជោគជ័យបានទៅ ។ ហេតុដែលនាំឲ្យល្ខោនបាសាក់ឈ្នះ មកពីល្ខោនបាសាក់មិនទំនើបហួសពេកនៅមានច្រៀងច្រើន លេងរឿងបូកណា ៗ របស់ខ្មែរតាមសាស្ត្រាទៀត ឯល្ខោនបាមោជ័យថ្មីពេក លេងតែរឿងជាន់ថ្មីមិនសូវមានច្រៀង នាំឲ្យអ្នកស្រុកភាគច្រើនដែលពុំទាន់យល់បែបបទសិល្បៈទំនើបថ្មីនោះ ឈោងចាប់ពុំដល់ ហេតុហ្នឹងហើយបានជាល្ខោនបាមោជ័យបាត់បង់ឥទ្ធិពលទៅ ។

---

## ការសេពគប់ (ពាក្យ ៧)

គប់ពាលបានទុក្ខប្រាសសុខឆ្ងាយ គប់ពាលអន្តរាយកាយមួយហ្មង គប់ពាលហិនហោចប្រយោជន៍ផង គប់ពាលកន្លងច្បាប់វិញ្ញូ ។ ពាលោពាលាមារយាទថោក ប្រវិញ្ញូនចលោកផ្គង់ជីវី ផ្គង់តែជីវិតឥតខណ្ឌី នរកប្រែវក់វីពុំទឹកដល់ ។ ស្ថានជាទុច្ចរិតសប្បាយលន់ ពុំឆ្អែតពុំឆ្អន់ផ្តុកលុះហល់ សាងតែអំពើអកុសល វេរាទុក្ខខ្វល់ដល់បរលោក ។

គប់ប្រាជ្ញបានសុខស្រណុកខ្លួន គប់ប្រាជ្ញគាប់ជួនបាត់សៅសោក គប់ប្រាជ្ញប្រាសទុក្ខមានជ័យជោគ តាំងពីឥធលោកយោគបរជាតិ ។ អ្នកប្រាជ្ញនាំកាយបានថ្កើងយស កេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់សុះសព្វញាតិ ប្រាប់ផ្លូវសុចរិតពិតពុំឃ្លាត អ្នកផងសង្វាតស្វះស្វែងរក ។ ដូចផ្កាពិដោរសុគន្ធា ជនផងនានាមីរមួលមក ព្រេបស្រង់យកក្លិនថ្ងៃពន្ធក គ្មោះគ្មានលែលក់ទុក្ខក្នុងប្រា[illegible] ។

ដូច្នេះឲ្យអស់ក្មេងទាំងឡាយ កែកុនខ្វល់ខ្វាយរិះរកអាន លះពាលយកប្រាជ្ញបានសុខសាន្ត ហិនស្ងួតនិញានប្រសើរអើយ ។

ដេង-ជ្រីវ

## ផ្នែកកំណត់និងប្រវត្តិការណ៍

# ប្រវត្តិនៃវត្តប្រាង្គ


រៀបរៀងដោយ ព្រះពោធិវង្ស ហួត-តាត

អគ្គាធិការនៃពុទ្ធិកសិក្សា


## នាមនៃចៅអធិការវត្តប្រាង្គ

តាំងពីពេលក្រោយដែលសម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀង ជាចៅអធិការវត្តប្រាង្គ ទ្រង់ស្តេចចេញពីវត្តប្រាង្គមកគង់នៅវត្តឧណ្ណាលោមក្រុងភ្នំពេញ ក្នុង គ.ស.១៨៦៥ ព្រះសង្ឃទាំងឡាយដែលធ្វើជាចៅអធិការវត្តប្រាង្គបន្តបន្ទាប់គ្នាមក ដោយលំដាប់រហូតដល់សព្វថ្ងៃនេះ មានចំនួន៩ រូបដូចមាននាមខាងក្រោមនេះគឺ :

១– លោកគ្រូព្រះមហា ឆាយ

២– ព្រះធម្មឃោសាចារ្យ មាស

៣– ព្រះធម្មឃោសាចារ្យ យិន

៤– ព្រះធម្មឃោសាចារ្យ ឡៀក

៥– ព្រះគ្រូគេនមុនី កែ

៦– ព្រះមហា ឆន្ទ

៧– ចៅអធិការ សេង

៨- ចៅអធិការ ពេជ្រ.ប៊ូ

៩- ព្រះគ្រូពោធិញ្ញាណ ជិត-កុំ ចៅអធិការបច្ចុប្បន្ន

គិតតាំងពីចៅអធិការទី ១ ក្នុង គ.ស.១៨៦៥ ដល់ទី៩ ក្នុង គ.ស.១៩៦៣នេះ ឃើញថាមានរយៈកាល ៩៨ ឆ្នាំហើយ ។

ក្នុងរយៈកាល ៩៨ ឆ្នាំនេះ វត្តប្រាង្គជួនកាលមានសេចក្ដីចំរើនរុងរឿង ជួនកាលក៏មិនមានសេចក្ដីចំរើនរុងរឿង ព្រោះកាលវេលាឋិតនៅក្នុងអនិច្ចលក្ខណធម៌ជានិច្ច ។

កាលនៅទីបំផុតនៃការគ្រប់គ្រងលោកគ្រូចៅអធិការទី ៣ គឺលោកគ្រូព្រះធម្មឃោសាចារ្យ យិន ឈ មានហេតុ១ដ៏កាចសាក្រក់កើតឡើងក្នុងទីវត្តប្រាង្គ នាំឲ្យវត្តប្រាង្គបានទទួលនូវវិបត្តិ ១ ដ៏ជាគ្រោះថ្នាក់ដែលពុំធ្លាប់ជួបប្រទះ គឺកើតជម្ងឺអាសន្នរោគនៅក្នុងទីវត្តត្រឹមតែ ១ថ្ងៃ ១យប់ប៉ុណ្ណោះ ជម្ងឺនោះអាចផ្ដាច់នូវជីវិតព្រះសង្ឃក្នុងទីវត្តប្រាង្គអស់ចំនួន ១៦ រូប រួមទាំងលោកគ្រូព្រះធម្មឃោសាចារ្យ យិន ឈ និងលោកគ្រូសូត្រ គឺព្រះបាឡាត់ ឆ ជ់ ផង ។ ក្នុងពេលនោះ ព្រះសង្ឃដែលសេសសល់ក្នុងវត្តត្រូវរត់ចេញពីវត្តអស់ឥតមានសល់ ។ ពួកពុទ្ធបរិស័ទជើងវត្តជិតឆ្ងាយក៏ឥតហ៊ានចូលមកក្នុងវត្តសោះឡើយ ។ ម្ល៉ោះហើយ វត្តប្រាង្គនោះត្រូវនៅដោយស្ងាត់ជ្រងំ ដូចជាមនុស្សដែលផុតខ្យល់ចេញចូលហើយ សល់នៅតែរូបកាយជាសាកសពទទេ ក្នុងកណ្ដាលព្រៃ ។ វត្តប្រាង្គក្នុងពេលនោះ

ត្រូវនៅក្នុងកណ្ដាប់ដៃនៃពួកចោរ ព្រមទាំងបិតនៅក្នុងកណ្ដាលនៃសម្រែក វត្តលូតាំងយប់តាំងថ្ងៃ ដូច្នេះហើយបានជាវត្តប្រាង្គបានត្រូវទទួលមហន្តរាយយ៉ាងសម្បើម គឺសម្បត្តិដ៏មានតម្លៃ ដែលមាននៅក្នុងវត្តទាំងប៉ុន្មាន ត្រូវវិនាសអន្តរាយអស់ឥតមានសល់ ។

វត្តប្រាង្គដែលទទួលគ្រោះថ្នាក់ ក្នុងសម័យនោះអស់ចំនួន ១៨ ថ្ងៃ ក្រោយពីនោះ សម្ដេចព្រះមហាសង្ឃរាជព្រះនាម ធៀង ទ្រង់បានចាត់តាំងព្រះធម្មឃោសាចារ្យ ឡុក ឲ្យទៅធ្វើជាចៅអធិការវត្តប្រាង្គតមកទៀត ។

លុះដល់ចៅអធិការទី ៦ វត្តប្រាង្គមានការរៀបចំខាងការសិក្សាខ្លះ ខាងផ្លូវប្រតិបត្តិខ្លះ តែមិនបានប្រព្រឹត្តទៅស្រួល ចេះតែរអាក់រអួលដោយមានឧបសគ្គស្ទាក់ផ្លូវជាដរាប ។

ក្នុងរយៈកាលនៃចៅអធិការទី ៧ ទី ៨ ទី ៩ វត្តប្រាង្គក៏ត្រឡប់បានចំរុងចំរើនឡើងដោយការសិក្សា និងការប្រតិបត្តិដ៏សមរម្យតាមព្រះពុទ្ធសាសនា ព្រមទាំងបានចំរើនដោយទីសេនាសនៈគ្រប់យ៉ាង ឧបសគ្គទាំងឡាយក៏រលាយរលត់ទៅជាលំដាប់ ។ ចំណែកភិក្ខុសាមណេរក្នុងទីវត្តប្រាង្គ ក៏មានបរិបូណ៌ ក្នុង ១ ឆ្នាំ ៗ មានចំនួន ៧០ ឬ ៨០ អង្គដែលចេញពីវត្តនានា ក្នុងព្រះរាជអាណាចក្រ មកសូមសំណាក់អាស្រ័យនៅក្នុងវត្តប្រាង្គ ដើម្បីសិក្សាព្រះបរិយត្តិធម៌ និងចំណេះវិជ្ជាផ្សេង ៗ ព្រោះ

នៅវត្តប្រាង្គ មានសាលាពុទ្ធិកបឋមសិក្សា តាំងពី គ.ស. ១៩៣៤ រហូតដល់ឆ្នាំ ១៩៦៣ នេះ ពុំដែលមានការអាក់ខានក្នុងឆ្នាំណាមួយឡើយ គឺមានអាចារ្យសម្រាប់បង្ហាត់បង្រៀន មានសមណនិស្សិតបរិបូណ៌ តាំងពុទ្ធបរិស័ទចំណុះជើងវត្ត ក៏មានសទ្ធាជ្រះថ្លាជួយទំនុកបម្រុងដោយចតុប្បច្ច័យ ល្មមព្រះភិក្ខុសង្ឃ សំណាក់អាស្រ័យរៀនសូត្របានដោយសុខស្រួល ។

ដែលជាពិសេសជាងគេ គឺលោកចៅអធិការទី ៩ ក្នុងបច្ចុប្បន្នកាលនេះ ។ លោកចៅអធិការនេះឈ្មោះ ធិត-កុំ មានសមណសក្តិជាព្រះគ្រូពោធិញាណ លោកត្រូវជាចៅទួតនៃលោកគ្រូព្រះធម្មឃោសាចារ្យ មាស ជាចៅអធិការទីពីរ ។ តាំងពីលោកបានទទួលឋានៈជាចៅអធិការមកទល់នឹងឆ្នាំ ១៩៦៣ នេះ ជាង ១០ ឆ្នាំហើយ ក្នុងវត្តប្រាង្គ មានសេចក្តីចំរុងចំរើនគ្រប់ផ្នែក សេចក្តីសុខសាន្តក៏មានបរិបូណ៌ តាំងពុទ្ធបរិស័ទក៏មានសាមគ្គីធម៌ល្អ ព្រោះលោកចៅអធិការនេះសូត្របួត មានបុគ្គលាភិសុភាពកបសារ មានចរិយាសមរម្យ គួរឲ្យគេពេញចិត្តជ្រះថ្លា ឯចំណេះវិជ្ជាគួរសមទេ មានត្រឹមតែវិញ្ញាបនប័ត្រនៃសាលាពុទ្ធិកបឋមសិក្សាប៉ុណ្ណោះ ប៉ុន្តែជាអ្នកឈ្លាសវៃក្នុងកិច្ចការតាំងពួង ហើយខំប្រឹងប្រែងបំពេញកិច្ចការគ្រប់យ៉ាង ឥតប្រហែសធ្វេស ។

ក្រោពីចៅអធិការ មានខ្ទួនខ្ញុំ គឺព្រះពោធិវង្ស ហ្វួត-តាត ដែល

មានជាតិភូមិនៅផ្សារទេដុនវែវ បានមកសិក្សាឯវត្តខុណ្ណាលោម ក្រុងភ្នំពេញ តាំងពីកាលនៅជាសាមណេរអាយុ ១៣ ឆ្នាំ លុះដល់មានវ័យបរិបូណ៌ហើយ បានទទួលឧបសម្បទជាភិក្ខុនៅវត្តឧណ្ណាលោម ហើយតមកខ្ញុំបានជួយបំពេញកិច្ចការគ្រប់ផ្នែកក្នុងវត្តប្រាង្គ រួមជាមួយនឹងលោកចៅអធិការវត្តប្រាង្គ តាំងពីចៅអធិការទី ៦ រហូតដល់ចៅអធិការទី ៩ ថ្ងៃនេះ ។

នៅក្នុងវត្តប្រាង្គ មានវត្ថុដ៏ប្រសើរ ជាគោលចារិកសម្រាប់វត្តមានពីរគឺ ព្រះប្រាង្គ និងវិហារ ។

## ព្រះប្រាង្គ

ព្រះប្រាង្គដែលមានរូបភាព ភ្ជាប់ក្នុងសៀវភៅនេះ គឺសម្ដេចព្រះមហាសង្ឃរាជព្រះនាម ទៀង ទ្រង់បានជួសជុលឡើងជាថ្មី ដោយទ្រង់នឹកដល់ព្រះពជបណ្ដាំនៃព្រះបាទសម្ដេចព្រះហរិរក្សរាមា ។ កាលមុនសម្ដេចព្រះមហាសង្ឃរាជទ្រង់ជួសជុលនោះ ព្រះប្រាង្គនេះឋិតនៅក្នុងសភាពទ្រុឌទ្រោមបាក់បែកច្រើនណាស់ មានដើមឈើតូច-ធំដុះទ្រុបទ្រុលគ្រប់ថ្នាក់ កន្លែងខ្លះបាក់បែកខ្ទេចខ្ទីរបេះរបេកឥដ្ឋចេញអស់ កន្លែងខ្លះគឺសល់នៅ ល្មមឲ្យសង្កេតយល់បានថាមានរូបភាពយ៉ាងនេះៗ ព្រោះព្រះប្រាង្គនេះតាមការពិនិត្យសង្កេតមើលដោយល្អិតទៅ ឃើញថាគេកសាងមកជាយូរអង្វែងច្រើនសតវត្សរ៍ហើយ មុនការកសាងវត្តប្រាង្គនោះទៅទៀត ។ (នៅមានត)



សម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ទ្រង់កំពុងស្តេចលើកម្រាលដ៏ប្រណិត ពោរពេញដោយបុប្ផា ក្លិនក្រអូបដែលយុវតីដ៏ស្រស់ប្រិមប្រិយ បាចថ្វាយជាព្រះបរមកិត្តិយសដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសពិធីសម្ពោធ ឆ្លងព្រះវិហារ - បញ្ចុះសីមាវត្តប្រាង្គ ( ឧត្តុង្គ ) នៅថ្ងៃទី ២២ - កុម្ភៈ ១៩៦៤

# បុណ្យឆ្លងវិហារវត្តប្រាង្គ និងបញ្ចុះសីមា

*ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមាតាជាតិ និង*
*សម្តេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍*

---

ឧដុង្គជារាជធានីបុរាណរបស់ប្រទេសកម្ពុជា មុនព្រះរាជធានីភ្នំពេញ ចម្ងាយប្រមាណ ៤០ គីឡូម៉ែត្រពីភ្នំពេញ ។ យើងនៅចាំបានថា ឧដុង្គជាអតីតរាជធានីខ្មែរ ដែលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទ្រង់បោះបង់ចោលនៅឆ្នាំ ១៨៦៥ ។ តាំងពីពេលនោះមក ឧដុង្គក្លាយទៅជាទីស្ងាត់ តែកិត្តិនាមឧដុង្គនៅមានល្បីជាដរាបរហូតមកដល់សព្វថ្ងៃ ។

ឧដុង្គក្លាយទៅជាទីស្ងាត់ ស្ទើរបាត់អនុស្សាវរីយ៍រាជធានីទៅហើយ ស្រាប់តែនៅថ្ងៃសៅរ៍ទី ២២ កុម្ភៈ ១៩៦៤ អនុស្សាវរីយ៍មួយដ៏មហាស្ចារ្យ មកបំផុសឲ្យនឹករឃើញដល់ថ្ងៃដែលព្រះរាជធានីតាំងនៅឧដុង្គមុននេះ ១០០ ឆ្នាំ ។ ថ្ងៃទី ២២ កុម្ភៈនេះ មិនគឺអ្វីទេ គឺជាថ្ងៃបុណ្យបញ្ចុះសីមាវត្តប្រាង្គ ។

កម្មវិធីបុណ្យបញ្ចុះសីមាវត្តប្រាង្គ គឺចាប់ពីថ្ងៃ ១៩ កុម្ភៈ រហូតដល់ថ្ងៃ ២២ កុម្ភៈ ឆ្នាំ ១៩៦៤ ។ នៅថ្ងៃទី ១ ពេលម៉ោង ៤ រសៀល មានពិធីរំលឹកគុណព្រះរតនត្រ័យនិងប្រកាសទេវតា ហើយហែនិមិត្តសីមាចូលទៅតម្កល់ក្នុងព្រះវិហារ ។ នៅពេលយប់ មានអុជប្រទីបផ្កាលា ហើយ

មានព្រះសង្ឃ ១០០អង្គ ចំរើនព្រះបរិត្ត-វេរនិមិត្តសីមានិងវិហារថ្វាយព្រះភិក្ខុសង្ឃ មានអុជកាំជ្រួចផង ។ បន្ទាប់មក ទើបមានព្រះធម្មកថិកមួយព្រះអង្គ សំដែងព្រះធម៌ទេសនា ។

---

នៅថ្ងៃទី ២ ពេលព្រឹកម៉ោង ៧ ប្រគេនយាគូចំពោះព្រះសង្ឃ ម៉ោង ១០ កន្លះប្រគេនចង្ហាន់ ម៉ោង ៣ រសៀលធម្មថិក ១ ព្រះអង្គ សំដែងធម៌ទេសនា រួចប្រគេនភេសជ្ជៈព្រះសង្ឃ ។ យប់ម៉ោង ៨ និមន្តព្រះសង្ឃ ១០០ អង្គចំរើនព្រះបរិត្ត-អុជកាំជ្រួច-ហើយនិមន្តព្រះធម្មកថិក ទេសនាព្រះធម្មត្រាស់-ធ្វើពុទ្ធាភិសេក ។

នៅថ្ងៃទី ៣ ពេលព្រឹកដូចថ្ងៃទី២ ។ ពេលម៉ោង ៨យប់ ចំរើនព្រះបរិត្ត ម៉ោង៩ ព្រះសង្ឃ ១០០អង្គ ធ្វើសង្ឃកម្ម គឺសូត្រដកសីមាចាស់ ចងសីមាថ្មី ។

ថ្ងៃទី ៤ គឺថ្ងៃទី ២២ កុម្ភៈ ១៩៦៤ ជាថ្ងៃបំផុសទៀតដល់អនុស្សាវរីយ៍នៃសម័យរាជធានីឧដុង្គ ។ នៅម៉ោង ៨ កន្លះ ពុទ្ធបរិស័ទកកកុញមករង់ចាំទទួលសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះប្រមុខរដ្ឋ ។ ចំណែកព្រះសង្ឃវិញ គេសង្កេតឃើញមានសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គជាប្រធាន ។ នៅម៉ោង ៨,៤០ នាទី ប្រជាពលករអើតងើយទៅលើមេឃ ទន្ទឹងរង់ចាំព្រះរាជបក្សីចក្រជាព្រះរាជទីនាំង ។ នៅពេលនេះហើយដែលប្រជាពលរដ្ឋនៅឧដុង្គ រង់ចាំធ្វើគារវកិច្ច ចំពោះសម្តេចព្រះ



សម្ដេចឪព្រះប្រមុខរដ្ឋ ទ្រង់កំពុងស្ដេចលើកម្រាល ពោះពេញដោយបុប្ផាដែលនារីដ៏ស្រស់ប្រិមប្រិយ បាចថ្វាយជាព្រះកិត្តិយសដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសពិធីសម្ភោធឆ្លងព្រះវិហារវត្តប្រាង្គ ( ឧត្តុង្គ ) នៅថ្ងៃទី ២២ កុម្ភៈ ១៩៦៤

មាតាជាតិ និងសម្តេចព្រះបិតាឯកពជ្យជាតិ ។ នៅម៉ោង ៨,៤៥ មហាបក្សីចក្របាននាំព្រះរាជដំណើរនៃសម្តេចឪទៅដល់ទីក្រុងខុដ្ឋ ។ ពេលសម្តេចយាងចុះពីទុម្ពាគចក្រ ឥស្សរជនខ្មែរជាន់ខ្ពស់ នៅរង់ចាំក្រាបបង្គំថ្វាយព្រះពរស្វាគមន៍ដល់សម្តេចឪ មានជាអាទិ៍គឺសហជីវិន សាន-ណាក់ ហៅហ្វាយខែត្រកំពង់ស្ពឺ អ្នកអង្គម្ចាស់ម៉ុងតាណា ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ អ្នកអង្គម្ចាស់កន្ទុល នាយករដ្ឋមន្ត្រី សហជីវិន អ៊ុង-ហុងសាធ ប្រធានរដ្ឋសភា ឯកឧត្តម សាន-យុន ឧត្តមសេនីយ៍ទោ ង៉ោ-ហ៊ូ សមាជិកសភាតាំងពីរ សមាជិករដ្ឋាភិបាល ។

នៅម៉ោង ៩ សម្តេចព្រះមាតាជាតិ ស្តេចយាងមកតាមព្រះទីនាំងរថយន្តកាត់ក្រុងខុដ្ឋ ។ ព្រះអង្គបានទទួលការផ្កាពីនារី ជានិមិត្តរូបថ្វាយព្រះពរស្វាគមន៍ ហើយនឹងការរៀបចំពីកងកំឡាំងជាតិ និងការបទ្ទីក្មេងជាតិថ្វាយជាព្រះរាជកិត្តិយស ។

លុះសម្តេចទាំងពីរព្រះអង្គទ្រង់គង់សម្រួលព្រះឥរិយាបថហើយ ទើបព្រះសង្ឃស្វាធ្យាយធម៌ជយន្តោថ្វាយ ដើម្បីជាគជ័យសិរីសួស្តី ។

បន្ទាប់មក ព្រះពោធិវង្ស ហួត-តាត ថ្លែងសុន្ទរកថារៀបរាប់អំពីការកសាងវិហារថ្មី ហើយនឹងថ្វាយចំពោះសម្តេចជាអម្ចាស់ទាំងពីរព្រះអង្គ នូវព្រះបុញ្ញកុសល ដែលកើតឡើងពីការកសាងព្រះវិហារនេះ ។

(នៅមានត)

# អំពីព្រះនាមព្រះតេជព្រះគុណ

## ដែលបានទទួលសញ្ញាប័ត្រតាំង

## ជាចៅអធិការនិងគ្រូសូត្រក្នុងវត្តនានា

## ក្នុងព្រះរាជអាណាចក្រ

(ត)

---

៣៧- ព្រះតេជព្រះគុណ អ៊ុំ-សាំងលាង នាមឆាយាសុន្ទរប្បញ្ញោ កើតពីគ.ស. ១៩៣៩ អាយុ ២៣ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្តពូនក់ថ្មី ឃុំក្រពាំងសាន ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាប័ត្រ ៣៤២១ ចុះថ្ងៃទី ២២-១១-៦២ ។

៣៨- ព្រះតេជព្រះគុណ ទិត-ឡូត នាមឆាយាបញ្ញាជោតិ កើតពី គ.ស. ១៨៩៥ អាយុ ៦៩ ឆ្នាំ វស្សា ៤៨ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តខ្យុំទាងដើង ឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង លេខសញ្ញាប័ត្រ ៣៤២២ ចុះថ្ងៃទី ២២-១១-៦២ ។

៣៩- ព្រះតេជព្រះគុណ សុក-ស៊ុន នាមឆាយាឥន្ទបញ្ញោ កើតពី គ.ស. ១៩២៩ អាយុ ៣៣ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាឧបជ្ឈាយ៍ ក្នុងវត្តចេតិយថ្មី ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ៣៤២៣ ចុះថ្ងៃទី ៣.១២-៦២ ។

៤០- ព្រះតេជព្រះគុណ អ៊ុំ-ស៊ិន នាមឆាយាសុជនថេរ កើតពី គ.ស. ១៩៣៥ អាយុ ២៧ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាចៅអធិការ

កុដិវត្តបេតិយថ្ម ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣៤៤៤ ចុះថ្ងៃទី ៣-១២-៦២ ។

៤១- ព្រះតេជព្រះគុណ ពត-សុខ នាមឆាយា ខេមបញ្ញោ ថេរ កើតពី គ.ស. ១៩២៥ អាយុ ៣៧ ឆ្នាំ វស្សា ១៨ បានទទួលតែងតាំងជាចេដ្យាយ៍ កុដិវត្តជ្រោយពិសី ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣៤៤៥ ចុះថ្ងៃទី ៣-១២-៦២ ។

៤២- ព្រះតេជព្រះគុណ អួង-ប៉ក់ នាមឆាយាគម្ពីរជោតកោ កើតពី គ.ស. ១៩៣៤ អាយុ ២៨ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាចៅអធិការ វត្តជ្រោយពិសី ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣៤៤៦ ចុះថ្ងៃទី ៣-១២-៦២ ។

៤៣- ព្រះតេជព្រះគុណ អ៊ុក-ប៉ម នាមឆាយាឥន្ទត្ថេរ កើតពីគ.ស. ១៩៣២ អាយុ ៣០ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិ វត្តជ្រោយពិសី ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣៤៤៧ ចុះថ្ងៃទី ៣-១២-៦២ ។

៤៤- ព្រះតេជព្រះគុណ គង់-សុត នាមឆាយាធម្មោបទីបោ កើតពី គ.ស. ១៩៣៥ អាយុ ២៧ ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង កុដិវត្តជ្រោយពិសី ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣៤៤៨ ចុះថ្ងៃទី ៣-១២-៦២ ។

៤៥- ព្រះតេជព្រះគុណ ខឹម-សុខុន នាមឆាយាពុទ្ធបញ្ញោ កើតពី គ.ស. ១៩២៨ អាយុ ៣៤ ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ គង់វត្តមង្គលសត្ថារ៉ែន ឃុំព្រែកតាសេក ស្រុកមុខកំពូល ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣៤២៩ ចុះថ្ងៃទី ១៥.១២.៦២ ។

៤៦- ព្រះតេជព្រះគុណ មា៉-សារេត នាមឆាយាគតិវេក កើតពី គ.ស. ១៩៣៩ អាយុ ២៣ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង គង់វត្តមង្គលសត្ថារ៉ែន ឃុំព្រែកតាសេក ស្រុកមុខកំពូល ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣៤៣០ ចុះថ្ងៃទី ១៥-១២-៦២ ។

៤៧- ព្រះតេជព្រះគុណ អ៊ុយ-ឡឹង នាមឆាយាតិស្សតេរ កើតពី គ.ស. ១៩០១ អាយុ ៦១ ឆ្នាំ វស្សា ៣៧ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ គង់វត្តសន្ទះពេជ្រ ឃុំកន្ទោក ស្រុកកំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣៤៣១ ចុះថ្ងៃទី ១៥-១២-៦២ ។

៤៨- ព្រះតេជព្រះគុណ ចោយ-ខុឹង នាមឆាយាមង្គលតេរ កើតពី ឆ្នាំរកា អាយុ ៤២ ឆ្នាំ វស្សា ២២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង គង់វត្តសន្ទះពេជ្រ ឃុំកន្ទោក ស្រុកកំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣៤៣២ ចុះថ្ងៃទី ១៥-១២-៦២ ។

៤៩- ព្រះតេជព្រះគុណ លឹម-លន់ នាមឆាយាខេមានន្ទោ កើតពី គ.ស. ១៩៣៣ អាយុ ២៣ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាគ្រូ

សូត្រស្តាំ វត្តសំពោង ឃុំថ្នល់ ស្រុកល្វាឯម ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៣៣ ចុះថ្ងៃទី ១៥.១២.៦២ ។

៥០- ព្រះតេជព្រះគុណយូរ-យ៉ែម នាមឆាយាឥសិទត្តោ កើតពី គ.ស. ១៩០៥ អាយុ ៥៧ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្តសំពោង ឃុំថ្នល់ ស្រុកក្តីពេញ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៣៤ ចុះថ្ងៃទី ១៥.១២.៦២ ។

៥១- ព្រះតេជព្រះគុណ តូប-សុក នាមឆាយា សុវណ្ណបញ្ញោ កើតពី គ.ស. ១៨៩០ អាយុ ៧៤ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តពោធិវង្ស ឃុំចំការសំរោង ស្រុក ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣៤៣៥ ចុះថ្ងៃទី ១៥.១២.៦២ ។

៥២- ព្រះតេជព្រះគុណ ទេព-គាប់ នាមឆាយាអគ្គសោ កើតពី គ.ស. ១៩៤០ អាយុ២៤ឆ្នាំ វស្សា៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្តពោធិវង្ស ឃុំចំការសំរោង ស្រុកខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣៤៣៦ ចុះថ្ងៃទី ១៥.១២.៦២ ។

ព្រះតេជព្រះគុណ ម៉ឹង-យៀម នាមឆាយាចន្ទសោភោ កើតពី គ.ស. ១៩៣៩ អាយុ ២៥ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្តពោធិវង្សឃុំចំការសំរោង ស្រុកខេត្តបាត់ដំបង លេខសញ្ញា-ប័ត្រ ៣៤៣៧ ចុះថ្ងៃទី ១៥-១២-៦២ ។

៩៤- ព្រះតេជព្រះគុណ ហែម-នាង នាមធាយា ឥន្ទបញ្ញោ កើតពីគ.ស. ១៩១៤ អាយុ ៥០ ឆ្នាំ វស្សា ២៧ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តកំពង់កែវអណ្តែត ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៣៨ ចុះថ្ងៃទី ១៩-១២-៦៤ ។

៩៥- ព្រះតេជព្រះគុណ គង់-ញឹម នាមធាយា សុវណ្ណកេសរ កើតពីគ.ស. ១៩២០ អាយុ ៤៤ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងកំពង់កែវអណ្តែតឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤៣៩ ចុះថ្ងៃទី ១៩-១២-៦៤ ។

៩៦- ព្រះតេជព្រះគុណ ហ៊ុយ-នាង នាមធាយា ឥន្ទបាលោ កើតពីគ.ស. ១៨៩៤ អាយុ ៧០ ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្តកំពង់កែវអណ្តែត ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៤០ ចុះថ្ងៃទី ១៩-១២-៦៤ ។

៩៧- ព្រះតេជព្រះគុណ ក៉ន់.វ៉ែន នាមធាយា ធម្មរក្ខិត កើតពីគ.ស. ១៩១៤ អាយុ ៤៨ ឆ្នាំ វស្សា ២៧ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តសិរីវន្នា ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៤១ ចុះថ្ងៃ ២៩-១២-៦៤ ។

(នៅមានត)